# ព្រះពោធិសត្វ

## ភាគទី ១



# ១_វានរិន្ទជាតក

បិដកលេខ ៥៨ , ទំព័រ ២៥

**យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ អតិវត្តតីតិ។**

( ក្រពើពោលថា ) បពិត្រ វានរិន្ទ បុគ្គលណា មានធម៌ ៤ ប្រការដូចអ្នក គឺសេចក្ដីទៀងទាត់ ១ ធម៌ គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការបរិច្ចាគ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ។



## អដ្ឋកថា វានរិន្ទជាតក

ព្រះបរមសាស្ដា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ដែលមានការខ្វល់ខ្វាយ រកឧបាយវិធីសព្វគ្រប់ ដើម្បីធ្វើឃាតព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនានេះ **យស្សេតេ ចតុរោ ធម្មា** ដូច្នេះជាដើម ។

ក្នុងសម័យនោះ ព្រះសាស្ដាទ្រង់បានស្ដាប់ដំណឹងថា ភិក្ខុទេវទត្តកំពុងប្រឹងប្រែងក្នុងការធ្វើឃាតព្រះអង្គ ទើបទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ មិនមែនទើបតែក្នុងពេលនេះទេ ដែលទេវទត្តខំប្រឹងប្រែង ដើម្បីសម្លាប់តថាគតនោះ ក្នុងកាលមុនក៏ខិតខំដូចគ្នាដែរ ប៉ុន្តែមិនអាចធ្វើសូម្បីតែសេចក្ដីតក់ស្លុតឱ្យដល់តថាគតបានឡើយ »។រួចហើយព្រះអង្គក៏នាំយករឿងក្នុងអតីតមកសាធក ( សម្ដែងប្រាប់ ) ដូចតទៅនេះ ។

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្តសោយ-រាជសម្បត្តិក្នុងក្រុងពារាណសី ព្រះពោធិសត្វសោយព្រះ-ជាតិជាពានរ ។ កាលដែលមានវ័យចម្រើនហើយ ក៏មានរាងកាយធំប៉ុនកូនសេះ សម្បូណ៌ទៅដោយកម្លាំង ត្រាច់ទៅតាមមាត់ទន្លេតែឯកឯង ។ នៅកណ្ដាលទន្លេឯណោះមានកោះមួយ ដែលសម្បូណ៌ទៅដោយដើមឈើមានផ្លែផ្សេងៗ មានស្វាយនិងខ្នុរជាដើម ។ ព្រះពោធិសត្វមានកម្លាំងដូចដំរីសារ លោតអំពីត្រើយខាងនេះហើយ ទៅឈប់នៅនឹងថ្ម ១ ដុំធំ ដែលលេចចេញពីទឹក នៅត្រង់រវាងត្រើយហើយនឹងកោះ រួចហើយលោតពីផែនថ្មនោះ ទៅដល់កោះ បរិភោគផ្លែឈើលើកោះនោះ យ៉ាងសប្បាយ ។ ដល់ពេលល្ងាច ក៏លោតត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ដោយឧបាយនោះឯង ។ ដល់ពេលស្អែកឡើង ក៏ទៅដូច្នោះទៀត ស្នាក់នៅទីនោះ ដោយនិយាម (ទំនៀម-ទម្លាប់) នេះឯង ។

ក្នុងគ្រាកាលនោះ មានក្រពើឈ្មោល ១ ព្រមដោយ



ក្រពើញីមួយទៀតជាប្រពន្ធរបស់ក្រពើឈ្មោលនោះ ដែលអាស្រ័យនៅនឹងដងទន្លេនោះឯង។ ក្រពើជាប្រពន្ធ ឃើញព្រះពោធិសត្វលោតទៅ លោតមក ក៏កើតការចាញ់គភ៌ត្រូវការបរិភោគសាច់បេះដូងរបស់ព្រះពោធិសត្វ ទើបនិយាយនឹងក្រពើជាប្តី :

**មេ** : សូមជម្រាបលោកប្តី នាងខ្ញុំកើតការចាញ់គភ៌ ត្រូវការបរិភោគសាច់បេះដូងរបស់វានរិន្ទនេះ ។

**ឈ្មោល** : បាន ប្រពន្ធសម្លាញ់ នាងប្រាកដជាបាន ថ្ងៃនេះ បងនឹងចាំចាប់វា នៅពេលល្ងាច ដែលវាត្រឡប់មកអំពីកោះវិញ ។

ដល់ពេលសមរម្យហើយ ក្រពើជាប្តីក៏បានទៅដេកចាំលើផែនថ្ម ។

ព្រះពោធិសត្វ ទៅនៅនឹងកោះអស់ ១ ថ្ងៃវាស់-ល្ងាច ដល់ពេលត្រូវត្រឡប់មកវិញ ក៏ឈប់នៅនឹងជាយកោះ សម្លឹងមើលផែនថ្ម ហើយបានគិតថា ឥឡូវនេះ ផែនថ្មមានកម្ពស់ជាងមុន តើព្រោះហេតុអ្វីហ្ន៎ ។

ព្រះពោធិសត្វ បានកំណត់កម្ពស់ទឹក និងកម្ពស់ថ្ម បានយ៉ាងល្អត្រឹមត្រូវ ព្រោះហេតុនោះ ទើបមានសេចក្ដីត្រិះរិះថា ថ្ងៃនេះ ទឹកមិនស្រកចុះ ហើយក៏មិនមានឡើងដែរ កាលបើដូច្នេះ ម៉េចបានជាថ្មខ្ពស់ឡើង ក្រែងក្រពើវាដេកចាំចាប់យើងលើផែនថ្មនោះទេដឹង ។

ព្រះពោធិសត្វ គិតថា យើងនឹងបញ្ជាក់មើលឱ្យដឹងច្បាស់សិន រួចហើយបានស្រែកហៅទៅរកដុំថ្មថា « អើយផែនថ្មដ៏ចម្រើន » ។ មិនមានពាក្យឆ្លើយតបឡើយ ក៏បានស្រែកហៅថ្មដល់ទៅ ៣ ដង ។ តើឱ្យថ្មឆ្លើយតបយ៉ាងដូចម្ដេចទៅ ។ វានរិន្ទពោធិសត្វ នៅតែនិយាយទៅរកថ្មទៀតថា « ផែនថ្មដ៏ចម្រើន ថ្ងៃនេះយ៉ាងម៉េចហ្នឹង បានជាមិនឆ្លើយតបនឹងខ្ញុំ » ។

ក្រពើបានស្ដាប់ហើយគិតថា ក្នុងថ្ងៃមុនៗ ផែនថ្មនេះ ពិតជាឆ្លើយតបនឹងវានរិន្ទមែនហើយ ឥឡូវនេះ យើងនឹងឆ្លើយទៅរកគេ :

**ក្រពើ** : មានការអ្វី វានរិន្ទដ៏ចម្រើន ?



**វានរិន្ទ** : អ្នកឯងជាអ្នកណា ?

**ក្រពើ** : យើងជាក្រពើ ។

**វានរិន្ទ** : អ្នកឯងមកដេកទីនេះ ដើម្បីត្រូវការអ្វី?

**ក្រពើ** : ដើម្បីត្រូវការសាច់បេះដូងរបស់អ្នក ។

ព្រះពោធិសត្វគិតថា យើងមិនមានផ្លូវដទៃទៅឡើយ ដូច្នេះ ពេលនេះយើងត្រូវប្រើឧបាយជាមួយនឹងក្រពើនេះ ។ គ្រាដែលគិតរួចហើយ ទើបនិយាយទៅកាន់ក្រពើថា « នែ ក្រពើសម្លាញ់ យើងនឹងលះបង់រាងកាយឱ្យដល់អ្នក ចូរអ្នកហាមាត់រង់ចាំទទួលយើងចុះ » ។ ជាធម្មតានៃសត្វក្រពើ នៅពេលហាមាត់ ភ្នែកទាំង ២ របស់វារមែងបិទ ដោយក្រពើនោះ មិនបានកំណត់ហេតុនេះ ក៏ហាមាត់រង់ចាំ ។ ព្រះពោធិសត្វដឹងនូវសភាពនោះហើយ ក៏លោតអំពីកោះមកជាន់លើក្បាលក្រពើ ហើយលោតពីក្បាលក្រពើមករកត្រើយ លឿនដូចផ្លេកបន្ទោរ ។

ក្រពើឃើញហេតុអស្ចារ្យនោះ ក៏គិតថា វានរិន្ទនេះ ធ្វើការគួរឱ្យអស្ចារ្យណាស់ ។ ភ្លាមនោះក្រពើបាន

ពោលថា « វានរិន្ទ ដ៏ចម្រើន ក្នុងលោកនេះ បុគ្គលប្រកបដោយធម៌ ៤ ប្រការ រមែងគ្របសង្កត់នូវសត្រូវបាន ធម៌ទាំងនោះ បានកើតមានដល់អ្នកគ្រប់យ៉ាង » ។ រួចហើយ ក្រពើបានពោលនូវគាថានេះ ដោយសេចក្តីថា :

- « បពិត្រ វានរិន្ទ បុគ្គលណា មានធម៌ ៤ ប្រការ ដូចអ្នក គឺសេចក្តីទៀងទាត់ ១ , ធម៌គឺប្រាជ្ញាជាគ្រឿងពិចារណា ១ , ព្យាយាមមិនដាច់ ១ , ការបរិច្ចាគ ១ , បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន » ។

បណ្តាបទទាំងនោះ បទថា **យស្ស** បានដល់បុគ្គលណាមួយ ។

បទថា **ឯតេ** ដោយសេចក្តីថា រមែងប្រាកដដោយប្រចក្សក្នុងធម៌ ដែលយើងនឹងពោលក្នុងពេលនេះ ។

បទថា **ចតុរោ ធម្មា** បានដល់គុណធម៌ ៤ ប្រការ។

បទថា **សច្ចំ** បានដល់វចីសច្ចៈ គឺដែលអ្នកប្រាប់ថានឹងមកកាន់សំណាក់របស់យើង អ្នកក៏មិនបានពោលកុហក អ្នកមកពិត១ នេះជាវចីសច្ចៈរបស់អ្នក ។



បទថា **ធម្មោ** បានដល់វិចារណបញ្ញា ពោលគឺ ការចេះពិចារណាថា កាលបើធ្វើយ៉ាងនេះហើយ នឹងត្រូវបានផលយ៉ាងនេះ ចំណុចនេះ ជាវិចារណបញ្ញារបស់អ្នក ។

សេចក្តីព្យាយាមមិនដាក់ធុរៈ ប្រឹងប្រែងមិនដាច់ លោកហៅថា **ធិតិ** សូម្បីគុណធម៌នេះ ក៏មានដល់អ្នក ។

បទថា **ចាគោ** បានដល់ ការលះបង់ខ្លួន គឺការដែលអ្នកលះជីវិត មកដល់សំណាក់យើង តែយើងមិនអាចចាប់អ្នកបាន នេះជាទោសរបស់យើងតែម្ខាង ។

បទថា **ទិដ្ឋំ** បានដល់បច្ចាមិត្ត ។

បទថា **សោ អតិវត្តតិ** ដោយសេចក្តីថា ធម៌ ៤ យ៉ាង ដូចពណ៌នាមកនេះ មានដល់បុគ្គលណា ដូចជាមានដល់អ្នក បុគ្គលនោះ រមែងឈានកន្លង គឺគ្របសង្កត់បាននូវបច្ចាមិត្តរបស់ខ្លួន ដូចជាអ្នកដែលបានកន្លងផុតយើងទៅ នៅក្នុងថ្ងៃនេះឯង ។

ក្រពើសរសើរព្រះពោធិសត្វយ៉ាងនេះហើយ ក៏ទៅកាន់លំនៅរបស់ខ្លួន ។

ព្រះបរមសាស្តា បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនទើបតែប្រឹងប្រែងដើម្បីសម្លាប់យើង ក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ខំប្រឹង-ប្រែងដូចគ្នាដែរ ។ ព្រះអង្គ ទ្រង់បាននាំព្រះធម៌ទេសនានេះមកហើយ ព្រះអង្គត្រាស់បន្តអនុសន្ធិ ប្រជុំជាតកថា ក្រពើក្នុងកាលនោះ បានមកជាភិក្ខុទេវទត្តក្នុងកាលនេះ ក្រពើជាប្រពន្ធ បានមកជានាងចិញ្ចា ចំណែកវានរិន្ទ បានមកជា **តថាគត** យ៉ាងនេះឯង ។

**ចប់ វានរិន្ទជាតក**



# ២.តយោធម្មជាតក

បិដកលេខ ៥៨ , ទំព័រ ២៥

**យស្សេតេ ច តយោ ធម្មា វានរិន្ទ យថា តវ**
**ទក្ខិយំ សូរិយំ បញ្ញា ទិដ្ឋំ សោ អតិវត្តតីតិ។**

(អារក្សទឹកពោលថា ) បពិត្រ វានរិន្ទ បុគ្គលណា មានធម៌ ៣ ប្រការដូចអ្នក គឺសេចក្តីសង្វាត ១ សេចក្តីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន ។

## អដ្ឋកថា តយោធម្មជាតក

ព្រះបរមសាស្តា កាលដែលទ្រង់គង់ប្រថាប់នៅព្រះវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធការដែលភិក្ខុទេវទត្តខិតខំប្រឹងប្រែងធ្វើឃាតព្រះអង្គនោះឯង ទ្រង់ត្រាស់ព្រះធម៌ទេសនានេះ មានពាក្យជាអាទិ៍ថា **យស្សេតេ ច តយោ ធម្មា** ។

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅក្រុងពារាណសី ភិក្ខុទេវទត្ត កើតក្នុងកំណើតពានរ គ្រប់គ្រងហ្វូងស្វាក្នុងដែនដីនៃព្រៃហិមពាន្ត ។ កាលកូនពានរដែលអាស្រ័យនឹងខ្លួនចម្រើនធំហើយ ពានរជាឪពុក ចិត្តអាក្រក់ បានខាំប្រដាប់បន្តពូជនៃកូនពានរទាំងនោះឱ្យដាច់អស់ ព្រោះខ្លាចថា ពានរទាំងនេះនឹងដណ្តើមគ្រប់គ្រងហ្វូង ។

ក្នុងគ្រានោះ ព្រះពោធិសត្វក៏អាស្រ័យនឹងពានរចិត្ត



អាក្រក់នោះដែរ ហើយបដិសន្ធិក្នុងផ្ទៃនៃនាងពានរមួយដែលមានចិត្តល្អ ។ កាលដែលនាងពានរដឹងថាខ្លួនមានគភ៌ដើម្បីនឹងថ្នមគភ៌របស់ខ្លួន ក៏បានទៅកាន់ជើងភ្នំដទៃ រហូតដល់មានគភ៌ចាស់គ្រប់កំណត់ ក៏ប្រសូតព្រះពោធិសត្វ ។ ព្រះពោធិសត្វចម្រើនវ័យ ធំដឹងក្តីឡើង ជាសត្វដែលសម្បូណ៌ទៅដោយកម្លាំង ថ្ងៃមួយក៏បានសួរម្តាយ :

**កូន** : ម៉ែ អ្នកណាជាឪពុករបស់កូន ?

**ម៉ែ** : កូនសម្លាញ់ ឪពុករបស់កូនគ្រប់គ្រងហ្វូងនៅភ្នំឯណោះ ។

**កូន** : សូមម៉ែនាំកូនទៅរកឪពុកផង ណា៎ម៉ែ ។

**ម៉ែ** : កូនអើយ កូនមិនអាចចូលទៅជិតឪពុករបស់កូនបានទេ ព្រោះឪពុករបស់កូន តែងតែខាំប្រដាប់បន្តពូជនៃកូនពានរដែលអាស្រ័យនឹងខ្លួនដាច់អស់ ដោយខ្លាចថា មានការដណ្តើមគ្រប់គ្រងហ្វូង ។

**កូន** : សូមម៉ែនាំកូនទៅចុះ កូននឹងបានដឹង ។

នាងពានរ ក៏បាននាំព្រះពោធិសត្វមកកាន់សំណាក់

ពានរជាឪពុក ។

ពានរនោះឃើញកូនរបស់ខ្លួនហើយ ក៏គិតថា កាលដែលកូននេះធំពេញវ័យឡើង នឹងមិនព្រមឱ្យយើងគ្រប់គ្រងហ្វូងឡើយ ។ ដូច្នេះយើងត្រូវសម្លាប់វា ក្នុងគ្រានេះតែម្តង គឺយើងនឹងធ្វើដូចជា ស្រឡាញ់វាណាស់ យើងចាប់ឱបវា រួចហើយយើងចាប់ឱបវាឱ្យណែន ច្របាច់ឱ្យស្លាប់ឱ្យខាងតែបាន។ ពានរចិត្តឃោរឃៅ បានពោលទៅកូនថា «មកនេះកូនសម្លាញ់ កូនទៅណាអស់កាលដ៏យូរនេះ »។ ដូច្នេះហើយ ក៏ចាប់ព្រះពោធិសត្វឱបរឹត បន្តិចមក ក៏រឹតឱ្យណែន ។ ព្រះពោធិសត្វ មានកម្លាំងដូចដំរីសារ ដឹងខ្លួនថា មិនស្រួល ទើបឱបរឹតតបវិញរហូតដល់បាក់ឆ្អឹងពានរជាឪពុក ។

លំដាប់នោះ ពានរជាឪពុក កើតគំនិតថា អានេះធំឡើងវានឹងសម្លាប់យើង ។ ដូច្នេះយើងត្រូវរកឧបាយកលប្រញាប់សម្លាប់វាមុន។ រួចហើយក៏គិតឃើញថា មិនឆ្ងាយពីនេះ មានស្រះធំមួយដែលមានអារក្សទឹក យើងនឹងឱ្យ



អារក្សទឹកស៊ីវានៅនឹងស្រះនោះ ។ ពានរជាឪពុកបានពោលទៅព្រះពោធិសត្វ :

**ឪពុក** : កូនអើយ ឪពុកចាស់ហើយ ឪពុកចង់ប្រគល់ហ្វូងពានរទាំងអស់ឱ្យកូនគ្រប់គ្រង ។ ថ្ងៃនេះយើងនឹងតាំងកូនឱ្យធ្វើជាប្រមុខដឹកនាំ នៅត្រង់នោះមានស្រះមួយ ក្នុងស្រះនោះ មានជលជាតច្រើនមុខ កូនទៅចុះទៅយកផ្កាកុមុទ ២ ផ្កា ផ្កាឧប្បល ៣ ផ្កា និងផ្កាបទុម ៥ ផ្កា ដែលកំពុងរីក អំពីស្រះនោះមក។

**កូន** : ល្អណាស់ លោកឪពុក កូននឹងទៅភ្លាម ។

ព្រះពោធិសត្វទៅហើយ ប៉ុន្តែមិនប្រញាប់ប្រញាល់ចុះទៅក្នុងស្រះឡើយ នៅត្រួតមើលស្នាមជើងជុំវិញមាត់ស្រះនោះ ។ កាលដែលត្រួតមើល ក៏បានឃើញតែស្នាមចុះប៉ុណ្ណោះ មិនឃើញស្នាមឡើងមកវិញទេ ។ ក៏ដឹងថាស្រះនេះប្រាកដជាមានអារក្សទឹក ។ ឪពុកយើង មិនអាចសម្លាប់យើងបានដោយខ្លួនឯង ក៏មានបំណងឱ្យអារក្សទឹកស៊ីយើង ។ ដូច្នេះ យើងនឹងមិនចុះក្នុងស្រះទឹកនេះឡើយ

ហើយត្រូវយកផ្កាទាំងនេះឱ្យបាន ។

ព្រះពោធិសត្វដើរទៅកាន់ទីដែលមិនមានទឹក កាច់បានផ្កា ២ ហើយលោតទៅត្រើយម្ខាង និងលោតត្រឡប់មកវិញ ស្រវាបានផ្កា ២ ទៀត ។ ដោយឧបាយនេះឯងព្រះពោធិសត្វបានផ្កាទាំងកង ដោយមិនបាច់ចុះទៅក្នុងទឹកដែលជាទីឋិតនៅក្នុងអាជ្ញារបស់អារក្សទឹកនោះឡើយ ។

គ្រានោះ អារក្សទឹក មានសេចក្ដីត្រិះរិះថា អច្ឆរិយ-បុរសនេះ មានបញ្ញាណាស់ យើងមិនធ្លាប់ឃើញទេ ក្នុងជីវិតរបស់យើងនេះ ផ្កាជលជាតទាំងឡាយ ក៏យកបានតាមប្រាថ្នា ទាំងដែលមិនត្រូវចុះកាន់ស្ថានដែលជាកន្លែងឋិតក្នុងអាជ្ញារបស់យើងទៀត ។ អារក្សទឹកបានផុសចេញពីទឹក ឡើងទៅរកព្រះពោធិសត្វ ហើយបានពោលថា «វានរិន្ទ ក្នុងលោកនេះ បុគ្គលណា មានធម៌ ៣ ប្រការ បុគ្គលនោះ រមែងគ្របសង្កត់បច្ចាមិត្តបាន អស្ចារ្យណាស់ក្នុងខ្លួនរបស់អ្នក គឺមានធម៌ទាំងនោះ គ្រប់ប្រការជាប្រា-កដ » ។ កាលដែលអារក្សទឹកអបអរសាទរព្រះពោធិសត្វ



ទើបពោលនូវគាថានេះ ដោយសេចក្ដីថា :

« បពិត្រ វានរិន្ទ បុគ្គលណា មានធម៌ ៣ ប្រការដូចអ្នក គឺសេចក្ដីសង្វាត ១ សេចក្ដីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន » ។

បណ្ដាបទទាំងនោះ បទថា **ឧក្ខិយំ** បានដល់ ភាពជាអ្នកមានព្យាយាមខ្លាំងក្លា ។ បទនេះ ជាឈ្មោះនៃសេចក្ដីព្យាយាមដ៏ខ្ពស់ ដែលប្រកបព្រមដោយមូលគឺបញ្ញាកម្ចាត់បង់ភ័យគ្រប់ប្រការដែលមកដល់ខ្លួន ។

បទថា **សូរិយំ** បានដល់ភាពជាអ្នកក្លាហាន ។ បទនេះ ជាឈ្មោះរបស់ធម៌ដែលមិនញញើតខ្លាច ។

បទថា **បញ្ញា** នេះជាឈ្មោះនៃការដឹងឧបាយ ដែលជាចំណុចចាប់ផ្ដើមនៃការប្រាកដផល ។

អារក្សទឹកនោះ អបអរសាទរដល់ព្រះពោធិសត្វដែលមានគុណធម៌ទាំង ៣ ប្រការ ដោយគាថានេះហើយក៏សួរព្រះពោធិសត្វ :

**អារក្សទឹក** : លោកយកផ្កាជលជាតទាំងនេះទៅ

ធ្វើអ្វី ?

**ព្រះពោធិសត្វ** : ឪពុករបស់យើង ប្រាថ្នានឹងតាំងយើងឱ្យជាអ្នកដឹកនាំ យើងយកទៅព្រោះហេតុនោះឯង។

**អារក្សទឹក** : ឧត្តមបុរសដូចលោក មិនគួរនឹងនាំយកផ្កាទាំងនេះ ទៅដោយខ្លួនឯងទេ ខ្ញុំជាអ្នកនាំយកទៅឱ្យ ។

អារក្សទឹកបានចាប់ក្ដោបយកផ្កា ដើរតាមក្រោយព្រះពោធិសត្វទៅ ។

គ្រានោះ បិតារបស់ព្រះពោធិសត្វ បានមើលឃើញពីចម្ងាយ ហើយគិតថា យើងបញ្ជូនវាទៅ ឱ្យវាទៅជាអាហាររបស់អារក្សទឹក ឥឡូវនេះ វាត្រឡប់ជាប្រើឱ្យអារក្សទឹកកាន់ផ្កាដើរមកតាមក្រោយវា ពេលនេះយើងវិនាសហើយ យើងសែនឈឺចាប់ណាស់ ។ ពេលនោះពានរចិត្តឃោរឃៅ បានស្លាប់បាត់បង់ជីវិត ដោយបែកធ្លាយបេះដូងជា ៧ ចំណែក ។ ហ្វូងពានរ បានប្រជុំគ្នាលើកព្រះពោធិសត្វ ឱ្យជារាជា ដឹកនាំពួកខ្លួន ក្នុងដែនដី



នៃព្រៃហិមពាន្តនោះឯង ។

ព្រះបរមសាស្ដា កាលដែលទ្រង់នាំយកព្រះធម៌ទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ពានរជាមេហ្វូងក្នុងកាលនោះ បានមកជាភិក្ខុទេវទត្តក្នុងកាលនេះ ឯចំណែកពានរជាកូន បានមកជា **តថាគត** ដូច្នេះឯង ។

**ចប់ តយោធម្មជាតក**

## ៣-អត្ថស្ស ទ្វារជាតក

បិដកលេខ ៥៨ , ទំព័រ ៣៧

**អារោគ្យមិច្ឆេ បរមញ្ច លាភំ**

**សីលញ្ច ពុទ្ធានុមតំ សុតញ្ច**

**ធម្មានុវត្តី ច អលីនតា ច**

**អត្ថស្ស ទ្វារា បមុខា ឆឡេតេតិ ។**

(សេដ្ឋីពោធិសត្វជាបិតា ពោលថា ) បុគ្គល គប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ ១ សីល (គឺមារយាទល្អ ) ១ ការយល់ឃើញតាមបណ្ឌិតអ្នកចេះដឹង ១ ការឧស្សាហ៍ស្តាប់ ១ ការអនុវត្តនូវសុចរិតធម៌ ១ ការមិនរួញរានៃចិត្ត ១ គុណធម៌ទាំង ៦ ប្រការនេះ គឺជាទ្វារមុខនៃប្រយោជន៍ ។



## អដ្ឋកថា អត្ថស្ស ទ្វារជាតក

ព្រះបរមសាស្តា កាលដែលទ្រង់គង់ប្រថាប់នៅព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធកុលបុត្រម្នាក់ដែលជាអ្នកឆ្លាតក្នុងប្រយោជន៍ ព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនានេះ មានពាក្យជាអាទិ៍ថា **អារោគ្យមិច្ឆេ បរមញ្ច លាភំ។**

មានរឿងដោយសង្ខេបថា ក្នុងព្រះនគរសាវត្ថី មានបុត្រនៃសេដ្ឋីម្នាក់ កើតមកបាន ៧ ឆ្នាំ ក៏ជាអ្នកមានបញ្ញាឆ្លាតក្នុងប្រយោជន៍ ។ ថ្ងៃមួយគេបានចូលទៅរកបិតា ហើយសួរនូវបញ្ហា អំពីទ្វារនៃប្រយោជន៍ ។ លោកសេដ្ឋីជាបិតា មិនជ្រាបនូវបញ្ហានោះ ទើបមានសេចក្តីត្រិះរិះថា បញ្ហានេះ ល្អិតសុខុមណាស់ វៀរចាកព្រះសម្មាសម្ពុទ្ធហើយ អ្នកដទៃក្នុងលោកសន្និវាស មិនអាចនឹងដោះបញ្ហានេះបានឡើយ ។ លោកសេដ្ឋី បាននាំបុត្រឱ្យកាន់នូវគ្រឿងសក្ការបូជា ទៅកាន់មហាវិហារវត្តជេតពន ដល់ហើយ ក៏

បូជាព្រះសាស្តា ថ្វាយបង្គំ រួចក៏អង្គុយក្នុងទីដ៏សមគួរ ។ លោកសេដ្ឋីបានក្រាបទូលនូវសេចក្តីនេះ ដល់ព្រះដ៏មាន-ព្រះភាគថា « បពិត្រ ព្រះអង្គដ៏ចម្រើន ក្មេងនេះមានបញ្ញាឆ្លាតក្នុងប្រយោជន៍ គេបានសួរនូវទ្វារនៃប្រយោជន៍ ដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមិនជ្រាបនូវបញ្ហានោះ ទើបមកកាន់សំណាក់នៃព្រះអង្គ សូមព្រះដ៏មានព្រះភាគទ្រង់ដោះបញ្ហានោះឱ្យទាន » ។

ព្រះបរមសាស្តា ព្រះអង្គទ្រង់ត្រាស់ថា « ម្នាលគហបតី សូម្បីក្នុងកាលមុន តថាគតក៏ត្រូវក្មេងនេះ សួរបញ្ហាហ្នឹងដែរ តថាគតបានដោះនូវបញ្ហានោះឱ្យដល់គេហើយ ។ ក្នុងកាលនោះ ក្មេងនេះ ដឹងបញ្ហានោះ ប៉ុន្តែឥឡូវនេះ គេកំណត់មិនបាន ព្រោះការអស់ទៅនៃភពមុន » ។

លោកសេដ្ឋី បានក្រាបទូលអារាធនា ព្រះអង្គទ្រង់ក៏បាននាំយករឿងក្នុងអតីតមកសាធកដូចតទៅ :

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្ត សោយ-



រាជសម្បត្តិក្រុងពារាណសី ព្រះពោធិសត្វ សោយព្រះជាតិជាសេដ្ឋី មានសម្បត្តិច្រើន ។ កាលនោះ បុត្ររបស់លោកសេដ្ឋី កើតបាន ៧ ឆ្នាំ ជាអ្នកមានបញ្ញាឆ្លាតក្នុងប្រយោជន៍ ថ្ងៃមួយបានចូលទៅរកបិតា សួរបញ្ហាអំពីទ្វារនៃប្រយោជន៍ថា « បពិត្របិតា អ្វីឈ្មោះថាទ្វារនៃប្រយោជន៍ »។ គ្រានោះ បិតារបស់គេ កាលដែលនឹងពោលដោះបញ្ហានោះ បានពោលនូវគាថាថា « បុគ្គល គប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ ១ សីល (គឺមារយាទល្អ) ១ ការយល់ឃើញតាមបណ្ឌិតអ្នកចេះដឹង ១ ការឧស្សាហ៍ស្តាប់ ១ ការអនុវត្តនូវសុចរិតធម៌ ១ ការមិនរួញរានៃចិត្ត ១ គុណ-ធម៌ទាំង ៦ ប្រការនេះ គឺជាទ្វារមុខនៃប្រយោជន៍ »។

បណ្តាបទទាំងនោះ ៥ អក្សរក្នុងបទថា **អារោគ្យ-មិច្ឆេ បរមញ្ច លាភំ** គ្រាន់តែជានិបាត ។ ព្រះពោធិសត្វនៅពេលនោះបានសម្តែងនូវសេចក្តីនេះថា « នែកូន មុនអ្វីៗទៀតទាំងអស់ គប្បីប្រាថ្នាលាភដ៏ក្រៃលែង ពោលគឺការមិនមានរោគ » ។

ដែលឈ្មោះថា ភាពជាបុគ្គលមិនមានរោគ បានដល់អាការដែលមិនមានសភាវៈចាក់ដោត មិនមានការក្រវល់ក្រវាយនៃរាងកាយ និងផ្លូវចិត្ត ។ ព្រោះថា កាលដែលរាងកាយត្រូវចាក់ដោតដោយរោគ មានការក្រវល់-ក្រវាយនោះ បុគ្គលរមែងមិនអាចនឹងញុំាងលាភដែលនៅមិនទាន់បាន ឱ្យកើតឡើង និងដែលបានយកមកទុកដាក់ហើយ ក៏មិនអាចនឹងប្រើប្រាស់បានឡើយ ប៉ុន្តែកាលដែលមិនមានការក្រវល់ក្រវាយដោយរោគទេ ក៏រមែងអាចបណ្តាលឱ្យកើតបានទាំង ២ ស្ថាននោះឯង ។ ម្យ៉ាងទៀត កាលបើចិត្តមានការក្តៅក្រហាយដោយឧបក្កិលេស បុគ្គលក៏មិនអាចនឹងញុំាងលាភ គឺគុណវិសេស មានឈានជាដើម ដែលនៅមិនទាន់កើត ឱ្យកើតបានឡើយ ទាំងដែលបានហើយ ក៏ប្រាសចាកប្រយោជន៍ តែបើរោគមិនមានទេ គឺអាចញុំាងលាភ បានដល់គុណវិសេសឱ្យកើតឡើងបាន ដែលបានហើយ ក៏អាចរីករាយដោយអំណាចនៃសមាបត្តិតទៅទៀត ។ ហេតុនោះ ការមិនមានរោគ ទើបឈ្មោះថា



ជាលាភដ៏ក្រៃលែង ដែលចាំបាច់ត្រូវប្រាថ្នានូវការមិនមានរោគនេះ មុនអ្វីៗទាំងអស់ នេះជាទ្វារឯកនៃប្រយោជន៍ ។ ទាំងអស់នេះ ជាអត្ថាធិប្បាយក្នុងចំណុចនោះ ។

បទថា **សីលញ្ញូ** បានដល់អាចារសីល គឺរបៀបរបបនៃមារយាទល្អ ។ ព្រះពោធិសត្វសម្តែងដល់ ចរិតរបស់ពពួកជន ដោយបទនេះ ។

បទថា **វុឌ្ឍានុមតំ** បានដល់ការប្រព្រឹត្តតាមបណ្ឌិតអ្នកចម្រើនដោយគុណទាំងឡាយ ។ ព្រះពោធិសត្វសម្តែងឱវាទរបស់គ្រូទាំងឡាយ ដែលសម្បូណ៌ដោយការចេះដឹង ដោយបទនេះ ។

បទថា **សុតញ្ញូ** គឺការស្តាប់ដោយអាងហេតុ ។ ព្រះពោធិសត្វសម្តែងពាហុសច្ចៈ ភាពនៃបុគ្គលមានការសិក្សាដ៏មុតមាំ ដែលអាស្រ័យនឹងខ្លួនឯងក្នុងលោកនេះ ដោយបទនេះ ។

បទថា **ធម្មានុវត្តី ច** បានដល់ការអនុវត្តតាមសុចរិតធម៌មាន ៣ យ៉ាង ។ ព្រះពោធិសត្វសម្តែងអំពីការ

វៀរចាកនូវទុច្ចរិតធម៌ ហើយប្រព្រឹត្តសុចរិតធម៌ ដោយបទនេះ ។

បទថា **អលីនតា ច** បានដល់ភាពនៃចិត្តដែលមិនរួញរា មិនធ្លាក់ចុះ ។ ព្រះពោធិសត្វសម្ដែងអំពីសភាពនៃចិត្តដែលប្រណីត និងដែលខ្ពង់ខ្ពស់ដ៏ក្រៃលែង មានសភាពមិនបាត់បង់នូវសេចក្ដីព្យាយាម ដោយបទនេះ ។

បទថា **អត្ថស្ស ទ្វារា បមុខា ឆឡេតេ** ដោយសេចក្ដីថា ការចម្រើន ឈ្មោះថា ប្រយោជន៍ ធម៌ទាំង ៦ ប្រការនេះ ជាទ្វារ ជាឧបាយ គឺជាផ្លូវនៃការសម្រេចដ៏ខ្ពង់ខ្ពស់ ជាទ្វារមុខនៃប្រយោជន៍ ទាំងដែលជាប្រយោជន៍លោកិយ ទាំងដែលជាប្រយោជន៍លោកុត្តរ ពោលគឺសេចក្ដីចម្រើន ។ ព្រះពោធិសត្វ ពោលដោះបញ្ហាទ្វារនៃប្រយោជន៍ ដល់បុត្រដោយប្រការដូច្នេះ ។ តាំងតែពីកាលនោះមក គេក៏បានប្រព្រឹត្តនៅក្នុងធម៌ទាំង ៦ ប្រការនោះ ។ ព្រះពោធិសត្វ បំពេញបុណ្យ មានទានជាដើម ហើយក៏ទៅតាមយថាកម្ម ។



ព្រះបរមសាស្ដា ទ្រង់នាំព្រះធម៌ទេសនានេះមក ហើយ ប្រជុំជាតកថា បុត្រក្នុងគ្រានោះ បានមកជាបុត្រក្នុងបច្ចុប្បន្ននេះ ចំណែកមហាសេដ្ឋីបានមកជា **តថាគត** ដូច្នេះឯង ។

**ចប់ អត្ថស្ស ទ្វារជាតក**

# ៤_គោធជាតក

បិដកលេខ ៥៨ , ទំព័រ ៦១

**កិន្តេ ជដាហិ ទុម្មេធ　　កិន្តេ អជិនសាដិយា**
**អព្ភន្តរន្តេ គហនំ　　ពាហិរំ បរិមជ្ជសីតិ។**

(ទន្សងពោធិសត្វ ពោលថា ) ម្នាលតាបសឥតបញ្ញា ប្រយោជន៍អ្វីដោយជដារបស់អ្នក និងប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះគ្រឿងសាំញ៉ាំ គឺកិលេស មាននៅខាងក្នុងខ្លួនអ្នក អ្នកខំដុសខាត់តែខាងក្រៅទេ ។



## អដ្ឋកថា គោធជាតក

ព្រះបរមសាស្តា កាលដែលទ្រង់គង់ប្រថាប់នៅព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុដែលជាអ្នកបោកបញ្ឆោតគេ ១ អង្គ ។ ព្រះអង្គទ្រង់ត្រាស់សម្តែងនូវរឿងក្នុងអតីតកាលមានដូចតទៅ :

ក្នុងអតីតកាល គ្រាដែលព្រះបាទព្រហ្មទត្ត សោយ-រាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វ បដិសន្ធិក្នុងកំណើតសត្វទន្សង ។ កាលនោះ មានតាបស ១ អង្គបានអភិញ្ញា ៥ មានតបៈដ៏ខ្លាំងក្លា អាស្រ័យនៅឯបច្ចន្ត-គ្រាម ក្នុងតំបន់មួយដែលមានបណ្ណសាលា នៅនឹងជាយព្រៃ ។ ពួកអ្នកស្រុក បានជួយគ្នាទំនុកបម្រុងព្រះតាបសដោយសេចក្តីគោរព ។ ព្រះពោធិសត្វ បានរស់នៅនឹងរន្ធដំបូកមួយ ខាងចុងទីចង្ក្រមរបស់ព្រះតាបសនោះឯង ហើយតែងតែចេញពីរន្ធមករកព្រះតាបស ១ ថ្ងៃ , ៣ ដង

រាល់ៗថ្ងៃ ស្តាប់ពាក្យដែលប្រកបដោយហេតុ ប្រកបដោយផល ថ្វាយបង្គំព្រះតាបសហើយ ក៏ត្រឡប់ទៅកាន់ទីរបស់ខ្លួនវិញ ។ ក្រោយមក ព្រះតាបសក៏បានចម្រើនពរលាពួកអ្នកស្រុកចេញទៅ ។ កាលដែលព្រះតាបសសម្បូរដោយសីលនិងវត្តនោះចេញទៅហើយ បន្ទាប់មក ក៏មានតាបស ១ អង្គទៀត មកសំណាក់នៅនឹងអាស្រមបទនោះដែរ ។ ព្រះពោធិសត្វកំណត់ថា តាបសក្រោយ ក៏ជាអ្នកមានសីល ទើបបានចូលទៅកាន់សំណាក់របស់តាបសបំពេញកិច្ចវត្តដូចមុនដែរ ។

ក្រោយមកថ្ងៃមួយ ស្រាប់តែមានភ្លៀងធ្លាក់យ៉ាងខ្លាំង ក្នុងរដូវរាំងស្ងួត ហ្វូងមេភ្លៀងបាននាំគ្នាចេញអំពីដំបូកទាំងឡាយ ពួកសត្វទន្សង ក៏បាននាំគ្នាចេញមកបរិភោគមេភ្លៀងទាំងនោះ ។ ក្នុងកាលនោះ ពួកអ្នកស្រុកបាននាំគ្នាចេញចាប់ទន្សងបានយ៉ាងច្រើន ហើយចាត់ចែងស្លម្ជូរគ្រឿងដ៏មានឱជារស ប្រគេនដល់តាបស ។ តាបសឆាន់សម្លម្ជូរគ្រឿងសាច់ទន្សងឆ្ងាញ់ ជាប់ចិត្តនឹងរសនោះ



ទើបសួរថា សម្លនេះឆ្ងាញ់ក្រៃលែងណាស់ តើសាច់នេះជាសាច់សត្វប្រភេទណា ? កាលដែលបានឮគេប្រាប់ថា ជាសាច់សត្វទន្សងហើយ ក៏គិតថា ទន្សងដ៏ធំនោះ មកកាន់សំណាក់របស់យើង យើងនឹងសម្លាប់វាស្លម្ជូរគ្រឿង ។ តាបសកំហូច ឱ្យគេនាំយកឆ្នាំងសម្រាប់ស្ល និងគ្រឿងផ្សំផ្សេងៗ មានទឹកដោះថ្លា និងអំបិលជាដើម ទុកនៅមួយកន្លែង ហើយលាក់ដំបងក្នុងសំពត់ដណ្ដប់ រង់ចាំការមកនៃព្រះពោធិសត្វ ។ តាបសកំហូចរង់ចាំនៅនឹងទ្វារបណ្ណសាលា អង្គុយរៀបឥរិយាបថដូចជាមានសេចក្ដីស្ងប់ណាស់ ។

ក្នុងវេលាល្ងាច ព្រះពោធិសត្វ គិតថា យើងនឹងទៅរកតាបស ហើយក៏ចេញដំណើរទៅ ខណៈដែលកំពុងតែចូលទៅជិតនោះឯង ក៏បានឃើញចំណុចខុសប្លែកនៃឥន្ទ្រិយរបស់តាបស ទើបគិតថា តាបសនេះ មិនបានអង្គុយដោយឥរិយាបថ ដែលធ្លាប់អង្គុយ ដូចថ្ងៃមុនៗទេ សូម្បីតែសម្លឹងមើលយើងក្នុងថ្ងៃនេះទៀតសោត ក៏សម្លឹង

ជារបៀបលួចលាក់ ។ ព្រះពោធិសត្វ បានទៅពីក្រោមខ្យល់នៃតាបស ហើយក៏បានធុំក្លិនសាច់ទន្សង ក៏បានគិតថា ថ្ងៃនេះ តាបសកំហូចនេះ មុខតែបរិភោគសាច់ទន្សងជាប់ចិត្តក្នុងរសហើយ ឥឡូវនេះ បំណងដើម្បីនឹងវាយសម្លាប់យើងដែលចូលទៅរកដោយដំបង ហើយយកសាច់របស់យើងស្ងោរស៊ីជាប្រាកដ ។ ព្រះពោធិសត្វ គិតឃើញដូច្នេះ ក៏មិនបានចូលទៅជិត ហើយបែរត្រឡប់ក្រោយរត់ចេញមកវិញ ។ តាបសកំហូច ដឹងថាសត្វទន្សងមិនព្រមមក ព្រោះដឹងខ្លួនថាយើងប្រុងសម្លាប់ ទោះជាយ៉ាងនេះក៏មិនរួចពីកណ្ដាប់ដៃអញ ហើយបានយកដំបងចេញមកគ្រវែងតម្រង់ទៅរកព្រះពោធិសត្វ ។ ដំបងបានចោលទៅប៉ះចុងកន្ទុយបន្តិចប៉ុណ្ណោះ ព្រះពោធិសត្វចូលក្នុងដំបូកដោយរហ័ស ហើយចេញក្បាលមកតាមរន្ធមួយទៀតពោលថា « វ៉ឺយ ! ជដិលកំហូច កាលដែលយើងចូលទៅរកអ្នកឯង គឺចូលទៅដោយសម្គាល់ថា ជាអ្នកមានសីលប៉ុន្តែឥឡូវនេះ ល្បិចកំហូចរបស់អ្នក យើងបានដឹងហើយ



មហាចោរដូចជាអ្នកឯងអ៊ីចឹង បួសធ្វើអ្វីទៅ » ។ កាលដែលតិះដៀលតាបសហើយ ទើបពោលនូវគាថា ដោយសេចក្ដីថា :

- « ម្នាលតាបស ឥតបញ្ញា ប្រយោជន៍អ្វីដោយជដារបស់អ្នក និងប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះគ្រឿងសាំញ៉ាំ គឺកិលេស មាននៅខាងក្នុងខ្លួនអ្នក អ្នកខំដុសខាត់តែខាងក្រៅទេ » ។

បណ្ដាបទទាំងនេះ បទថា **កិន្តេ ជដាហិ ទុម្មេធ** ដោយសេចក្ដីថា នែវ៉ឺយ ជដិលដ៏ល្ងង់ខ្លៅ ប្រាសចាកការចេះដឹង ការបួងសក់នេះ ចំពោះបុគ្គលដែលវៀរចាកនូវការបៀតបៀន ទើបគួរ ចំណែកអ្នកប្រាសចាកនូវគុណនេះ នឹងទ្រទ្រង់ទុកនូវជដាធ្វើអ្វី ។

បទថា **កិន្តេ អជិនសាដិយា** ដោយសេចក្ដីថា ចាប់ផ្ដើមតាំងតែអំពីអ្នកឯងដែលមិនមាននូវសំវរគុណមក អ្នកឯងមិនសមនឹងដណ្ដប់ស្បែកខ្លាទេ ប្រយោជន៍អ្វីដោយស្បែកខ្លាដែលអ្នកទ្រទ្រង់ ។

បទថា **អព្ភន្តរេ គហនំ** ដោយសេចក្ដីថា ខាងក្នុងគឺសន្ដានចិត្តរបស់អ្នក ទ្រុបទ្រុលទៅដោយកិលេសគឺ រាគៈ ទោសៈ មោហៈ ។

បទថា **ពាហិរំ បរិមជ្ជសិ** ដោយសេចក្ដីថា អ្នកឯងហ្នឹង កាលដែលខាងក្នុងមានភាពសាំញ៉ាំ ទ្រុបទ្រុលក្រាស់ចង្អៀតទៅដោយកិលេស ដូច្នេះ បែរជាមកវល់តែដុសខាត់ខាងក្រៅ ដោយការងូតទឹកជាដើម និងដោយការទ្រទ្រង់នូវភេទជាអ្នកបួស ។ កាលបើវល់តែដុសខាត់ខាងក្រៅយ៉ាងនេះ អ្នកឯងប្រៀបដូចជាសំបកឃ្លោកស្មោកគ្រោកខាងក្នុង ឬដូចជាពាងដែលពេញទៅដោយថ្នាំពិស ឬម្យ៉ាងទៀត ដូចជាដំបូកដែលពេញទៅដោយអាសិរពិស ពុំនោះសោតទេ ដូចជាផ្នូរខ្មោចដ៏វិចិត្រដែលពេញទៅដោយលាមក សឹងរលើបរលោងតែខាងក្រៅប៉ុណ្ណោះ អ្នកឯងគឺជាចោរ នឹងនៅក្នុងទីនេះធ្វើអ្វី ប្រញាប់ចេញឱ្យឆាប់ទៅ បើអ្នកឯងមិនប្រញាប់ទៅទេ យើងនឹងប្រាប់អ្នកស្រុក ឱ្យធ្វើការបណ្ដេញអ្នកឯង ។



ព្រះពោធិសត្វ គំរាមតាបសកំហូចយ៉ាងនេះហើយ ក៏ចូលទៅក្នុងដំបូកវិញ រីឯតាបសកំហូច ក៏គេចអំពីទីនោះទៅ ។

ព្រះបរមសាស្ដា ទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា តាបសកំហូចក្នុងគ្រានោះ បានមកជាភិក្ខុអ្នកបោកបញ្ឆោតគេក្នុងគ្រានេះ ឯព្រះតាបសមានសីលនោះ បានមកជាសារីបុត្ត ចំណែកគោធបណ្ឌិត (ទន្សងពោធិសត្វ) បានមកជា **តថាគត** ដូច្នេះឯង ។

**ចប់ គោធជាតក**

# ៥_ឆទ្ទន្តជាតក

បិដកលេខ ៦០ , ទំព័រ ១៧១ ព្រមដោយអដ្ឋកថា

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់គង់ប្រថាប់នៅនា ព្រះជេតពនមហាវិហារ ទ្រង់ប្រារព្ធភិក្ខុនីក្រមុំមួយអង្គ ទ្រង់ត្រាស់នូវព្រះធម៌ទេសនានេះថា :

**កឹ នុ សោចសិន្ទុច្ចន្តី** ដូច្នេះជាដើម ។

ប្រារព្ធសេចក្តីគឺថា នាងភិក្ខុនីនោះ ជាធីតារបស់ត្រកូលមួយ ក្នុងព្រះនគរសាវត្ថី ឃើញទោសក្នុងឃរាវាសវិស័យ ក៏បានចេញទៅបួសក្នុងព្រះពុទ្ធសាសនា ។ ថ្ងៃមួយភិក្ខុនីអង្គនោះ បាននិមន្តទៅដើម្បីនឹងស្តាប់ព្រះធម៌ ព្រមជាមួយនឹងពួកភិក្ខុនីដទៃ ឃើញព្រះរូបឆោម ដែលកើតឡើងដោយបុញ្ញានុភាព រកប្រមាណមិនបាន ប្រកបដោយព្រះរូបសម្បត្តិដ៏ឧត្តមរបស់ព្រះទសពល ។ ព្រះអង្គទ្រង់គង់ប្រថាប់លើធម្មាសនៈដែលប្រដាប់តាក់តែងហើយ កំពុង



សម្តែងនូវព្រះធម៌ទេសនា ។ នាងភិក្ខុនីឃើញដូច្នេះហើយទើបគិតថា កាលដែលយើងត្រាច់ទៅក្នុងវដ្តសង្សារ ធ្លាប់បានជាបាទបរិចារិកា នៃព្រះមហាបុរសនេះដែរឬទេហ្ន៎ ។ ទាន់ពេលនោះឯង នាងក៏បានរលឹកជាតិមុនឃើញថា យើងធ្លាប់បានជា បាទបរិចារិកា របស់មហាបុរសនេះ ក្នុងកាលដែលព្រះអង្គជាស្តេចដំរីឆទ្ទន្ត ។ កាលដែលនាងរលឹកបានដូច្នោះហើយ បីតិដ៏ខ្លាំងក្លាក៏បានកើតឡើង ។ ដោយកម្លាំងនៃសេចក្តីត្រេកអរ នាងជាភិក្ខុនីទើបសើចចេញមកដោយសំឡេងខ្លាំងៗ រួចហើយ ក៏បានគិតទៀតថា ដែលជាបាទបរិចារិកា មានអធ្យាស្រ័យប្រព្រឹត្តនូវប្រយោជន៍ដល់ស្វាមី មានតិចនាក់ទេ ដែលមិនបានធ្វើនូវប្រយោជន៍នោះគឺមានច្រើន តើយើងមានអធ្យាស្រ័យប្រព្រឹត្តនូវប្រយោជន៍ដល់បុរសនេះដែរ ឬក៏ទេហ្ន៎ ។ នាងរលឹកបានក្នុងពេលនោះ នាងឃើញសេចក្តីពិតថា ដោយពិត យើងសាងនូវកំហុសទុកក្នុងហឫទ័យមិនតិចឡើយ គឺយើងបានប្រើនាយព្រានសោណុត្តរ ឱ្យយកព្រួញលាបទៅ

ដោយថ្នាំពិសបាញ់ស្តេចដំរីឆទ្ទន្ត ដែលមានកម្ពស់ប្រមាណ ១២០ ហត្ថ [១] ឱ្យដល់នូវសេចក្តីស្លាប់ ។ ទាន់ពេលនោះដែរ សេចក្តីសោកសៅក៏កើតឡើងដល់នាង ដួងហឫទ័យក៏ក្តៅក្រហាយ នាងមិនអាចអត់ទ្រាំនូវសេចក្តីសោកសៅនោះបាន ទើបស្រែកទ្រហោយំដោយសំឡេងខ្លាំង ៗ ។

ព្រះបរមសាស្តា ទ្រង់ទតព្រះនេត្រឃើញដូច្នោះ ក៏ទ្រង់ព្រះញញឹមឱ្យប្រាកដ ធ្វើឱ្យភិក្ខុសង្ឃទូលសួរថា : បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាហេតុ ជាបច្ច័យ ញុំាងឱ្យព្រះអង្គទ្រង់ព្រះញញឹម ? ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា : ម្នាលភិក្ខុទាំងឡាយ នាងភិក្ខុនីក្រមុំរូបនេះ រលឹកដល់កំហុសដែលធ្លាប់ធ្វើមកលើតថាគតក្នុងជាតិមុន ទើបបានជាស្រែកទ្រហោយំ ។ ជាបន្តទៅព្រះអង្គទ្រង់នាំអតីតនិទានមកសម្តែង ។

ក្នុងអតីតកាល មានដំរីប្រមាណ ៨០០០ (ប្រាំបីពាន់ដំរី) មានឫទ្ធិហោះទៅក្នុងអាកាសបាន អាស្រ័យនៅ

១-កាលដែលទើបនឹងពេញវ័យ ដំរីឆទ្ទន្តមានកម្ពស់ ៨៨ ហត្ថ ។



នឹងស្រះឆទ្ទន្ត នាដែនដីនៃព្រៃហិមពាន្ត ។ គ្រានោះ ព្រះពោធិសត្វ កើតជាកូននៃដំរីដែលជាមេហ្វូង មានសម្បុរកាយ គឺដងខ្លួនពណ៌សសុទ្ធ ឯមាត់និងជើងពណ៌ក្រហម ។ ក្រោយមក ព្រះពោធិសត្វបានចម្រើនវ័យឡើង កម្ពស់បាន ៨៨ ហត្ថ ពីមុខទៅក្រោយប្រវែង ១២០ ហត្ថ ប្រកបដោយប្រមោយដ៏ល្អល្អះ ប្រវែង ៥៨ ហត្ថ ចំណែកភ្លុកទាំងពីរវាស់ដោយជុំវិញបាន ១៥ ហត្ថ ប្រវែងពីគល់មកចុង ៣០ ហត្ថ ប្រកបដោយរស្មី ៦ ពណ៌ ។ ព្រះពោធិសត្វជាប្រមុខនៃដំរី ដែលមានហ្វូងដំរី ៨០០០ ជាបរិវារ បូជាព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ អគ្គមហេសីរបស់ព្រះពោធិសត្វនោះ មានពីរ គឺចុល្លសុភទ្ទា ១ និងមហាសុភទ្ទា ១ ។ ស្តេចដំរីព្រមទាំងបរិវារ អាស្រ័យនៅនឹងកាញ្ចនគុហា នាភ្នំដ៏ខ្ពស់ ។ ម្យ៉ាងទៀត ស្រះឆទ្ទន្តនោះ ទាំងចំណែកបណ្តោយ និងចំណែកទទឹង មានប្រវែងប្រមាណ ៥២ យោជន៍ ត្រង់កណ្តាលជម្រៅប្រមាណ ១២ យោជន៍ មិនមានសារាយ មិនមានចក ឫក៏ព្រាំឡើយ ។ ស្រះឆទ្ទន្តមាន

ទឹកថ្លាដូចដុំកែវមណី បន្ទាប់ពីកណ្ដាលស្រះឡើងមក មានចង្កុលណីដុះព័ទ្ធជុំវិញទឹក ទទឹងមួយយោជន៍ បន្ទាប់មកទៀត ឧប្បលខៀវដុះព័ទ្ធជុំវិញចង្កុលណី ទទឹងក៏មួយយោជន៍ បន្តមកមានទទឹងមួយយោជន៍ៗ ដូចគ្នា គឺឧប្បលក្រហម ឧប្បលស បទុមក្រហម បទុមស និងកុមុទ ដុះឡើងមកព័ទ្ធជុំវិញគ្នាជាបន្តបន្ទាប់ ។ ពីខាងក្រៅនៃពូកឈូកទាំង ៧ ប្រភេទ មានឈូកគ្រប់មុខលាយចម្រុះគ្នា មានចង្កុលណីជាដើម ព័ទ្ធជុំវិញ ដែលមានកម្រាស់មួយយោជន៍ដូចគ្នាដែរ ។ បន្តចេញមកដល់ទឹកដែលមានជម្រៅរាក់ល្មមត្រឹមផ្ចិតដំរី [១] មានពូកស្រូវសាលីក្រហមដុះឡើងមក ទទឹងកម្រាស់មួយយោជន៍ដូចគ្នាទៀត ។ បន្តមកទៀតដល់មាត់ទឹក គឺមួយយោជន៍ដូចគ្នា មានពូកវៃទឹកសន្ធឹកទៅដោយផ្កាពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម និងពណ៌ស ដែលមានក្លិនក្រអូបផ្សាយទៅ ។ ឡើងពីមាត់ទឹកមកលើគោក មានឪឡឹក ឃ្លោក ល្ពៅ ត្រឡាច ។ បន្ត

១_ដំរីបច្ចុប្បន្ន ។



មកទៀតមានព្រៃអំពៅ ដើមប៉ុនៗដើមស្លា រួចហើយព្រៃចេក ផ្លែធំៗប៉ុនភ្លុកដំរី[១] ព្រៃខ្នុរណាំង ផ្លែប៉ុនៗពាងទឹក ។ មានព្រៃខ្នុរសម្ងដែលផ្លែមានរសឆ្ងាញ់ តមកមានព្រៃខ្វិត ព្រៃរាំង រហូតដល់ព្រៃសណ្ឋះដែលមានដើមឈើធំៗលាយចម្រុះគ្នា បន្ទាប់មកទៀតព្រៃឫស្សី នេះជាភាពសម្បូណ៌សម្បើម នៃស្រះឆទ្ទន្តក្នុងសម័យនោះ ។ នៅក្នុងអដ្ឋកថាសំយុត្តនិកាយ លោកក៏បានពណ៌នា នូវភាពសម្បូណ៌សម្បើមនេះ ដូចគ្នាដែរ ដែលមានក្នុងបច្ចុប្បន្ន [២] ។

ម្យ៉ាងទៀត មានភ្នំព័ទ្ធជុំវិញព្រៃឫស្សីដល់ទៅ ៧ ជាន់ បើរាប់ពីខាងក្រៅមក ភ្នំទី ១ ឈ្មោះចុល្លកាឡបព៌ត ភ្នំទី ២ ឈ្មោះមហាកាឡបព៌ត ភ្នំទី ៣ ឈ្មោះឧទកបស្សបព៌ត ភ្នំទី ៤ ឈ្មោះចន្ទបស្សបព៌ត ភ្នំទី ៥ ឈ្មោះសុរិយបស្សបព៌ត ភ្នំទី ៦ ឈ្មោះមណីបស្សបព៌ត និងភ្នំទី ៧ ឈ្មោះសុវណ្ណបស្សបព៌ត ។

១_ដំរីបច្ចុប្បន្ន ។ ២_បច្ចុប្បន្នសម័យអដ្ឋកថា ។ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ លោកនិមន្តទៅគង់នៅទីនោះអស់ ១២ ឆ្នាំ ហើយបរិនិព្វានក្នុងទីនោះ ។

សុវណ្ណបស្សបពីត មានកម្ពស់ដល់ទៅ ៧ យោជន៍[១] ព័ទ្ធជុំវិញស្រះឆទ្ទន្ត ដូចជាកណ្ដាប់មាត់បាត្រ នៅខាងក្នុងសុវណ្ណបស្សបពីតនោះ មានពណ៌ដូចមាស ហើយព្រោះតែពន្លឺចេញអំពីសុវណ្ណបស្សបពីត បានធ្វើឱ្យស្រះឆទ្ទន្តនោះឯង ភ្លឺហាក់បីដូចជាពន្លឺព្រះអាទិត្យដ៏ស្រទន់ ដែលទើបតែឧទ័យ ។ ភ្នំដែលមានជាបន្តបន្ទាប់រាប់ពីក្នុងចេញទៅក្រៅវិញ គឺភ្នំទី ៦ កម្ពស់ ៦ យោជន៍ , ទី ៥ កម្ពស់ ៥ យោជន៍ , ទី ៤ កម្ពស់ ៤ យោជន៍ , ទី ៣ កម្ពស់ ៣ យោជន៍ , ទី ២ កម្ពស់ ២ យោជន៍ និងទី ១ កម្ពស់ ១ យោជន៍ ។

នៅនឹងជ្រុងទិសឦសាននៃស្រះឆទ្ទន្ត ដែលមានភ្នំ ៧ ជាន់ព័ទ្ធជុំវិញយ៉ាងនេះ មានដើមជ្រៃធំ តាំងនៅក្នុងឱកាសដែលទឹកនិងខ្យល់ប៉ះត្រូវបាន ។ ដើមជ្រៃនោះវាស់ដោយជុំវិញបាន ៥ យោជន៍ កម្ពស់ដើម ៧ យោជន៍ មានមែកវែងបាន ៦ យោជន៍ លូតចេញទៅក្នុងទិសទាំង៤

១-មិនមែនមួយយោជន៍សុទ្ធតែ ១៦ គីឡូម៉ែត្រនោះទេ ។



សូម្បីមែកដែលដុះទៅលើ ក៏ប្រវែង ៦ យោជន៍ដូចគ្នាដែរ ដូច្នេះ បើវាស់ពីគល់ទៅដល់ចុងកំពូល មានកម្ពស់ ១៣ យោជន៍ ពីចុងមែកម្ខាងទៅចុងមែកម្ខាងទៀតប្រវែង ១២ យោជន៍ ប្រដាប់ដោយពូរជ្រៃ ៨០០០ ជាដើមឈើខ្ពស់ត្រដែត ស្រស់ស្អាត បីដូចជាភ្នំកែវមណី ។

នៅឯទិសបស្ចិមនៃស្រះឆទ្ទន្ត នាភ្នំសុវណ្ណបស្សបពីត មានកាញ្ចនគុហា[១] ដ៏ធំ ប្រមាណ ១២ យោជន៍ ។ ដល់រដូវភ្លៀង ស្ដេចដំរីឆទ្ទន្ត មានដំរី ៨០០០ ជាបរិវារ បានអាស្រ័យនៅនឹងកាញ្ចនគុហានោះឯង ។ ក្នុងរដូវក្ដៅ ក៏មកឈរទទួលខ្យល់និងទឹកនៅរវាងពូរជ្រៃ ក្រោមមហានិគ្រោធព្រឹក្ស[២] ។

ក្រោយមកថ្ងៃមួយ ដំរីទាំងឡាយមកប្រាប់ថា ព្រៃរាំងដ៏ធំនោះ មានផ្ការីកហើយ ។ ស្ដេចដំរីឆទ្ទន្តគិតថា យើងនឹងលេងកីឡាផ្ការាំង ។ លុះគិតដូច្នេះហើយព្រមទាំង

១-គុហាមាស ។ កាញ្ចនៈនិងកញ្ចនៈ ហៅបានដូចគ្នា ។

២-ដើមជ្រៃធំដែលមានកម្ពស់ ១៣ យោជន៍នោះឯង ។

បរិវារក៏ទៅកាន់ព្រៃរាំងនោះ យកក្បាលជល់ដើមរាំងមួយដើមដែលមានផ្កាវីកស្គុសស្គាយ ។ នាងចុល្លសុភទ្ទា ឈរនៅខាងលើខ្យល់ ស្លឹករាំងចាស់ៗ ជាប់ជាមួយនឹងមែកងាប់ៗ ព្រមទាំងស្រមោចផង អង្គ្រងផង បានធ្លាក់ត្រូវសរីរៈរបស់នាង ។ រីឯនាងមហាសុភទ្ទា ឈរនៅខាងក្រោមខ្យល់ លម្អងកេសរ និងស្លឹកស្រស់ៗ បានធ្លាក់មករោយត្រូវចំសរីរៈរបស់នាង ។ នាងចុល្លសុភទ្ទា គិតថា ស្តេចដំរីនេះ រោយកេសរនិងស្លឹកស្រស់ៗ ឱ្យត្រូវលើសរីរៈភរិយាដែលខ្លួនស្រឡាញ់ប្រោសប្រាណ ចំណែកខ្លួនប្រាណរបស់យើងឯណេះវិញ ឱ្យស្លឹកចាស់ៗជាប់នឹងមែកងាប់ៗ ទាំងអង្គ្រង ទាំងស្រមោច ធ្លាក់មកត្រូវ យើងនឹងតបស្នងឱ្យបានស័ក្តិសម គិតដូច្នេះហើយ ក៏បានចងពៀរនឹងព្រះមហាសត្វ ។

ក្រោយមក ថ្ងៃមួយ ស្តេចដំរីព្រមដោយបរិវារបានចុះកាន់ស្រះឆទ្ទន្ត ដើម្បីងូតទឹក ។ ខណៈនោះ មានដំរី ២ នៅក្មេងៗ យកប្រមោយចាប់កាន់ស្មៅម្យ៉ាងមក



ដុសកាយស្តេចដំរី បីដូចចំអើតបោសកំពូលភ្នំកៃលាសដូច្នោះឯង ។ កាលស្តេចដំរីងូតទឹកឡើងមកហើយ ទើបឱ្យនាងដំរីទាំងពីរចុះងូត ដល់នាងទាំងពីរឡើងមក នាំគ្នាទៅឈរក្បែរព្រះមហាសត្វ ទើបដំរីទាំង ៨០០០ ចុះស្រះលេងកីឡាក្នុងទឹក ហើយនាំយកផ្កាជលជាតផ្សេងៗអំពីស្រះ មកប្រដាប់តាក់តែងដល់ព្រះមហាសត្វ ដូចជាប្រដាប់តាក់តែងនូវស្តូបប្រាក់ ដូច្នោះដែរ ស្រេចហើយទើបប្រដាប់តាក់តែងឱ្យនាងទាំងពីរតាមក្រោយ ។ ពេលនោះ មានដំរីមួយ ត្រាច់ទៅក្នុងស្រះ បានផ្កាឈូកដ៏ធំមួយមានត្របក ៧ ស្រទាប់ ទើបនាំមកឱ្យព្រះមហាសត្វ ។ ស្តេចដំរីយកប្រមោយទទួលមហាបទុម មករោយកេសរដាក់លើសីសៈរបស់ខ្លួន ហើយហុចឱ្យដល់នាងមហា-សុភទ្ទាដែលជាជេដ្ឋភរិយា ។ នាងចុល្លសុភទ្ទាឃើញដូច្នោះក៏អន់ចិត្ត ហើយគិតថា ស្តេចដំរីនេះឱ្យមហាបទុម ដែលមានត្របក ៧ ស្រទាប់ ដល់ភរិយាដែលជាទីស្រឡាញ់ពេញចិត្ត និងជាទីប្រោសប្រាណតែមួយ ចំណែកយើង

មិនបានឱ្យឡើយ ហើយទើបចងពៀរចំពោះព្រះមហាសត្វបន្ថែមទៀត ។

ថ្ងៃក្រោយមក កាលដែលស្ដេចដំរីព្រះមហាសត្វចាត់ចែងរៀបចំផ្លែឈើនិងដំឡូង ព្រមទាំងមើមត្រាវដែលឆ្អិនស្រេចស្រាប់ផ្សំដោយទឹកឃ្មុំ ថ្វាយដល់ព្រះបច្ចេកពុទ្ធឆាន់ ៥០០ អង្គ ។ នាងចុល្លសុភទ្ទាបានថ្វាយផលាផលដែលជារបស់ខ្លួនដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្ដីប្រាថ្នាថា : បពិត្រ លោកម្ចាស់ដ៏ចម្រើន ខ្ញុំម្ចាស់ឃ្លាតចាកពីអត្តភាពក្នុងជាតិនេះទៅ សូមឱ្យបានកើតក្នុងត្រកូល **មទ្ទរាជ** និងបានឈ្មោះថា **សុភទ្ទារាជកញ្ញា** កាលដែលចម្រើនវ័យហើយ សូមឱ្យបានជាអគ្គមហេសី នៃព្រះចៅក្រុងពារាណសី ជាទីស្រឡាញ់ពេញចិត្ត និងជាទីប្រោស-ប្រាណរបស់ព្រះអង្គ រហូតដល់ធ្វើអ្វី ប្រាថ្នាអ្វីក៏បានតាមចិត្តចង់ និងអាចក្រាបទូលដល់ព្រះអង្គ សូមឱ្យទ្រង់ប្រើនាយព្រាន មកបាញ់ស្ដេចដំរីនេះ ដោយព្រួញលាបថ្នាំពិស រហូតដល់ស្លាប់ ព្រមទាំងនាំយកភ្លុកទាំងគូដែលមាន



រស្មី ៦ ពណ៌បានទៀតផង ។ ចាប់តាំងពីថ្ងៃនោះមក នាងចុល្លសុភទ្ទា ជាដំរីជាប់ដោយគំនុំក្នុងចិត្ត មិនបរិភោគស្មៅ ឬទោះបីអាហារអ្វីក៏ដោយ ព្រមទាំងទឹក រាងកាយស្គាំងស្គម កម្លាំងចុះខ្សោយ មិនយូរប៉ុន្មានក៏ដួលចុះ ហើយស្លាប់ទៅ កើតក្នុងព្រះគភ៌នៃព្រះអគ្គមហេសីនៃព្រះរាជាដែនមទ្ទរដ្ឋ ។ កាលដែលប្រសូតមកហើយ ពេញរូបពេញរាង ព្រះជនក ព្រះជននី ក៏បាននាំទៅថ្វាយដល់ព្រះចៅក្រុងពារាណសី ។ នាងជាទីស្រឡាញ់ប្រោសប្រាណរបស់ព្រះរាជា រហូតដល់បានទៅជាប្រមុខនៃនាងស្នំ ១៦០០០ នាក់ ព្រមទាំងបាននូវញាណជាគ្រឿងរលឹកជាតិមុនឃើញទៀតផង ។ ព្រះនាងសុភទ្ទានោះ ទ្រង់បានត្រិះរិះថា សេចក្ដីប្រាថ្នារបស់យើងសម្រេចហើយ ពេលនេះ នឹងឱ្យទៅយកភ្លុកទាំងគូរបស់ស្ដេចដំរីនោះមក ។ ចាប់តាំងពីនោះមក ព្រះនាងយកប្រេងលាបនូវព្រះសរីរៈទ្រទ្រង់នូវសំពត់សៅហ្មង បានសម្ដែងនូវព្រះអាការឈឺ ហើយស្ដេចចូលកាន់បន្ទប់សិរីសេយ្យាសន៍ ទ្រង់ផ្ទំលើ

ព្រះទែនសយនា ។ ព្រះរាជាទ្រង់ត្រាស់សួរថា : ព្រះនាងសុភទ្ទាទៅណា ? កាលដែលទ្រង់ជ្រាបថា ប្រឈួនហើយ ទើបស្តេចចូលទៅអង្គុយប្រថាប់លើព្រះទែន ទ្រង់លូកស្ទាបព្រះប្រឹស្ឋាង្គរបស់ព្រះនាង ហើយត្រាស់នូវព្រះគាថាទី ១ ថា :

**កិន្នុ សោចសិនុច្ចង្គី បណ្ឌុសី វរវណ្ណិនី**
**មិលាយសិ វិសាលក្ខី មាលាវ បរិមទ្ទិតា ។**

ម្នាលនាងសុភទ្ទាគួរនាចរណៃ ខ្លួនប្រាណជើងដៃបីដូចជាមាស
សម្បុរលឿងខ្ចីស្រីវរោភាស នេត្រាល្អល្អះវិសេសវិសាល ។
តើនាងកើតអ្វីទើបស្រីសោកា ភក្ត្រាស្រពោនទុក្ខអួនពុំស្រាល
បីដូចបទុមគេខ្វាំហើយហាល អម្បាលមាលាក្នុងគ្រាស្រពាប់ ។

បណ្តាបទទាំងនេះ បទថា **អនុច្ចង្គី** ដោយសេចក្តីថា នាងមានព្រះសីរៈភ្លឺថ្លាស្រស់ស្អាតបីដូចមាស ។

បទថា **មាលាវ បរិមទ្ទិតា** ដោយសេចក្តីថា បីដូចបទុមត្រូវខ្វាំប្រចាច់ ដូច្នោះឯង ។



ព្រះនាងសុភទ្ទាទ្រង់ស្តាប់ហើយ ទើបត្រាស់នូវគាថាឆ្លើយតបដូច្នេះថា :

**ទោហឡោ មេ មហារាជ សុបិនន្តេនុបច្ចគា**
**ន សោ សុលភរូបោវ យាទិសោ មម ទោហឡោ។**

បពិត្រមហារាជអំណាចបវរ ខ្ញុំម្ចាស់ចាញ់គភិព្រោះតែយល់សប្តិ
ចំណង់ចម្លែកក្រែងប្លែកអភ័ព្វ មិនអាចបានទ្រព្យប្រសព្វទុក្ខព្រួយ ។

បណ្តាបទទាំងនោះ បទថា **ន សោ** ដោយសេចក្តីថា ការចាញ់ព្រះគភ៌ដែលខ្ញុំម្ចាស់យល់សប្តិឃើញយ៉ាង-ណានោះ ។

បទថា **សុបិនន្តេនុបច្ចគា** ដោយសេចក្តីថា ខ្ញុំម្ចាស់សុបិននិមិត្ត ក្នុងទីបំផុតនៃសុបិន ទើបចាញ់ព្រះគភ៌ របស់ដែលចាញ់ព្រះគភ៌ព្រោះការយល់សប្តិនោះ ហាក់ដូចជាមិនងាយរកបានឡើយ ប៉ុន្តែបើខ្ញុំម្ចាស់មិនបាននូវរបស់នោះទេ ខ្ញុំម្ចាស់មុខតែមិនមានជីវិតរស់នៅឡើយ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នោះហើយទើបត្រាស់ព្រះគាថា :

**យេកេចិ មានុសា កាមា ឥធ លោកស្មិ នន្ទនេ**

**សព្វេ តេ បចុរា មយ្ហំ អហន្តេ ទម្មិ ទោហឡំ ។**

កាមគុណទាំងអស់ជារបស់មនុស្សា ក្នុងលោកនេះរ៉ាងណានីមួយ
សុទ្ធតែរបស់យើងម្ចាស់អូនកុំព្រួយ រៀមបងនឹងជួយតាមចិត្តអូនចង់។

បណ្តាបទទាំងនោះ បទថា **បចុរា** ដោយសេចក្តីថា ម្នាលនាងសុភទ្ទាដ៏ចម្រើន កាមសម្បត្តិដែលជារបស់មនុស្ស ដែលពួកមនុស្សប្រាថ្នានៅក្នុងលោកនេះ និងរតនៈ ៧ ប្រការឯណានីមួយ នៅក្នុងនន្ទវ័ន មានច្រើនណាស់ រកបានដោយងាយ គឺកាមគុណ ៥ ឯណានីមួយ មានក្នុងមនុស្សលោក យើងនឹងឱ្យវត្ថុកាម និងកិលេសកាមទាំងអស់នោះដល់នាង ។

ព្រះទេវីបានស្តាប់ ដូច្នោះហើយ ទើបពោលថា បពិត្រព្រះសម្មតិទេព ការចាញ់គភ៌របស់ខ្ញុំម្ចាស់ រក្សាបានដោយលំបាក ខ្ញុំម្ចាស់មិនក្រាបទូលឱ្យទ្រង់ជ្រាបក្នុងពេលនេះទេ ។ នៅក្នុងដែនរបស់ព្រះអង្គ មានព្រានព្រៃចំនួនប៉ុនណា សូមទ្រង់ព្រះមេត្តាប្រោសឱ្យមកប្រជុំគ្នាទាំងអស់



ខ្ញុំម្ចាស់នឹងទូលឱ្យទ្រង់ជ្រាប ក្នុងកណ្តាលព្រានព្រៃទាំង-នោះ រួចហើយព្រះនាងក៏ត្រាស់នូវគាថា ក្នុងលំដាប់តទៅ :

**លុទ្ធា ទេវ សមាយន្តុ យេ កេចិ វិជិតេ តវ**

**ឯតេសំ អហមក្ខិស្សំ យានិសោ មម ទោហឡោ។**

បពិត្រព្រះអង្គសូមទ្រង់ឱ្យព្រាន ដែលមានប៉ុន្មានក្នុងដែនដីទ្រង់
មកប្រជុំគ្នាកុំបីរារង់ នឹងប្រាប់ចំណង់ដល់ពួកព្រានព្រៃ។

ក្នុងគាថានោះ មានសេចក្តីអធិប្បាយថា បពិត្រព្រះសម្មតិទេព ក្នុងដែនរបស់ព្រះអង្គ មាននាយព្រានជំពូកណា ដែលជាព្រានសមគួរ នាយព្រានគ្រប់ជំពូកនោះចូរមកប្រជុំគ្នា គឺប្រកាសហៅគ្នាមក ខ្ញុំម្ចាស់នឹងប្រាប់អំពីការចាញ់គភ៌របស់ខ្ញុំម្ចាស់ ដែលមានសភាពយ៉ាងណានោះដល់នាយព្រានទាំងនោះ ។

ព្រះចៅក្រុងពារាណសី ទទួលពាក្យរបស់ព្រះ-មហេសីហើយ ស្តេចចេញអំពីបន្ទប់សិរីសេយ្យាសន៍ ត្រាស់បង្គាប់ដល់ពួកអាមាត្យថា : នាយព្រានព្រៃចំនួន

ប៉ុន្មាន មាននៅក្នុងកាសិករដ្ឋ ដែលមានអាណាខេត្ត ៣០០ យោជន៍ ចូរអ្នកទូងស្គរប្រកាស ឱ្យព្រានព្រៃទាំងអស់នោះមកប្រជុំគ្នា ។ អាមាត្យទាំងនោះ ក៏ធ្វើតាមព្រះរាជឱង្ការ។ មិនយូរប៉ុន្មាន ពួកព្រានព្រៃក្នុងកាសិករដ្ឋ ក៏បាននាំគ្នាយកគ្រឿងបណ្ណាការតាមលទ្ធភាព ចូលមកគាល់ព្រះរាជាហើយ ឱ្យក្រាបទូលការដែលពួកខ្លួនបានមកដល់ ឱ្យទ្រង់ជ្រាបថា ព្រានព្រៃទាំងអស់ ប្រមាណ ៦០.០០០ នាក់ បានមកប្រជុំគ្នាហើយ ។ ព្រះរាជាទ្រង់ជ្រាបថា ពួកនាយព្រានមកហើយ ទើបទ្រង់ប្រថាប់ឈរឯព្រះបញ្ជរ ហើយចង្អុលប្រាប់ដល់ព្រះទេវីត្រាស់នូវគាថា :

**ឥមេ តេ លុទ្ទកា ទេវិ   កតហត្ថា វិសារទា**
**វនញ្ញូ ច មិគញ្ញូ ច   មមត្ថេ ចត្តជីវិតា ។**

សូមមហេសីអូនទតព្រះនេត្រា   ពួកព្រាននេះណាសុទ្ធមានថ្វីដៃ
ជាអ្នកក្លៀវក្លាស្គាល់ម្រឹគស្គាល់ព្រៃ ដើម្បីក្សត្រថ្លៃស៊ូក្ស័យនឹងជួយ ។

បណ្តាបទទាំងនោះ បទថា **ឥមេ** ដោយសេចក្តីថា ម្នាលនាងទេវី នាងឱ្យពួកព្រានឯណាមកប្រជុំគ្នា នាយ



ព្រានទាំងនោះ គឺពួកនេះឯង ។

បទថា **កតហត្ថា** ដោយសេចក្តីថា សុទ្ធតែមានថ្វីដៃ គឺឆ្លាត បានទទួលការសិក្សារហូតដល់មានជំនាញក្នុងក្បួនបាញ់ និងក្បួនចាប់ជាដើម ។

បទថា **វិសារទា** ដោយសេចក្តីថា ជាអ្នករួចផុតអំពីភ័យ ។

បទថា **វនញ្ញូ ច មិគញ្ញូ ច** ដោយសេចក្តីថា ជំនាញក្នុងការដើរព្រៃ និងដឹងអំពីពួកសត្វ ។

បទថា **មមត្ថេ** ដោយសេចក្តីថា ពួកនាយព្រានទាំងអស់នេះ ព្រមលះបង់ជីវិត ក្នុងប្រយោជន៍របស់យើងបាន គឺគេធ្វើតាមដែលយើងប្រាថ្នា ។

ព្រះទេវី បានស្តាប់ដូច្នោះហើយ ទើបពោលនូវគាថា :

**លុទ្ទបុត្តា និសាមេថ   យាវន្តេត្ថ សមាគតា**
**ឆព្វិសាណំ គជំ សេតំ   អទ្ទសំ សុបិនេ អហំ**
**តស្ស ទន្តេហិ មេ អត្ថោ អលាភេ នត្ថិ ជីវិតំ ។**

លុទ្ទបុត្រទាំងអស់ដែលកោះប្រជុំ ចូរស្តាប់ពាក្យខ្ញុំរៀបរាប់ទុក្ខព្រួយ
ខ្ញុំសុបិនឃើញដំរីសមួយ ចិត្តញ៉ាំរញ្ជួយព្រោះចង់បានភ្លុក ។
ព្រោះភ្លុកទាំងគូចែងចាំងរស្មី ឆព្វណ្ណរង្សីហាត្ថីប្រមុខ
ភ្ញាក់ឡើងកាលណាចិន្តាកើតទុក្ខ បើមិនបានភ្លុកខ្ញុំមុខជាក្ស័យ ។

គប្បីជ្រាបដោយការវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះ : ព្រះនាងទេវីត្រាស់ថា អ្នកទាំងឡាយដែលជាផៅពង្សនៃព្រានព្រៃ បានមកព្រមគ្នាក្នុងទីនេះ ចូរតាំងចិត្តស្តាប់ពាក្យរបស់យើង ។

បទថា **ឆព្វិសាណំ** បានដល់ ដំរីស ដែលភ្លុកមានរស្មី ៦ ប្រការ ។ យើងយល់សប្តិឃើញដំរីសមានរស្មីនៃភ្លុក ៦ ពណ៌ ។ កាលដែលយើងឃើញគជសារមានសភាពបែបនេះ ទើបមានសេចក្តីត្រូវការនូវភ្លុកទាំងពីររបស់ដំរីនោះ កាលបើមិនបានទេ ជីវិតយើងនេះក៏នឹងមិនមានដែរ ។

ពួកបុត្រព្រានព្រៃ បានស្តាប់នូវព្រះសវនីយ៍ដូច្នោះហើយ ក៏បាននាំគ្នាក្រាបទូលថា :



**ន នោ បិតូនំ ន បិតាមហានំ**
**ទិដ្ឋោ សុតោ កុញ្ជរោ ឆព្វិសាណោ**
**យមទ្ទស សុបិនេ រាជបុត្តី**
**អក្ខាហិ នោ យាទិសោ ហត្ថិនាគោ ។**

បិតានិងជីតា នៃខ្ញុំរ៉ាមិនដែលដឹង
គជសារអស្ចារ្យម្លឹង មិនដែលដឹងឃើញឮឡើយ ។
ភ្លុកភ្លឺឆរង្សី រាជបុត្រីកុំកន្តើយ
សុបិនយ៉ាងណាហើយ ទ្រង់ត្រាស់ឆ្លើយឱ្យដឹងសព្វ ។

បណ្តាបទទាំងនោះ មានសេចក្តីអធិប្បាយអំពីពាក្យរបស់ពួកនាយព្រានថា បពិត្រព្រះនាងម្ចាស់ ស្វេតកុញ្ជរ ភ្លុកមានរស្មី ៦ ពណ៌ លក្ខណៈដូចនេះ បិតា ឬជីតារបស់ពួកទូលព្រះបង្គំ មិនធ្លាប់ឃើញ មិនធ្លាប់ឮឡើយ មិនចាំបាច់ពោលថ្វី ដល់ពួកទូលព្រះបង្គំទេ ។ ព្រោះហេតុនោះ ដែលព្រះនាងម្ចាស់ ទ្រង់និមិត្តឃើញស្តេចដំរីមានលក្ខណៈយ៉ាងណា សូមទ្រង់ត្រាស់ប្រាប់នូវអាការលក្ខណៈយ៉ាងនោះ ដល់ពួកទូលព្រះបង្គំជាខ្ញុំ មកចុះ ។

ពួកបុត្រព្រានព្រៃ បានពោលនូវគាថាបន្ត :

**ទិសា ចតស្សោ វិទិសា ចតស្សោ**
**ឧទ្ធំ អធោ ទស ទិសា ឥមាយោ**
**កតមំ ទិសំ តិដ្ឋតិ នាគរាជា**
**យមទ្ទស សុបិនេ ឆព្វិសាណំ ។**

ទិសតូចនិងទិសធំ លើក្រោមជុំជាទិសដប់
ទ្រង់ត្រាស់ពីយល់សប្តិ សូមរៀបរាប់សព្វសេចក្តី ។
ឋានស្តេចដំរីសារ ភ្លុកអស្ចារ្យឆរង្សី
ទីនោះតើឈ្មោះអ្វី ឋានដំរីនៅទិសណា ។

បណ្តាបទទាំងនោះ បទថា **ទិសា** បានដល់ក្នុងទិសទាំងឡាយ ។

បទថា **កតមំ** ដោយសេចក្តីថា ក្នុងបណ្តាទិសទាំងឡាយនោះ ស្តេចដំរីនៅទិសណា ព្រះនាងម្ចាស់ ។

កាលដែលពួកនាយព្រាន ទូលសួរយ៉ាងនេះហើយ ព្រះនាងសុភទ្ទារាជទេវី ទើបទ្រង់ពិនិត្យមើលព្រានព្រៃទាំងអស់ក្នុងចំនួននោះ ទ្រង់ឃើញព្រានព្រៃម្នាក់ ឈ្មោះ



**សោណុត្តរ** ដែលធ្លាប់ចងពៀរនិងព្រះមហាសត្វ ប្រាកដថាជាព្រានខ្លាំងពូកែជាងពួកព្រានដទៃ រូបរាងសណ្ឋានឃើញអាក្រក់ប្រាកដច្បាស់ គឺបាតជើងកំប៉ាង ស្មងកំពីកកំពកជង្គង់ធំ ឆ្អឹងជំនីរប៉ោង ពុកមាត់ក្រាស់ ពុកចង្កាក្រហមភ្នែកលឿង ដូច្នេះជាដើម ។ ទ្រង់ទតឃើញយ៉ាងនេះហើយ ទើបព្រះតម្រិះថា បុគ្គលនេះ ទើបអាចធ្វើតាមពាក្យរបស់យើងបាន ហើយក៏ក្រាបទូលសូមព្រះបរម-រាជានុញ្ញាត ឱ្យនាំព្រានសោណុត្តរឡើងទៅខាងលើប្រា-សាទជាន់ទី ៧ ទ្រង់បើកសីហបញ្ជរខាងទិសឧត្តរ ហើយលើកព្រះហស្តចង្អុលត្រង់ទៅកាន់ព្រៃហិមពាន្ត នៅខាងឧត្តរទិស រួចត្រាស់ ៤ គាថាប្រាប់ដល់ព្រាន :

**ឥតោ ឧជុំ ឧត្តរាយំ ទិសាយំ**
**អតិក្កម្ម សោ សត្ត គិរី ព្រហន្តេ**
**សុវណ្ណបស្សោ នាម គិរី ឧឡារោ**
**សំបុប្ផិតោ កឹបុរិសានុចិណ្ណោ ។**

អ្នកចេញអំពីទីតាំងនេះទៅ ត្រូវដើរសំដៅទៅទិសឧត្តរ
ឆ្លងភ្នំធំៗឡើងខ្ពស់តៗ ខ្ពស់ក្រៃបវរភ្នំទីប្រាំពីរ ។
ភ្នំនោះមានឈ្មោះសុវណ្ណបស្សៈ អ្នកឃើញប្រចក្សបុប្ផាគីរី
ព្រមទាំងកិន្នរអ្ហូអរមូលមីរ សុវណ្ណគីរីសព្វសត្វទ្រហឹង ។

**អារុយ្ហ សេលំ ភវនំ កិន្នរានំ**
**ឱលោកយ បព្វតបាទមូលំ**
**អថ ទក្ខសិ មេឃសមានវណ្ណំ**
**និគ្រោធរាជំ អដ្ឋសហស្ស បានំ ។**

អ្នកចូរឡើងភ្នំជំរំកិន្នរ រួចហើយឱនកនេត្រាសម្លឹង
មើលចុះមកក្រោមដល់ជើងភ្នំហ្នឹង គ្រានោះអ្នកដឹងហេតុការណ៍ប្រាកដ ។
គឺអ្នកបានឃើញស្ដេចជ្រៃមួយដើម មានពួរសម្បើមប្រាំបីពាន់គត់
និគ្រោធរាជាមានពណ៌ប្រាកដ បាលីកំណត់មេឃវណ្ណោ ។

**តត្ថច្ឆតិ កុញ្ជរោ ឆព្វិសាណោ**
**សព្វសេតោ ទុប្បសហោ បរេភិ**
**រក្ខន្តិ នំ អដ្ឋសហស្សនាគា**
**ឦសាទន្តា វាតជវប្បហារិនោ ។**



ស្ដេចដំរីសភ្លុកឆរង្សី នៅក្រោមដើមជ្រៃជោគជ័យពេញពោរ
គ្មានអ្វីផ្ទាញ់បានសន្ដានទន់ទោរ ស្ដេចកុញ្ជរោបរិវារញីឈ្មោល ។
ដំរីរក្សាមានប្រាំបីពាន់ អង្គរក្សឆទ្ទន្តភ្លុកដូចចន្ទោល
សន្ទុះដូចខ្យល់ប្រហារខ្លាំងចោល មិនងាយនឹងចូលដល់សត្វជាម្ចាស់ ។

**តិដ្ឋន្តិ តេ តុម្ពលមស្សសន្តា**
**កុប្បន្តិ វាតស្សបិ ឯរិតស្ស**
**មនុស្សភូតំ បន តត្ថ ទិស្វា**
**ភស្មំ ករេយ្យុំ នាស្ស រជោបិ តស្ស ។**

បរិវារទាំងនោះស្រែកស្រុះគួរស្លុត ក្រេវក្រោធបំផុតសូម្បីខ្យល់ប៉ះ
ឈរអែបឯកអង្គដង្ហើមខ្លាំងណាស់ សូរខ្យល់ឮច្បាស់កក្រើកធរណី ។
បើបានឃើញមនុស្សក្នុងទីនោះឯង គ្មានខ្លាចរអែងចាប់បោកជាន់ឈ្លី
ធ្វើឱ្យជាផេះជាផង់ធូលី បាត់បង់ជីវីខ្ទេចខ្ទីសូន្យល្អង ។

បទថា **ឥតោ** ដោយសេចក្ដីថា ម្នាលព្រានព្រៃដ៏ចម្រើន អ្នកចេញអំពីទីនេះទៅហើយ ។

បទថា **ឧត្តរាយំ** ដោយសេចក្ដីថា អ្នកចូរទៅត្រង់ទិសឧត្តរ ដើរឆ្លងភ្នំខ្ពស់ធំ ៧ គឺកាលដែលអ្នកឆ្លងភ្នំបាន ៦

ហើយ អ្នកនឹងដល់ភ្នំឈ្មោះសុវណ្ណបស្សគីរី ជាភ្នំពោរ-ពេញដោយមាស ។

បទថា **ឧឡ្ហារោ** ដោយសេចក្តីថា ធំខ្ពស់ជាងភ្នំទាំង ៦ ដែលព័ទ្ធពីក្រៅនោះ ។

បទថា **ឱលោកយ** ដោយសេចក្តីថា អ្នកចូរឱនចុះសម្លឹងមើល ។

បទថា **តត្ថច្ឆតិ** ដោយសេចក្តីថា ក្នុងរដូវក្តៅស្តេចស្វេតកុញ្ជរនោះ ឈរទទួលទឹកនិងខ្យល់ នៅក្រោមដើមជ្រៃនោះឯង ។

បទថា **ទុប្បសហោ** ដោយសេចក្តីថា មនុស្សសត្វដទៃ ដែលនឹងមានសមត្ថភាព ចូលទៅធ្វើការគ្របសង្កត់ចាប់យកស្តេចស្វេតកុញ្ជរនោះ មិនមានឡើយ ដូច្នោះទើបឈ្មោះថា មនុស្សសត្វដទៃនឹងគ្របសង្កត់បានដោយលំបាក ។ ដល់រដូវក្តៅ ស្តេចដំរីសដែលមានសភាពបែបនេះ ឈរទទួលទឹកនិងខ្យល់ នាគល់ជ្រៃនោះ ។ ម្នាលនាយព្រាន ដំរី ៨០០០ តើដូចម្តេច ?



បទថា **ឈីសានទន្តា** ប្រែថា មានភ្លុកស្មើដោយចន្ទោលរថ ។

បទថា **វាតជវប្បហារិនោ** ដោយសេចក្តីថា ដំរីទាំងនោះ មានប្រក្រតីស្ទុះទៅប្រហារបច្ចាមិត្ត បានលឿនដូចខ្យល់បក់ ដំរីទាំង ៨០០០ ដែលមានសភាពបែបនេះគាល់រក្សាស្តេចដំរីនោះជានិច្ច ។

បទថា **តុម្ហូលំ** ដោយសេចក្តីថា ដំរីទាំងនោះឈរដកខ្យល់ដង្ហើមចេញចូល គួរឱ្យខ្លាច គឺមានសំឡេងលាន់រំពងគឹកកង ជាប់តគ្នាជាលំដាប់ទៅ ។

បទថា **ឯរិតស្ស** ដោយសេចក្តីថា ដំរីទាំងនោះរមែងក្រោធ សូម្បីតែខ្យល់ដែលមកប៉ះខ្ទប់ ដេញតាមស្នូរកក្រើកញាប់ញ័រ ។ បើឃើញមនុស្សមកក្នុងទីនោះៗហើយ គឺកាចខ្លាំងណាស់ ។

បទថា **នាស្ស** ដោយសេចក្តីថា កាលមនុស្សត្រូវខ្យល់ដង្ហើមរបស់ដំរីនោះឯងកម្ចាត់ ធ្វើឱ្យជាផេះ ជាផង់ធូលីហើយក៏នៅមិនព្រមឱ្យសូម្បីតែល្អងធូលីធ្លាក់ត្រូវស្តេច

ដំរីនោះដែរ ។

នាយព្រានសោណុត្តរ ស្តាប់នូវព្រះសវនីយ៍ហើយ ក៏ភ័យខ្លាចចំពោះសេចក្តីស្លាប់ ក្រាបទូលគាថា ដូច្នេះថា :

**ពហូ ហិ មេ រាជកុលម្ហិ សន្តិ**
**បិលន្ធនា ជាតរូបស្ស ទេវិ**
**មុត្តា មណី វេឡុរិយាមយា ច**
**កឹ កាហសិ ទន្តបិលន្ធនេន**
**មារេតុកាមា កុញ្ជរំ ឆព្វិសាណំ**
**ឧទាហុ ឃាតេស្សសិ លុទ្ទបុត្តេ ។**

បពិត្រព្រះទេវី គ្រឿងកែវមណីអលង្ការ
មាសប្រាក់កែវមុក្តា វេឡុរិយាកែវពៃទូរ្យ ។
មានក្នុងរាជត្រកូល បើប្រមូលច្រើនពហូ
ព្រះនាងនៅគិតគូរ ឱ្យតស៊ូសម្លាប់សត្វ ។
យកភ្លុកស្តេចដំរី ឆទន្តត្រូវឆ្លងកាត់
ព្រៃភ្នំច្រើនពេកក្តាត់ មិនមែនសត្វងាយប្រហារ ។
បពិត្រព្រះនាងម្ចាស់ ប្រាកដច្បាស់ជាត្រូវការ
នូវភ្លុកដំរីសារ ឬប្រាថ្នាប្រហារព្រាន ។



បណ្តាបទទាំងនោះ បទថា **បិលន្ធនា** បានដល់ គ្រឿងអាភរណៈទាំងឡាយ ។

បទថា **វេឡុរិយាមយា** បានដល់គ្រឿងកែវពៃទូរ្យ។

បទថា **ឃាតេស្សសិ** ដោយសេចក្តីថា នាយព្រាន សោណុត្តរ ទូលសួរថា : ឬថាព្រះនាងម្ចាស់មានព្រះ-បំណងនឹងឱ្យស្តេចដំរីសម្លាប់ផៅពង្សរបស់ពួកនាយព្រាន ដោយយកគ្រឿងប្រដាប់ជាលេសអាង ។

លំដាប់នោះ ព្រះនាងទេវី ត្រាស់គាថា :

**សា ឥស្សិតា ទុក្ខិតា ចស្មិ លុទ្ទ**
**ឧទ្ធញ្ច សុស្សាមិ អនុស្សរន្តី**
**ករោហិ មេ លុទ្ទក ឯតមត្ថំ**
**ទស្សាមិ តេ គាមវរានិ បញ្ច ។**

នែ ! ម្នាលនាយព្រានកុំមានកង្វា យើងមានឥស្សាទាំងការអន់ចិត្ត
នឹកឃើញរឿងដើមយើងរីងរៃពិត ទើបយើងរិះគិតតាមពៀរដែលចង។
ម្នាលនាយព្រានព្រៃចូរលៃលកចុះ ប្រសិនការនោះសមតាមបំណង
ប្រាំស្រុកយកសួយបានមួយសែនម្តង យើងនឹងតបស្នងសងគុណដល់ព្រាន។

បទថា **សា** បានដល់ **សា អហំ** ប្រែថា យើងនោះ ។

បទថា **អនុស្សរន្តី** ដោយសេចក្តីថា យើងរលឹកដល់ពៀរដែលស្តេចដំរីនោះ ធ្វើមកលើយើងក្នុងកាលមុន ហើយយើងក៏សង្រេងសង្រៃរីងរៃក្នុងចិត្ត ។

បទថា **ឧស្សាមិ តេ** ដោយសេចក្តីថា នៅពេលដែលសេចក្តីត្រូវការរបស់យើងនេះបានសម្រេច យើងនឹងលើកស្រុកសួយ ៥ តំបន់ ដែលយកប្រាក់ចំណូលបាន ១ សែន រាល់ៗឆ្នាំ ជារង្វាន់ដល់អ្នក ។

គ្រាកាលដែល ព្រះនាងទេវីត្រាស់យ៉ាងនេះហើយ ក៏បានត្រាស់លួងលោមព្រានថា : នែ សម្លាញ់ព្រានអើយ ក្នុងជាតិមុនយើងបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធ ហើយបានតាំងសេចក្តីប្រាថ្នាថា សូមឱ្យយើងជាមនុស្សអាចនឹងឱ្យអ្នកដទៃសម្លាប់ដំរីឆទ្ទន្តនេះ យកភ្លុកទាំងគូមកឱ្យបាន គឺមិនមែនជាការយល់សប្តិទេ ។ សេចក្តីប្រាថ្នារបស់យើងត្រូវតែសម្រេច អ្នកចូរទៅចុះ កុំខ្លាចឡើយ ។



នាយព្រានសោណុត្តរ ទទួលបដិបត្តិតាមព្រះ-សវនីយ៍នៃព្រះទេវីថា : ទូលព្រះបង្គំ យល់ព្រម ព្រះនាងម្ចាស់ ។ ហើយព្រានព្រៃក៏បានទូលថា : បើដូច្នោះ សូមព្រះនាងម្ចាស់ ទ្រង់ប្រោសចង្អុលទីនៅរបស់ស្តេចដំរីឆទ្ទន្តនោះ ដល់ទូលព្រះបង្គំ ឱ្យបានច្បាស់លាស់ ។ កាលដែលនឹងទូលសួរតទៅ ទើបពោលនូវគាថា :

**កត្ថច្ឆតិ កត្ថម្បេតិ ឋានំ**
**វីថិស្ស កា ន្ហានគតស្ស ហោតិ**
**កថញ្ហិ សោ ន្ហាយតិ នាគរាជា**
**កថំ វិជានេមុ គតិ គជស្ស ។**

ធម្មតានៃគជសារ　　នៅត្រង់ណាជាប្រក្រតី
ឈរដើរដេកលើដី　　ផ្លូវដំរីចុះទឹកស្រះ ។
តើងូតទឹកយ៉ាងណា　　ដំណើរការមានច្រើនណាស់
ដូចម្តេចខ្ញុំដឹងច្បាស់　　ព្រះនាងម្ចាស់សូមប្រាប់ផង ។

បណ្តាបទទាំងនោះ បទថា **កត្ថច្ឆតិ** ដោយសេចក្តីថា ស្តេចដំរីនៅទីត្រង់ណា ។

បទថា **កត្ថមុបេតិ** ដោយសេចក្ដីថា ចូលទៅក្នុងទីណា ។ អធិប្បាយថា ឈរទីណា ។

បទថា **វីថិស្ស ភា** ដោយសេចក្ដីថា ផ្លូវណា ជាផ្លូវដែលស្ដេចដំរីទៅងូតទឹក គឺស្ដេចដំរីទៅងូតទឹកផ្លូវណា។

បទថា **កថំ វិជានេមុ គតិ** ដោយសេចក្ដីថា កាលបើព្រះនាងម្ចាស់មិនបង្ហាញប្រាប់ ទូលព្រះបង្គំ នឹងដឹងអំពីទីទៅមករបស់ស្ដេចដំរីនោះបានយ៉ាងណា។ ព្រោះហេតុនោះ សូមព្រះនាងម្ចាស់មេត្តាប្រោសប្រាប់ ដល់ទូលព្រះបង្គំជាខ្ញុំផងចុះ ។

កាលព្រះនាងទេវី នឹងត្រាស់ប្រាប់នូវកន្លែង ដែលបានដឹងច្បាស់ ដោយញាណជាគ្រឿងរលឹកជាតិបាន ដល់នាយព្រានសោណុត្តរ ទើបបានពោល ២ គាថា :

**តត្ថេវ សា បោក្ខរណី អវិទូរេ**
**រម្មា សុតិត្ថា ច មហោទកា ច**
**សំបុប្ផិតា ភមរគណានុចិណ្ណា**
**ឯត្ថ ហិ សោ ន្ហាយតិ នាគរាជា។**



ជិតទីលំនៅនៃស្ដេចដំរី មានបោក្ខរណីស្អាតក្រៃកន្លង
មហោទកាទឹកថ្លាច្រើនផង ផ្កាមានលំអងរីករោយព្រោងព្រាត ។
កំពង់រាបស្មើសែនមនោរម្យ ដេរដាសដោយឃ្មុំភមរជាតិ
ឯស្ដេចដំរីតែងនៅមិនឃ្លាត ពីស្រះជលជាតស្រពកាយបវរ ។

**សីសំ នហាតោ ឧប្បលមាលធារី**
**សព្វសេតោ បុណ្ឌរីកតចន្ទី**
**អាមោទមានោ គច្ឆតិ សន្និកេតំ**
**បុរក្ខត្វា មហេសី សព្វភទ្ទំ ។**

ស្ដេចដំរីសបវរអង្គកាយ ស្បែកសសុសសាយដូចផ្កាឈូកស
ជម្រះសីសៈរីករាយត្រេកអរ ទ្រង់ផ្កាបវរឧប្បលមាលា ។
ឱ្យមេដំរីមហេសីសត្វ មាននាមបញ្ញត្តិសព្វភទ្ទា
នាំមុខទៅកាន់និគ្រោធរាជា ឬក៏គុហាលំនៅអាត្មា ។

បណ្ដាបទទាំងនោះ បទថា **តត្ថេវ** ដោយសេចក្ដីថា ក្នុងកន្លែងនៅនៃស្ដេចដំរីនោះឯង ។

បទថា **បោក្ខរណី** នេះ ព្រះនាងទេវីត្រាស់សំដៅដល់ស្រះឆទ្ទន្ត ។

បទថា **សំបុប្ផិតា** ប្រែថា មានផ្កាកុមុទ ២ បែប ផ្កាឧប្បល ៣ បែប ផ្កាបទុម ៥ បែប ចេញផ្ការីកដោយជុំវិញ ។

បទថា **ឯត្ថ ហិ សោ** ដោយសេចក្តីថា ស្តេចដំរីនោះ ចុះងូតទឹកក្នុងស្រះឆទ្ទន្តនោះឯង ។

បទថា **ឧប្បលមាលធារី** ដោយសេចក្តីថា ទ្រទ្រង់នូវមាល័យបុប្ផជាតិ ដែលកើតក្នុងទឹកនិងលើគោក មានឧប្បលជាដើម ។

បទថា **បុណ្ឌរីកតចង្គី** ដោយសេចក្តីថា ប្រកបដោយអវយវៈសសុទ្ធ មានសម្បុរស្បែកដូចជាផ្កាឈូកស ។

បទថា **អាមោទមានោ** ដោយសេចក្តីថា ទាំងដែលត្រេកអររីករាយផង ។

បទថា **សន្តិកេតំ** ដោយសេចក្តីថា ទៅកាន់លំនៅរបស់ខ្លួន ។

បទថា **បុរេត្វា** ដោយសេចក្តីថា ព្រះនាងទេវីត្រាស់ថា ស្តេចដំរី ធ្វើមហេសីឈ្មោះសព្វភទ្ទា ឱ្យនៅខាង



មុខ ហែហមដោយដំរី ៨០០០ ជាបរិវារទៅកាន់លំនៅរបស់ខ្លួន ។

នាយព្រានសោណុត្តរ ស្តាប់ព្រះសវនីយ៍ហើយ ក៏បានទូលរ៉ាប់រងថា ប្រពៃហើយ ព្រះនាងម្ចាស់ ទូលព្រះបង្គំ នឹងសម្លាប់នូវដំរីនោះ នាំយកភ្លុកមកថ្វាយ ។ គ្រានោះ ព្រះទេវីទ្រង់រីករាយសប្បាយព្រះទ័យ ប្រទានទ្រព្យឱ្យដល់ព្រាន ១០០០ ហើយបង្គាប់ថា អ្នកចូរត្រឡប់ទៅផ្ទះវិញសិនចុះ ៧ ថ្ងៃទៀត សឹមទៅទីនោះ ។ កាលដែលបញ្ជូនព្រានឱ្យទៅហើយ ក៏បង្គាប់ឱ្យជាងដែកមកគាល់ ទ្រង់បញ្ជាថា : នែជាង យើងត្រូវការ កាំបិតបត់ ពូថៅ ចប ពន្លាក ញញួរ កាំបិតកាត់គុម្ពព្រៃឫស្សី កណ្តៀវច្រូត ស្នៅ ដាវ កំណាត់ដែកស្រួច រណារ និងដែកតម្លក់មុខបី អ្នកចូរប្រញាប់ធ្វើរបស់ទាំងអស់មកឱ្យយើង ។ រួចហើយ ព្រះទេវី ក៏បង្គាប់ឱ្យជាងស្បែកមកគាល់ ទ្រង់បញ្ជាថា : នែជាង អ្នកគួរនឹងធ្វើនូវស្បោងស្បែក សម្រាប់ដាក់សម្ភារៈធ្ងន់ ប្រមាណ ១ កុម្ភៈឱ្យយើង ហើយយើងត្រូវការ

ខ្សែស្បែក ខ្សែរឹត ស្រោមដៃ ស្បែកជើង និងឆត្រស្បែក អ្នកចូរជួយធ្វើរបស់ទាំងអស់នេះ មកឱ្យយើងដោយប្រញាប់ផង ។

ចាប់តាំងពីថ្ងៃនោះមក ជាងទាំងពីរនាក់ក៏ប្រញាប់ខំធ្វើរបស់ទាំងអស់ នាំយកមកថ្វាយដល់ព្រះទេវី ។ ព្រះនាងទើបទ្រង់ត្រៀមរៀបចំស្បៀង ឱ្យព្រានសោណុត្តរនោះ តាំងតែពីប្រដាប់បង្កាត់ភ្លើងជាដើមទៅ ។ ព្រះនាងរៀបចំទុកដាក់នូវឧបករណ៍គ្រប់យ៉ាង ព្រមទាំងស្បៀងមានសជូវជាដើមដាក់នៅក្នុងស្បោងស្បែក ។ គ្រឿងឧបករណ៍ និងស្បៀងទាំងអស់នោះ ទម្ងន់ប្រមាណ ១ កុម្ភៈ ។ ចំណែកនាយព្រានសោណុត្តរនោះ ត្រៀមខ្លួនស្រេចហើយ ដល់ថ្ងៃទី ៧ ក៏មកគាល់ថ្វាយបង្គំព្រះរាជ-ទេវី ។ លំដាប់នោះ ព្រះនាងទេវី បានប្រាប់ទៅព្រានថា គ្រឿងឧបករណ៍គ្រប់យ៉ាងរបស់អ្នក ស្រេចបាច់អស់ហើយ អ្នកចូរសាកល្បងលើកស្បោងនេះសិនមើល ។ នាយព្រានសោណុត្តរនោះ ជាមនុស្សដែលមានកម្លាំងច្រើន ទ្រទ្រង់



នូវកម្លាំងស្មើនឹងដំរីសារ ៥ ព្រោះដូច្នោះ ទើបគេចាប់លើកស្បោងឡើងដូចជាស្បោងម្ហូ ហើយស្ពាយនឹងស្មាឈរធ្វើព្រងើយ ដូចឈរស្មាទទេ ។ ព្រះនាងសុភទ្ទា បានប្រទាននូវរបស់របរឱ្យដល់កូនៗ នៃនាយព្រាន ហើយក្រាបទូលឱ្យព្រះរាជាទ្រង់ជ្រាប និងប្រាប់ឱ្យនាយព្រានសោណុត្តរចេញដំណើរទៅ ។

ចំណែកនាយព្រានសោណុត្តរនោះ កាលដែលក្រាបថ្វាយបង្គំព្រះរាជា និងព្រះរាជទេវីហើយ ក៏ចុះចាកអំពីព្រះរាជនិវេសន៍ ឡើងរថចេញពីព្រះនគរ ដោយបរិវារជាច្រើន ឆ្លងកាត់ស្រុកនិគម និងជនបទមកតាមលំដាប់ដល់ចុងនៃព្រះរាជអាណាខេត្តហើយ ទើបឱ្យពួកអ្នកស្រុកត្រឡប់វិលវិញ។ ព្រានសោណុត្តរ ដើរចូលព្រៃទៅជាមួយនឹងអ្នកស្រុកជាយដែន រហូតដល់ផុតដែនដីរបស់មនុស្ស ទើបឱ្យពួកមនុស្សជាយដែនត្រឡប់ទាំងអស់ ហើយដើរទៅតែម្នាក់ឯង ។ នាយព្រាន ដើរចូលព្រៃតែម្នាក់ឯងអស់ ៣០ យោជន៍ ឆ្លងកាត់ព្រៃស្តុក ១៨ លើក ដោយលំដាប់

គឺមុនដំបូងព្រៃស្បូវភ្លាំង ព្រៃស្មៅ រហូតដល់ព្រៃឈើមានខ្លឹម ។ ក្នុងព្រៃទាំងនោះ មានជាអាទិ៍ គឺព្រៃបន្ទា ព្រៃផ្តៅ ព្រៃរពាក់ ព្រៃបបុស ព្រៃត្រែង ព្រៃឫស្សី ព្រៃឈើធម្មតា ព្រៃចម្រុះគ្នា ព្រៃឈើអត់ខ្លឹម ព្រៃឈើមានខ្លឹម និងព្រៃក្រាស់ ។ ព្រៃក្រាស់នោះ សូម្បីតែពស់ក៏វារទៅបានដោយលំបាក ។ កាលដែលព្រានទៅដល់ហើយ ក៏យកកណ្តៀវច្រូតស្បូវភ្លាំងជាដើម យកកាំបិតកាប់គុម្ពព្រៃបន្ទាជាដើម យកពូថៅកាប់គល់ឈើ យកពន្លាកធំចោះធ្វើផ្លូវដើរ ។ ដល់ព្រៃឫស្សី ក៏កាប់ឫស្សីធ្វើបង្គោងដាក់ឡើងទៅលើ ហើយកាប់ទៀត ឱ្យឫស្សីដួលដាក់ធ្វើស្ពានដើរទៅខាងលើគុម្ពឫស្សី ។ ដល់ទីដែលមានភក់សុទ្ធ ក៏ដាក់ឈើស្ងួតៗដើរទៅ ហើយដាក់ឈើដទៃទៀត ជាបន្ត ទើបលើកឈើមុនឡើងសម្រាប់ដាក់តទៅមុខ ។ ឆ្លងទីដែលមានភក់បានហើយ ក៏ដល់ទីដែលមានទឹកសុទ្ធ ក៏ចងក្បូនឆ្លងទៅ ហើយឈរនៅត្រង់ជើងភ្នំ ។ ព្រានបានយកខ្សែចងដែកតម្កក់មុខបី បោះឡើងទៅឱ្យជាប់នៅនឹងភ្នំ ហើយទើប



តោងឡើងតាមខ្សែស្បែកដល់ខាងលើ ដៃឆ្វេងតោងខ្សែ ដៃស្តាំកាន់ដែក ដែលមានមុខដ៏មុតដូចពេជ្រ កាប់ថ្មភ្នំស្រេចហើយ ទើបឈរនៅទីនោះ ហើយកន្ត្រាក់ដែកតម្កក់មុខបី បោះទៅខាងលើទៀត ធ្វើទំនងនេះឯងច្រើនដង រហូតឡើងទៅដល់កំពូលភ្នំ ។ កាលដែលចុះពីភ្នំវិញ ក៏ធ្វើទំនងនោះដែរ ។ អាចារ្យពួកខ្លះបានពោលថា នាយព្រានសោណុត្តរ ចុះអំពីភ្នំដោយឆត្រស្បែក ដូចបក្សីត្រដាងស្លាបទម្លាក់ខ្លួនចុះ ដូច្នោះឯង ។

ព្រះបរមសាស្តា កាលដែលទ្រង់នឹងធ្វើឱ្យច្បាស់-លាស់ នូវដំណើរដែលនាយព្រានសោណុត្តរ ទទួលយកព្រះសវនីយ៍ របស់ព្រះនាងសុភទ្ទាយ៉ាងនេះ ហើយចេញចាកអំពីព្រះនគរ ឆ្លងកាត់ព្រៃស្តុកជាច្រើនកន្លែង រហូតដល់ភ្នំ ហើយឆ្លងភ្នំ ៦ ខាងដើមបាន និងឡើងកាន់កំពូលភ្នំសុវណ្ណបស្សៈ ព្រះអង្គទើបទ្រង់ត្រាស់នូវព្រះគាថា :

**តត្ថេវ សោ ឧគ្គហេត្វាន វាក្យំ**
**អាទាយ តូណិញ្ច ធនុញ្ច លុទ្ទោ**

**វិតុរិយតិ សត្ត គិរី ព្រហន្តេ**
**សុវណ្ណបស្សន្នាម គិរី ឧឡារំ ។**

ព្រានព្រៃនោះ បានរៀនពាក្យក្នុងទីនោះ ហើយក៏ចាប់យកនូវបំពង់ព្រួញ និងធ្នូ ដើរដល់ភ្នំធំទាំង ៧ ។ (កាលដែលឆ្លងផុតពីភ្នំទី ៦ ហើយ) ក៏ពិចារណាមើលទៅ ឃើញភ្នំដ៏ខ្ពស់មួយ ឈ្មោះសុវណ្ណបស្សៈ ។

បណ្ដាបទទាំងនោះ បទថា **សោ** ដោយសេចក្ដីថា ម្នាលភិក្ខុទាំងឡាយ នាយព្រាននោះទទួលយកព្រះតម្រាស់របស់ព្រះទេវី ដែលប្រថាប់នៅលើប្រាសាទជាន់ទី ៧ នោះហើយ កាន់យកបំពង់ព្រួញនិងធ្នូដ៏ធំទៅកាន់ទីស្កុកនៃភ្នំ គិតថា ភ្នំណាហ្ន៎ ឈ្មោះសុវណ្ណបស្សបពឹត បានទៅដល់មហាបពឹតទី ៧ ។

បទថា **វិតុរិយតិ** ដោយសេចក្ដីថា ពិចារណាមើលក្នុងគ្រានោះ ។ កាលដែលកំពុងតែពិចារណាមើលចុះឡើង ក៏បានឃើញភ្នំដែលឈ្មោះថា សុវណ្ណបស្សគិរីដ៏ធំខ្ពស់ ទើបគិតថា គឺជាភ្នំនេះហើយ ។



**អារុយ្ហ សេលំ ភវនំ កិន្នរានំ**
**ឱលោកយិ បព្វតបាទមូលំ**
**តត្ថទ្ទសា មេឃសមានវណ្ណំ**
**និគ្រោធរាជំ អដ្ឋសហស្សបាទំ ។**

ព្រានព្រៃបានឡើងកាន់ភ្នំ ជាកន្លែងនៅនៃពួកកិន្នរ ក៏រមិលមើលនូវទីជិតនៃជើងភ្នំ បានឃើញស្ដេចជ្រៃមួយដើម មានសម្បុរប្រាកដស្មើដោយមេឃ មានពូរ ៨០០០ នៅជិតជើងភ្នំនោះឯង ។

បទថា **ឱលោកយិ** ដោយសេចក្ដីថា គេឡើងទៅកាន់បពឹតដែលជាទីនៅនៃពួកកិន្នរហើយ ឱនចុះសម្លឹងមើលខាងក្រោម កត់សំគាល់ទីដែលព្រះនាងសុភទ្ទាប្រាប់មក ។

បទថា **តត្ថ** ដោយសេចក្ដីថា សម្លឹងឃើញដើមនិគ្រោធនោះ នៅជិតៗនឹងជើងភ្នំនោះឯង ។

**តត្ថទ្ទសា កុញ្ជរំ ឆព្វិសាណំ**
**សព្វសេតំ ទុប្បសហំ បរេភិ**

**រក្ខន្តិ នំ អដ្ឋសហស្សនាគា**

**ឦសាទន្តា វាតជវប្បហារិនោ ។**

បានឃើញដំរីមានភ្លុកពណ៌ ៦ ជាដំរីសសុទ្ធ ដែលពួកដំរីដទៃ គ្របសង្កត់បានដោយក្រ នៅក្រោមដើមជ្រៃនោះ ។ ពួកដំរី ៨០០០ មានភ្លុកងដូចជាចន្ទោលរថ មានប្រក្រតីទៅប្រហារបច្ចាមិត្ត ដោយសន្ទុះដ៏លឿនដូចជាខ្យល់ តែងរក្សានូវស្តេចដំរីនោះ ។

បទថា **តត្ថ** ដោយសេចក្តីថា ឈរនៅនឹងគល់ដើមជ្រៃនោះ ។

**តត្ថទ្ទសា បោក្ខរណឹ អវិទូរេ**

**រម្មំ សុតិត្ថញ្ច មហោទកញ្ច**

**សម្បុប្ផិតំ ភមរគណានុចិណ្ណំ**

**យត្ថ ហិ សោ ន្ហាយតិ នាគរាជា ។**

បានឃើញស្រះបោក្ខរណី នៅជិតដើមជ្រៃនោះ ជាទីគួរីករាយ មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង (មានផ្កាកុមុទ ឧត្បល ចង្កុលណី និងឈូក) រីកស្គុស-



ស្កាយផង ដេរដាសដោយពួកភមរជាតិផង ជាទីសម្រាប់ចុះងូតរបស់ស្តេចដំរីដ៏ប្រសើរនោះ ។

បទថា **តត្ថ** ដោយសេចក្តីថា ខាងក្នុងភ្នំ នៅមិនឆ្ងាយពីដើមជ្រៃនោះឯង ។ ស្តេចដំរីងូតទឹក នាស្រះឆទ្ទន្តណា គេបានឃើញស្រះឆទ្ទន្តនោះ ។

**ឱស្វាន នាគស្ស គតឹ ឋិតញ្ច**

**វីថិស្ស យា ន្ហានគតស្ស ហោតិ**

**ឱឃាតមាគច្ឆិ អនរិយរូបោ**

**បយោជិតោ ចិត្តវសានុគាយ ។**

បានឃើញនូវការដើរទៅ និងការឈរនៅ នៃដំរីដ៏ប្រសើរផង ឃើញផ្លូវរបស់ដំរីដ៏ប្រសើរនោះ ទៅងូតទឹកផង ព្រានព្រៃជាអនរិយជន គឺជនថោកទាប មានចិត្តលាមក ត្រូវព្រះនាងសុភទ្ទា ជាអ្នកធ្លាក់ក្នុងអំណាចចិត្តទ្រង់ប្រើមក ក៏បានចាត់ចែងជីករណ្តៅ ។

បទថា **ឱស្វាន** ដោយសេចក្តីថា ក្នុងពេលដែលដំរីទាំងឡាយទៅហើយ នាយព្រាននោះ ក៏បានចុះអំពី

សុវណ្ណបស្សបពីត ពាក់ស្រោមដៃ និងពាក់ស្បែកជើង ហើយត្រូតពិនិត្យមើល ទីដែលស្តេចដំរីនោះទៅ និងទីដែលស្តេចដំរីនោះនៅជាប្រចាំ ។ ព្រានបានឃើញសព្វគ្រប់ទាំងអស់ គឺឃើញថា ស្តេចដំរីដើរផ្លូវនេះ ងូតទឹកត្រង់នេះ កាលដែលងូតទឹកហើយ ឡើងមកឈរត្រង់នេះ។ ព្រោះព្រានមិនមានហិរិ គឺមានចិត្តលាមក ត្រូវព្រះនាងសុភទ្ទា ដែលជាអ្នកលុះក្នុងអំណាចចិត្ត ប្រើមក ព្រោះហេតុដូច្នោះ ទើបបានជាព្រានមករៀបចំជីករណ្តៅ ។

ក្នុងរឿងនោះ មានសេចក្តីតាមលំដាប់លំដោយដូចតទៅ : បានឮមកថា នាយព្រានសោណុត្តរនោះ មកដល់លំនៅរបស់ព្រះមហាសត្វ កំណត់បាន ៧ ឆ្នាំ, ៧ ខែ, ៧ ថ្ងៃ ។ ព្រានបានកំណត់មើលទីនៅរបស់ព្រះមហាសត្វតាមន័យដែលបានពោលហើយនោះឯង ហើយបានកំណត់ក្នុងចិត្តទុកថា យើងនឹងជីករណ្តៅត្រង់នេះ ឈរអែបក្នុងរណ្តៅនោះ រួចបាញ់ស្តេចដំរីឱ្យដល់នូវសេចក្តីស្លាប់ ។ ដូច្នេះហើយ ព្រានក៏បានចូលព្រៃ កាត់ដើមឈើ



ដើម្បីធ្វើសសរជាដើម ត្រៀមទព្វសម្ភារៈទុក ។ កាលដំរីទាំងឡាយឡើងពីងូតទឹកទៅលំនៅហើយ ទើបយកចបដ៏ធំជីករណ្តៅ ៤ ជ្រុង ត្រង់ទីឈរនៅនៃស្តេចដំរី ហើយយកទឹកស្រោច កាយយកអាចម៍ដីចេញមក ដាំសសរចុះដាក់រនូត ក្រាលក្តារ ចោះប្រហោង រោយធូលីដី និងកាយស្លឹកឈើដាក់ខាងលើ ធ្វើទីចេញចូលរបស់ខ្លួន ។ កាលដែលធ្វើរណ្តៅរួចស្រេចហើយ ក្នុងពេលជិតភ្លឺ ទើបទទូរក្បាល ដណ្តប់សំពត់កាសាវៈ កាន់ធ្នូ ព្រមទាំងព្រួញដែលលាបដោយថ្នាំពិស ចុះទៅឈរក្នុងរណ្តៅ ។

ព្រះបរមសាស្តា កាលដែលទ្រង់ប្រកាសនូវសេចក្តីនោះ ព្រះអង្គបានត្រាស់សម្តែងនូវព្រះគាថា :

**ខណិត្វាន កាសុំ ផលកេហិ ឆាទយិ**
**អត្តានមោធាយ ធនុញ្ច លុទ្ទោ**
**បស្សាគតំ បុថុសល្លេន នាគំ**
**សមប្បយិ ទុក្កដកម្មការី ។**

ព្រានព្រៃ ជាអ្នកធ្វើនូវអំពើអាក្រក់ បានជីករណ្តៅ

ហើយ គ្របដោយផែនក្ដារទាំងឡាយ រួចបញ្ចូលខ្លួន និងធ្នូ ទៅក្នុងរណ្ដៅនោះ ហើយបាញ់នូវដំរី ដែលដើរមកឈរ នៅខាងរណ្ដៅរបស់ខ្លួន ដោយព្រួញដ៏ថ្លោស ។

បណ្ដាបទទាំងនោះ បទថា **បស្សាវគតំ** ដោយសេចក្ដីថា បាញ់ស្ដេចដំរី ដែលមកឈរខាងរណ្ដៅរបស់ខ្លួន ។

បានឮថា ក្នុងថ្ងៃទី ២ ស្ដេចដំរីនោះមកងូតទឹក ហើយឡើងមកឈរនៅទីលានដ៏ធំស្រឡះ ។ លំដាប់នោះ ទឹកបានហូរពីសរីរៈរបស់ស្ដេចដំរីនោះឯង ហូរស្រក់តាមផ្លូវនាភីប្រទេស ធ្លាក់ត្រូវខ្លួនរបស់នាយព្រាន តាមប្រហោងក្ដារ ។ ដោយការសង្កេតដូច្នោះ នាយព្រានក៏ដឹងថា ព្រះមហាសត្វមកឈរនៅពីលើហើយ ទើបយកព្រួញដ៏ធំបាញ់ស្ដេចដំរី ដែលមកឈរនៅខាងរណ្ដៅរបស់ខ្លួន ។

បទថា **ទុក្កដកម្មការី** ដោយសេចក្ដីថា ឈ្មោះថា បុគ្គលធ្វើកម្មដ៏អាក្រក់ ព្រោះបង្កទុក្ខឱ្យកើតដល់ព្រះមហាសត្វ ទាំងកាយ ទាំងចិត្ត ។



**វិទ្ធោ ច នាគោ កោញ្ចមនាទិ ឃោរំ**
**សព្វេច នាគា និន្នាទុ ឃោររូបំ**
**តិណញ្ច កដ្ឋញ្ច រណំ ករោន្តា**
**ធាវឹសុ តេ អដ្ឋ ទិសា សមន្តតោ ។**

ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយ ក៏បន្លឺនូវកោញ្ចនាទដ៏ពន្លឹក ពួកដំរីទាំងអស់ក៏បានបន្លឺនូវសំឡេងមានសភាពដ៏ពន្លឹក ។ ដំរីទាំងនោះ ក៏ធ្វើនូវស្មៅ និងមែកឈើឱ្យខ្ទេចខ្ទី ហើយស្ទុះស្ទាទៅទាំង ៨ ទិសដោយជុំវិញ។

បទថា **កោញ្ចមនាទិ** ដោយសេចក្ដីថា បន្លឺកោញ្ចនាទគឹកកង ។ គប្បីជ្រាបថា សរដ៏ថ្លោសនោះ ទម្លុះចំត្រង់នាភីប្រទេស គឺផ្ចិតនៃស្ដេចដំរី ទម្លាយអវយវៈមានតម្រងបស្សាវៈជាដើម ឱ្យបែកខ្ទេច កាត់ពោះវៀនតូចជាដើម ហើយ រហូតធ្លុះចេញមកខាងខ្នងរបស់ស្ដេចដំរី មិនត្រឹមតែប៉ុណ្ណោះ នៅធ្លុះផុតពីខ្នងស្ដេចដំរី ព្រួញបានស្ទុះលឿនទៅក្នុងអាកាសទៀតផង ។ មុខរបួសធ្លុះធ្លាយដូចជាត្រូវកាប់ដោយពូថៅ ឈាមហូរចេញមកដូចទឹកល័ក្តចេញពី

ថ្នាំង បង្កើតទុក្ខវេទនាដល់ព្រះមហាសត្វពន់ប្រមាណ ។ ស្តេចដំរី មិនអាចអត់ទ្រាំនូវទុក្ខវេទនាបាន ក៏ស្រែកកង រំពង លាន់សន្ធឹកពេញសកលបពិត បន្លឺកោញ្ចនាទពេញ ទំហឹងដល់ទៅបីដង ។

បទថា **សព្វេវ** ដោយសេចក្តីថា ដំរីទាំង ៨០០០ បានឮនូវសំឡេងនោះ ក៏នាំគ្នាតក់ស្លុត ភ័យខ្លាចចំពោះ មរណៈ បន្លឺសំឡេងដ៏ពន្លឹក គួរឱ្យខ្លាចញញើត ។

បទថា **រណំ ករោន្តា** ដោយសេចក្តីថា ដំរី ៨០០០ នាំគ្នាស្រែកដោយសំឡេងគឹកកងរំពងគួរឱ្យស្លុត ស្ទុះមក តាមសំឡេងនោះ ឃើញដំរីឆទ្ទន្តបានទទួលនូវទុក្ខវេទនា ក៏គិតថា ពួកយើងនឹងចាប់បច្ចាមិត្តឱ្យបាន ហើយបាននាំ គ្នារត់រក រហូតស្មៅនិងកំណាត់ឈើបែកបាក់ខ្ទេចខ្ទីរវក់ ។

**វធិស្សមេនន្តិ បរាមសន្តោ**
**កាសាវមទ្ទក្ខិ ធជំ ឥសីនំ**
**ទុក្ខេន ផុដ្ឋស្សុទបាទិ សញ្ញា**
**អរហទ្ធជោ សព្ភិ អវជ្ឈរូបោ ។**



ដំរីដ៏ប្រសើរ យកជើងឈូសដី ដោយបំណងថា អញនឹងសម្លាប់នូវព្រានព្រៃនេះ ក៏ឃើញនូវសំពត់កាសាវៈ ដែលជាទង់ជ័យរបស់ពួកឥសី ។ ដំរីដ៏ប្រសើរ ត្រូវសេចក្តី ទុក្ខប៉ះពាល់ហើយ ក៏មានសញ្ញាកើតឡើងថា ធម្មតា បុគ្គលប្រើប្រាស់នូវទង់ជ័យព្រះអរហន្ត មានសភាពដែល សប្បុរសមិនគួរសម្លាប់ ។

បទថា **វធិស្សមេនន្តិ** ដោយសេចក្តីថា ម្នាលភិក្ខុ ទាំងឡាយ កាលដែលដំរីទាំងឡាយ ចេញទៅក្នុងទិសា-នុទិសហើយ និងកាលដែលនាងដំរីមហាសុភទ្ទា ចូលទៅ ឈរជិត លួងលោមចិត្ត ស្ទាបអង្អែលហើយ ស្តេចដំរីឆទ្ទន្ត ក៏អត់សង្កត់នូវទុក្ខវេទនាបាន ឈប់ស្រែក ហើយកំណត់ ផ្លូវដែលព្រួញបាញ់មក ។ ព្រះមហាសត្វ ពិចារណាមើល ថា បើព្រួញនេះមកអំពីទិសខាងកើត ព្រួញនឹងទម្លុះក្បាល ជាមុន ហើយទៅធ្លាយខាងកន្ទុយ ដូច្នេះជាដើម ប៉ុន្តែនេះ គឺព្រួញចូលតាមផ្ចិត ធ្លុះខ្នងទៅក្នុងអាកាស កាលបើយ៉ាង នេះ នឹងមានមនុស្សឈរនៅក្រោមដីបាញ់មក ។ ព្រះ-

មហាសត្វ បំណងនឹងត្រួតមើលក្រោមដី ទើបគិតថា អ្នកណានឹងដឹងថាមានអ្វីកើតឡើង គួរតែយើងឱ្យនាងមហា-សុភទ្ទាចេញទៅសិន ហើយទើបពោលថា : ប្រពន្ធសម្លាញ់ ដំរីទាំង ៨០០០ នាំគ្នាស្វែងរកបច្ចាមិត្តរបស់ប្តី ដោយនាំគ្នាទៅគ្រប់ទិសានុទិស តើនាងរវល់តែមកធ្វើអ្វីនៅទីនេះ ។ កាលដែលនាងមហាសុភទ្ទាបានស្តាប់ហើយ ក៏តបថា : បពិត្រប្តីសម្លាញ់ នាងខ្ញុំម្ចាស់ ឈរនៅជួយព្យាបាល លួងលោមចិត្តប្តី សូមស្តេចដំរី អត់នូវទោសឱ្យដល់ខ្ញុំម្ចាស់ផងចុះ ។ មហាសុភទ្ទាធ្វើប្រទក្សិណ ៣ ជុំ លុះរួចស្រេចពីការគោរពក្នុងឋានទាំង ៤ ហើយ ក៏ហោះទៅក្នុងអាកាស ។ ចំណែកស្តេចដំរី ក៏យកជើងឈូសដី ក្តារក៏បានរបើកឡើង ស្តេចដំរីឱនមើលទៅឃើញនាយព្រានសោណុត្តរ ក៏កើតទោសចិត្តគិតថា យើងនឹងសម្លាប់វា ទើបលូកប្រមោយដូចជាភួងប្រាក់ចូលទៅ ចាប់លើកនាយព្រានមកខាងលើដាក់ចំពីមុខ ឃើញសំពត់កាសាវៈដែលជាទង់ជ័យព្រះអរហន្ត មានព្រះពុទ្ធជាអម្ចាស់ជា-



ដើម ។ លំដាប់នោះ សញ្ញាស្មារតី គឺការនឹករលឹកឃើញខុសត្រូវ បានកើតឡើងដល់ព្រះមហាសត្វ ដែលបានទទួលនូវទុក្ខវេទនាដ៏ខ្លាំងក្លាដូច្នេះថា ដែលឈ្មោះថា ជាទង់ជ័យនៃព្រះអរហន្ត មិនគួរបណ្ឌិតទម្លាយចោលឡើយ គួរតែធ្វើនូវសក្ការៈគោរពបូជាតែម្យ៉ាងប៉ុណ្ណោះ ដោយពិត ។ កាលដែលព្រះមហាសត្វនឹងសន្ទនាជាមួយនាយព្រាន ទើបពោលនូវគាថា ២ គាថា :

**អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហិស្សតិ**
**អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ។**

អ្នកណាមិនទាន់បង្អន់ទឹកចត់ កិលេសសង្កត់ចិត្តក្បត់បំពាន
ប្រាសចាកបញ្ញាគ្មានការទូន្មាន តណ្ហាស្រេកឃ្លានមិនមានសច្ចៈ ។
ជាជនទ្រុស្តសីលសិរិលសាកសព នឹងស្លៀកដណ្តប់ដោយកាសាវៈ
អ្នកនោះមិនគួរនាំឱ្យប្រឡាក់ នូវកាសាវៈទង់ជ័យអរហន្ត ។

គាថានោះ មានសេចក្តីអធិប្បាយដូចនេះ ម្នាលព្រានព្រៃអើយ បុគ្គលណា នៅមានកិលេសដូចទឹកចត់ មានរាគៈជាដើម ប្រាសចាកការទូន្មាននូវឥន្ទ្រិយ ទាំង

វចីសច្ចៈ គឺមិនចូលដល់គុណទាំងអស់នោះ ហើយស្លៀកដណ្តប់នូវកាសាវពស្ត្រ ដែលជ្រលក់ដោយទឹកអម្ចត់ បុគ្គលនោះ មិនគួរនឹងស្លៀកដណ្តប់នូវកាសាវពស្ត្រនោះឡើយ គឺមិនសមគួរជាមួយនឹងសំពត់នោះឯង ។ រីឯគាថាទី ២ ដែលស្តេចដំរីឆទ្ទន្តបានពោលគឺ

**យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ**
**ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។**

ចំណែកអ្នកណាខ្ជាក់ចោលទឹកចត់ សង្កត់កិលេសចេះគ្រប់ចេះគ្រាន់
ទូន្មានឥន្ទ្រិយសតិដឹងទាន់ មិនភាន់ស្មារតីវចីសច្ចៈ ។
ជាអ្នកតាំងមាំក្នុងសីលគ្រប់សព្វ នឹងស្លៀកដណ្តប់ដោយកាសាវៈ
អ្នកនោះទើបគួរមាននូវសិទ្ធិស័ក្តិ ទ្រទ្រង់ទុកដាក់កាសាវពស្ត្រ ។

ដោយសេចក្តីថា បុគ្គលណា ជាអ្នកជម្រះនូវកិលេសបាន គឺខ្ជាក់ចោលនូវកិលេសដូចទឹកចត់ទាំងនោះបាន ។

បទថា **សីលេសុ សុសមាហិតោ** ដោយសេចក្តីថា បុគ្គលណា ជាអ្នកមានសីលនិងអាចារៈ តាំងមាំដោយល្អ



បរិបូណ៌ បុគ្គលនោះ ឈ្មោះថា គួរស្លៀកដណ្តប់នូវសំពត់កាសាវៈនេះ ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់ប្រកាសនូវសេចក្តីនោះ ទើបព្រះអង្គទ្រង់ត្រាស់នូវព្រះគាថា :

**សមប្បិតោ បុថុសល្លេន នាគោ**
**អទុដ្ឋចិត្តោ លុទ្ទកំ អជ្ឈភាសិ**
**កិមត្ថិយំ កិស្ស វា សម្ម ហេតុ**
**មមំ វធី កស្ស វា យំ បយោគោ ។**

ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយ ដោយសរដ៏ថ្លោស មិនមានចិត្តប្រទូស្ត បាននិយាយនឹងព្រានព្រៃថា នែសម្លាញ់ អ្នកត្រូវការអ្វី តើព្រោះហេតុអ្វី បានជាអ្នកសម្លាប់យើង ម្យ៉ាងទៀត ការប្រកបនេះ ជារបស់បុគ្គលណា ។

បណ្តាបទទាំងនោះ បទថា **កិមត្ថិយំ** ដោយសេចក្តីថា អ្នកប្រាថ្នាអ្វីទុកក្នុងអនាគត ។

បទថា **កិស្ស វា** ប្រែថា ព្រោះហេតុអ្វី ។

អធិប្បាយថា ដោយហេតុណា គឺអ្នកចងពៀរអ្វីជាមួយនឹងយើង ។

បទថា **ភស្ស ទា** ដោយសេចក្ដីថា ឬថា នេះជាបំណងរបស់អ្នកដទៃ គឺអ្នកណា ប្រើអ្នកឱ្យមកសម្លាប់យើង ។

កាលដែលព្រានសោណុត្តរ ប្រាប់នូវសេចក្ដីនោះដល់ស្ដេចដំរី ក៏បានពោលព្រះគាថា :

**កាសិស្ស រញ្ញោ មហេសី ភទន្តេ**
**សា បូជិតា រាជកុលេ សុភទ្ទា**
**សា តំ អទ្ទស សា ច មមំ អសំសិ**
**ទន្តេហិ អត្ថោតិ មមំ អវោច ។**

| | |
|---|---|
| បពិត្រដំរីដ៏ចម្រើនអើយ | មិនមែនខ្ញុំឡើយគឺព្រះក្សត្រី |
| ស្រីស្រស់ស្រីង្គារនាដែនកាសី | មានព្រះសវនីយ៍ដោយក្ដីប្រាថ្នា ។ |
| ព្រះនាងទេវីនាមសុភទ្ទា | ដែលគេបូជាក្នុងរាជវង្សា |
| សុបិនឃើញអ្នកហើយប្រាប់ខ្ញុំថា | យើងនេះត្រូវការនូវភ្លុកទាំងគូ ។ |



បណ្ដាបទទាំងនោះ បទថា **បូជិតា** ដោយសេចក្ដីថា ដែលប្រជាជនបូជាហើយ ក្នុងឋានៈជាព្រះអគ្គមហេសី ។

បទថា **អទ្ទស** ដោយសេចក្ដីថា ព្រះនាងទ្រង់ព្រះសុបិននិមិត្តឃើញអ្នក ។

បទថា **អសំសិ** ដោយសេចក្ដីថា ទាំងដែលព្រះ-នាងម្ចាស់ ទ្រង់ប្រោសឱ្យធ្វើសក្ការៈដល់យើងខ្ញុំហើយ និងត្រាស់ប្រាប់ថា ក្នុងព្រៃហិមពាន្ត មានស្ដេចដំរី រូបរាងយ៉ាងនេះ នៅក្នុងកន្លែងនោះ ។

បទថា **ទន្តេហិ** ដោយសេចក្ដីថា ព្រះនាងទេវីបានត្រាស់ប្រាប់ដល់យើងខ្ញុំថា ភ្លុកទាំង ២ របស់ស្ដេចដំរីនោះមានរស្មី ៦ ពណ៌ដ៏រុងរឿង យើងត្រូវការនូវភ្លុកទាំងនោះបំណងនឹងធ្វើជាគ្រឿងប្រដាប់ អ្នកចូរទៅនាំយកនូវភ្លុកនៃដំរីនោះ មកឱ្យយើង ។

ព្រះមហាសត្វ បានស្ដាប់ដូច្នោះហើយ ក៏ដឹងថានេះជាអំពើរបស់នាងចុល្លសុភទ្ទា ។ ព្រះមហាសត្វ ខំអត់ទ្រាំនូវទុក្ខវេទនា ហើយបានពោលថា : ព្រះនាង

សុភទ្ទានោះ មិនមែនត្រូវការនូវភ្លុកទាំងពីររបស់យើងទេ នេះគឺជាបំណងដែលប៉ងដើម្បីឱ្យអ្នកសម្លាប់យើង ទើបបានបញ្ជូនអ្នកឱ្យមកដូច្នេះ ។ កាលដែលនឹងសម្ដែងសេចក្ដីតទៅ ទើបព្រះមហាសត្វពោលនូវគាថា ២ គាថា :

**ពហូ ហិ មេ ទន្តយុគា ឧឡារា**
**យេ មេ បិតូនញ្ច បិតាមហានំ**
**ជានាតិ សា កោធនា រាជបុត្តី**
**វធត្ថិកា វេរមកាសិ ពាលា ។**

ព្រះរាជបុត្រីប្រាកដដឹងថា គូនៃភ្លុកណានោះវ៉ាច្រើនក្រៃ
របស់បិតាជីតាយើងនៃ តែនេះស្រីថ្លៃមានក្ដីរោធ ។
ជាមួយនឹងយើងនាងចងវេរា បំណងពាធាជាប់ជារហូត
នាងជាស្រីល្ងង់លង់ក្នុងក្ដីក្រោធ ទើបឱ្យអ្នកស្រូតមកសម្លាប់យើង ។

បណ្ដាបទទាំងនោះ បទថា **ឥមេ** ដោយសេចក្ដីថា ភ្លុកទាំងឡាយ ជាច្រើនលើករបស់បិតានិងជីតានៃស្ដេចដំរីនោះ បានទុកដាក់ក្នុងទីកំបាំង ដោយបំណងថា កុំបានដល់នូវសេចក្ដីវិនាសឡើយ ។ ស្ដេចដំរីឆទ្ទន្តសំដៅយកភ្លុកដំរី



ទាំងនោះ ទើបពោលយ៉ាងនេះ ។

បទថា **ជានាតិ** ដោយសេចក្ដីថា ព្រះនាងសុភទ្ទានោះ ជ្រាបហើយថា ភ្លុកនៃដំរីមានចំនួនដ៏ច្រើន លាក់ទុកដាក់ក្នុងទីនេះ ។

បទថា **វធត្ថិកា** ដោយសេចក្ដីថា ប៉ុន្តែព្រះនាងសុភទ្ទានោះ មានបំណងឱ្យអ្នកសម្លាប់យើងឱ្យស្លាប់តែម្ដង នាងបានចងពៀរ ព្រោះទុកនូវសេចក្ដីព្យាបាទ សូម្បីគ្រាន់តែរឿងបន្តិចបន្តួចក្នុងចិត្ត គឺព្រះនាងនឹងឱ្យយើងដល់នូវសេចក្ដីស្លាប់ ដោយអំពើដ៏កាចសាហាវដែលមានសភាពបែបនេះ ។

**ឧដ្ឋេហិ តំ លុទ្ទ ខរំ គហេត្វា**
**ទន្តេ ឥមេ ឆិន្ទ បុរា មរាមិ**
**វជ្ជាសិ តំ កោធនំ រាជបុត្តឹ**
**នាគោ ហតោ ហន្ទ ឥមស្ស ទន្តា ។**

នៃព្រានព្រៃអើយអ្នកក្រោកមកវ៉ា ចូរចាប់រណារហើយអារនូវភ្លុក
ទាំងគូនេះចុះយើងទ្រាំនឹងទុក្ខ យើងលះបង់ភ្លុកមុននឹងមរណា ។

អ្នកគប្បីទូលព្រះរាជបុត្រី ដែលមានសេចក្ដីខឹងក្រោធនោះថា ស្ដេចដំរីសបានស្លាប់ហើយណា នេះគូទន្ដាសូមយាងទទួល ។

បទថា **ខរំ** ប្រែថា រណារ ។

បទថា **បុរា មរាមិ** ដោយសេចក្ដីថា ពេលដែលយើងនៅមិនទាន់ស្លាប់ ។

បទថា **ទជ្ជាសិ** ដោយសេចក្ដីថា អ្នកគប្បីក្រាបទូល ។

បទថា **ហន្ទ ឥមស្ស ឧន្នា** ដោយសេចក្ដីថា អ្នកគប្បីទូលព្រះនាងសុភទ្ទានោះថា ស្ដេចដំរីនោះត្រូវទូល-ព្រះបង្គំសម្លាប់ឱ្យស្លាប់ហើយ មនោរថរបស់ព្រះនាងបានដល់ទីបំផុតហើយ សូមព្រះនាងយាងទទួលនូវភ្លុកទាំងគូនេះ របស់ស្ដេចដំរីនោះចុះ ។

នាយព្រានសោណុត្តរ បានស្ដាប់ពាក្យរបស់ស្ដេចដំរីហើយ ក៏ក្រោកឡើងចាកទីអង្គុយ កាន់រណារចូលមកជិតៗស្ដេចដំរី ដោយគិតថា យើងនឹងកាត់យកភ្លុកទៅ ។ ឯស្ដេចដំរីនោះកម្ពស់ប្រមាណ ១២០ ហត្ថ ឈរខ្ពស់



ត្រដែតហាក់ដូចជាភ្នំប្រាក់ ដោយហេតុនេះ ព្រានសោណុត្តរទើបឈោងអារភ្លុកមិនដល់ ។ លំដាប់នោះ ព្រះមហាសត្វ ទើបដាក់កាយចុះដេកឱនក្បាលឱ្យទាប ។ ខណៈនោះឯងនាយព្រាន ក៏បានជាន់ប្រមោយដែលដូចជាភ្លូងប្រាក់របស់ព្រះមហាសត្វ ឡើងទៅនៅលើសីសៈបីដូចជាឡើងទៅឈរលើកំពូលភ្នំកៃលាស ហើយយកជង្គង់បុករុញសាច់ដែលសំយុងចុះត្រង់មាត់ ញាត់ចូលទៅខាងក្នុង ។ ព្រានចុះអំពីសីសៈនៃស្ដេចដំរីមកវិញ ទើបស៊ិករណារចូលទៅខាងក្នុងមាត់ យកដៃទាំងពីរទាញចុះរុញឡើង យ៉ាងប្រញាប់ប្រញាល់ ។ ទុក្ខវេទនាកើតឡើងដល់ព្រះមហាសត្វដ៏យ៉ាងខ្លាំងក្លា មាត់ពេញទៅដោយព្រះលោហិត ។ កាលបើនាយព្រានអារចុះ អារឡើង ក៏មិនអាចអារឱ្យដាច់នូវភ្លុកនោះបានឡើយ ។ ក្នុងកាលនោះ ព្រះមហាសត្វ ទើបខំខ្ជាក់លោហិតចេញពីមាត់ ស៊ូទ្រាំនូវទុក្ខវេទនា សួរនាយព្រានថា សម្លាញ់អើយ អ្នកមិនអាចនឹងកាត់ភ្លុកឱ្យដាច់បានទេឬ ? នាយព្រានសោណុត្តរ

បានតបថា : ពិតមែនហើយលោកម្ចាស់ ។ ព្រះមហាសត្វតាំងសតិមាំ ពោលថា បើដូច្នោះ អ្នកចូរលើកប្រមោយរបស់យើងឡើង ឱ្យចាប់នូវដងរណារខាងលើ ព្រោះយើងខ្លួនឯង មិនមានកម្លាំងនឹងលើកប្រមោយរបស់ខ្លួនឯងបាន ។ នាយព្រានក៏បានធ្វើតាមយ៉ាងនោះ ។ ព្រះ-មហាសត្វយកប្រមោយចាប់កាន់ដៃរណារ ហើយខំអារភ្លុកខ្លួនឯង ស្រាប់តែភ្លុកទាំងពីរដាច់ចុះ ហាក់ដូចជាកាត់មែកឈើដូច្នោះឯង ។ ស្តេចដំរីទើបឱ្យនាយព្រាន នាំភ្លុកទាំងនោះ មកកាន់នៅនឹងប្រមោយ ហើយពោលថា : **សម្លាញ់ព្រាន យើងឱ្យភ្លុកទាំងនេះ មិនមែនថា យើងមិនស្រឡាញ់នោះទេ ហើយយើង ក៏មិនបានប្រាថ្នានូវភាពជា ព្រះឥន្ទ ជាមារ ជាព្រហ្មឡើយ ប៉ុន្តែព្រោះភ្លុកគឺព្រះសព្វញ្ញុតញ្ញាណនោះ យើងស្រឡាញ់ជាងគូនៃភ្លុកនេះ រាប់រយពាន់ដង ។ សូមបុណ្យនេះ ចូរជាបច្ច័យនៃការបានសម្រេច នូវព្រះសព្វញ្ញុតញ្ញាណ ។** រួចហើយ ព្រះមហាសត្វក៏បានឱ្យភ្លុកទៅព្រាន ហើយសួរ



ថា តើអ្នកមកដល់ទីនេះ អស់ពេលប៉ុន្មានដែរ ? កាលដែលនាយ ព្រានប្រាប់ថា : ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ទើបព្រះមហា-សត្វពោលថា : អញ្ជើញអ្នកទៅដោយអានុភាពនៃភ្លុក ១ គូនេះ អ្នកនឹងដល់ព្រះនគរពារាណសី ខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ។

ព្រះមហាសត្វ បានធ្វើនូវការរក្សា ឱ្យដល់នាយព្រានសោណុត្តរនោះ បញ្ជូនគេទៅដោយតាំងសច្ចាធិដ្ឋានថា :

**យើងជាអ្នកត្រូវព្រួញពិសទម្លុះរាងកាយហើយ សូម្បីត្រូវទុក្ខវេទនាគ្របសង្កត់ដ៏ខ្លាំងក្លា ក៏មិនបានគិតប្រទូសរ៉ាយដល់បុគ្គល ដែលស្លៀកដណ្តប់នូវកាសាវ-ពស្ត្រ ។ បើសេចក្តីនេះជាការពិត យើងជាស្តេចដំរីសូមអធិដ្ឋាន សូមឱ្យពាឡម្រឹគក្នុងព្រៃសណ្ឌៈ កុំគប្បីមករាំងស្ទះ ធ្វើនូវអន្តរាយឱ្យដល់នាយព្រាននេះឡើយ ។**

ក្នុងគ្រានោះឯង កាលដែលព្រះមហាសត្វបញ្ជូននាយព្រានឱ្យទៅហើយ ក៏បានដួលចុះ ធ្វើនូវកាលកិរិយា

ទាំងដែលពួកដំរី និងនាងមហាសុភទ្ទា មិនទាន់បានមកដល់វិញផង ។

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់ប្រកាសនូវសេចក្តីនោះ ទើបត្រាស់នូវព្រះគាថា :

**ឧដ្ឋាយ សោ លុទ្ទោ ខរំ គហេត្វា**
**ឆេត្វាន ទន្តានិ គជុត្តមស្ស**
**វគ្គូ សុភេ អប្បដិមេ បថព្យា**
**អាទាយ បក្កាមិ តតោ ហិ ខិប្បំ ។**

ព្រានព្រៃនោះ ក្រោកឈរឡើង ហើយចាប់រណារអារនូវភ្លុកនៃដំរីដ៏ប្រសើរ ហើយក៏យកនូវភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ដើរចៀសចេញទៅអំពីទីនោះ យ៉ាងឆាប់ ។

បណ្តាបទទាំងនោះ បទថា **វគ្គូ** ប្រែថា ល្អដ៏វិសាល ។

បទថា **សុភេ** ប្រែថា ស្អាត ។

បទថា **អប្បដិមេ** ដោយសេចក្តីថា ល្អស្អាត រកភ្លុក



ដទៃក្នុងផែនដីនេះប្រៀបមិនបាន ។

កាលនាយព្រាននោះ ចៀសចេញទៅហើយ ដំរីទាំងឡាយក៏មកដល់ ដោយមិនបានឃើញនូវបច្ចាមិត្តឡើយ ។ ព្រះបរមសាស្តា ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថាជាបន្ត :

**ភយដ្ដិតា នាគវធេន អដ្ដា**
**យេ តេ នាគា អដ្ឋ ទិសា វិធាវុំ**
**អទិស្វាន បោសំ គជបច្ចាមិត្តំ**
**បច្ចាគមុំ យេន សោ នាគរាជា ។**

ពួកដំរីត្រូវភ័យ បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខព្រួយ ព្រោះគេសម្លាប់នូវដំរីដ៏ប្រសើរ បានស្ទុះទៅគ្រប់ទិសទាំង ៨ លុះមិនឃើញបុរសជាសត្រូវនឹងដំរី ក៏ត្រឡប់មកកាន់ទីនៃស្តេចដំរីដ៏ប្រសើរវិញ ។

បណ្តាបទទាំងនោះ បទថា **ភយដ្ដិតា** ដោយសេចក្តីថា ដោយការភ័យខ្លាចចំពោះមរណភ័យ ចូលមកគំរាមហើយ ។

បទថា **អង្ឃា** ប្រែថា ដល់នូវសេចក្ដីទុក្ខ ។

បទថា **គជបច្ចាមិត្តំ** បានដល់ បុគ្គលដែលជាសត្រូវរបស់ស្ដេចដំរី ។

បទថា **យេន សោ** ដោយសេចក្ដីថា ស្ដេចដំរីនោះ ដួលចុះធ្វើកាលកិរិយា ក្នុងទីលានដ៏ធំទូលាយ ដូចជាភ្នំកៃលាស ដំរីទាំងឡាយ នាំគ្នាមកកាន់ទីនោះ ។

ចំណែកនាងមហាសុភទ្ទា ដែលមកព្រមគ្នានឹងដំរីទាំងនោះក្ដី ដំរីទាំង ៨០០០ ក្ដី នាំគ្នាយំស្រែកពេញទំហឹងក្នុងទីនោះ ហើយនាំគ្នាទៅកាន់សំណាក់នៃព្រះបច្ចេកពុទ្ធ។ ដំរីដែលជាកុលុបកៈនៃព្រះមហាសត្វ បានក្រាបទូលដល់ព្រះបច្ចេកពុទ្ធថា : បពិត្រ ព្រះអង្គដ៏ចម្រើន បច្ចយទាយករបស់លោកម្ចាស់ទាំងឡាយ ត្រូវបាញ់ដោយព្រួញពិស ធ្វើកាលកិរិយាហើយ សូមនិមន្តនូវលោកម្ចាស់ទាំងឡាយទៅមើលសពរបស់បច្ចយទាយកនោះ ។ ចំណែកព្រះបច្ចេកពុទ្ធទាំង ៥០០ អង្គ ក៏ហោះមកតាមផ្លូវអាកាស ចុះត្រង់ទីលានដ៏ធំនោះឯង ។ ខណៈនោះ ដំរីធំៗ ជួយគ្នា



យកភ្លុកលើកសរីរកាយរបស់ស្ដេចដំរី ឡើងកាន់ចិតកាធារ (ជើងថ្ករ ) ហើយធ្វើឈាបនកិច្ច ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ធ្វើការស្វាធ្យាយព្រះធម៌នៅក្នុងទីបូជាសពស្ដេចដំរីនោះរហូតដល់ភ្លឺ ។ ដំរីទាំង ៨០០០ នាំគ្នាពន្លត់ភ្លើងដោយការស្រោចទឹកត្រង់ជើងថ្ករួចស្រេចហើយ បានឱ្យមហាសុភទ្ទានាំមុខ មកកាន់លំនៅរបស់ខ្លួន ។

ព្រះបរមសាស្ដា កាលដែលទ្រង់ប្រកាសនូវសេចក្ដីនោះ ក៏បានត្រាស់នូវព្រះគាថា :

**តេ តត្ថ កន្ទិត្វា រោទិត្វាន នាគា**
**សីសេ សកេ បំសុកំ ឱកិរិត្វា**
**អាគមិំសុ តេ សព្វេ សកំ និកេតំ**
**បុរក្ខត្វា មហេសឹ សព្វភទ្ទំ ។**

ដំរីដ៏ប្រសើរទាំងនោះ កន្ទក់កន្ទេញស្រែករពោទ៍ក្នុងទីនោះ ហើយរោយរាយនូវកម្ទេចផេះ ត្រង់ទីបូជាសពដាក់លើសីសៈរបស់ខ្លួន ។ ដំរីទាំងអស់នោះ ក៏ឱ្យមេដំរីជាមហេសី ឈ្មោះសព្វភទ្ទាដើរមុខ មកកាន់ទីនៅរបស់ខ្លួន។

បណ្ដាបទទាំងនោះ បទថា **បំសុកំ** បានដល់ធូលីនៃសិរីវង្គារ គឺផេះធ្យូងត្រង់ទីបូជាសព ។

ចំណែកនាយព្រានសោណុត្តរ យកភ្លុកទាំងគូមក នៅមិនទាន់គ្រប់ ៧ ថ្ងៃផង ក៏ដល់ព្រះនគរពារាណសី ។ ព្រះបរមសាស្ដា ទ្រង់ត្រាស់ព្រះគាថាជាបន្ត :

**អាទាយ ទន្តានិ គជុត្តមស្ស**
**វគ្គូ សុភេ អប្បដិមេ បឋព្យា**
**សុវណ្ណរាជីហិ សមន្តមោទរេ**
**សោ លុទ្ទកោ កាសិបុរំ ឧបាគមិ**
**ឧបនេសិ សោ រាជកញ្ញាយ ទន្តេ**
**នាគោ ហតោ ហន្ទ ឥមស្ស ទន្តា ។**

ព្រានព្រៃនោះបាននាំយកភ្លុកទាំងគូនៃដំរីដ៏ប្រសើរ ជាភ្លុកល្អ ស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបាន នៅលើផែនដី ភ្លឺសព្វដោយរស្មី មានពណ៌ដូចមាស ហើយចូលទៅកាន់ដែនកាសី ។ ព្រានព្រៃនោះ ក៏បង្អោននូវភ្លុកទាំងគូ ថ្វាយព្រះរាជកញ្ញាថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំ



ជាខ្ញុំសម្លាប់បានហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ ។

បណ្ដាបទទាំងនោះ បទថា **សុវណ្ណរាជីហិ** ដោយសេចក្ដីថា ចាំងជះរស្មីមានពណ៌ដូចមាស ។

បទថា **សមន្តមោទរេ** ដោយសេចក្ដីថា ជះរស្មីពណ៌មាសទៅដោយជុំវិញក្នុងព្រៃសណ្ឌៈ ។

បទថា **ឧបនេសិ** ដោយសេចក្ដីថា ចំណែកនាយព្រានសោណុត្តរ បញ្ជូនដំណឹងទៅទូលព្រះទេវីថា ទូល-ព្រះបង្គំនឹងនាំភ្លុកទាំងគូ ដែលចាំងជះរស្មី ៦ ពណ៌ នៃស្ដេចដំរីឆទ្ទន្តចូលមកថ្វាយ សូមព្រះទេវីទ្រង់ប្រោសឱ្យគេប្រដាប់តាក់តែងនូវព្រះនគរ ឱ្យដូចជានគរទេវតា ។ នាយព្រានក៏ចូលកាន់ព្រះនគរ ឡើងទៅកាន់ប្រាសាទ នាំភ្លុកទាំងគូចូលទៅ ។ កាលដែលព្រាននាំភ្លុកចូលទៅហើយ ក៏ក្រាបទូលថា បពិត្រព្រះនាងម្ចាស់ ទូលព្រះបង្គំបានដឹងថា ព្រះនាងម្ចាស់ មានការខឹងក្រោធដោយហេតុបន្តិច-បន្តួច ហើយចងពៀរនឹងស្ដេចដំរីណា ទូលព្រះបង្គំ បាន

សម្លាប់នូវដំរីនោះហើយ សូមយាងព្រះនាងម្ចាស់ទតមើលចុះ នេះគឺភ្លុកទាំងគូនៃស្ដេចដំរីនោះ ។ នាយព្រាន ក៏បានថ្វាយនូវភ្លុកនោះដល់ព្រះនាងសុភទ្ទា ។ ព្រះនាងសុភទ្ទាបានយកប្រដាប់ទ្រធ្វើដោយកែវមណី ទទួលនូវគូនៃភ្លុកដ៏វិចិត្រ មានរស្មី ៦ ពណ៌ របស់ព្រះមហាសត្វ មកដាក់ត្រង់ដើមទ្រូង ទតព្រះនេត្រមើលភ្លុកនៃស្វាមីដ៏ជាទីស្រឡាញ់របស់ព្រះនាងក្នុងជាតិមុន ។ ភ្លាមនោះ ព្រះទេវី បានរលឹកថា នាយព្រានសោណុត្តរ សម្លាប់ស្ដេចដំរី ដែលមានសភាពដ៏ល្អបែបនេះ ឱ្យបាត់បង់ជីវិត ហើយកាត់យកភ្លុកទាំងគូមក ។ កាលដែលព្រះនាងនឹកដល់អនុស្សាវរីយ៍ជាមួយនឹងព្រះមហាសត្វ ទ្រង់ក៏សោកសៅដ៏ក្រៃលែងមិនអាចអត់ទ្រាំបាន ។ ពេលនោះ ដួងហឫទ័យរបស់ព្រះនាងក៏បានបែកធ្លាយ ហើយធ្វើកាលកិរិយាទៅ ក្នុងថ្ងៃនោះឯង ។

ព្រះបរមសាស្ដា កាលដែលទ្រង់ប្រកាសនូវសេចក្ដីនោះ ព្រះអង្គបានត្រាស់នូវព្រះគាថា :



**ទិស្វាន ទន្តានិ គជុត្តមស្ស**
**ភត្តុ បិយស្ស បុរិមាយ ជាតិយា**
**តត្ថេវ តស្សា ហទយំ អផាសិ**
**តេនេវ សា កាលមកាសិ ពាលា ។**

ព្រះនាងសុភទ្ទា បានទតឃើញភ្លុកទាំងគូនៃដំរីដ៏ប្រសើរ ដែលធ្លាប់ជាប្ដីដ៏ជាទីស្រឡាញ់អំពីជាតិមុន ក៏បែកហឫទ័យក្នុងទីនោះឯង ហេតុនោះ ព្រះនាងជាស្រីល្ងង់បានសោយព្រះវិលាល័យទៅ ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលដែលសរសើរនូវព្រះគុណនៃព្រះទសពល ទើបបានសម្ដែងជាគាថា :

**សម្ពោធិបត្តោ ច មហានុភាវោ**
**សិតំ អកាសី បរិសាយ មជ្ឈេ**
**បុច្ឆីសុ ភិក្ខូ សុវិមុត្តចិត្តា**
**នាការណោ បាតុករោន្តិ ពុទ្ធា ។**

ព្រះបរមសាស្តា ព្រះអង្គបានសម្រេចនូវសម្ពោ-ធិញ្ញាណផង មានអានុភាពច្រើនផង បានធ្វើនូវការញញឹម ក្នុងកណ្តាលនៃពួកបរិស័ទ ។ ភិក្ខុទាំងឡាយដែលមានចិត្តផុតស្រឡះហើយ បានក្រាបបង្គំទូលសួរថា ព្រះពុទ្ធទាំងឡាយ មិនដែលធ្វើនូវការញញឹមឱ្យប្រាកដ ដោយឥតហេតុទេ ។

បណ្តាបទទាំងនោះ បទថា **សិតំ អាកាសិ** ដោយសេចក្តីថា ម្នាលអាវុសោទាំងឡាយ ព្រះបរមសាស្តា ទ្រង់បានសម្រេចនូវព្រះសម្ពោធិញ្ញាណ ហើយមាននូវអានុភាពច្រើន ថ្ងៃមួយ ព្រះអង្គទ្រង់គង់លើធម្មាសនៈ ដែលបានប្រដាប់តាក់តែងហើយ កណ្តាលបរិស័ទ ក្នុងសាលាធម្មសភា ទ្រង់ធ្វើនូវការញញឹម ។

បទថា **នាភារណេ** ដោយសេចក្តីថា ភិក្ខុទាំងឡាយ ដែលជាព្រះខីណាស្រព បានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលធ្វើនូវការញញឹម ដោយឥតហេតុទេ ។ ក៏ការញញឹមរបស់



ព្រះអង្គដែលទ្រង់ធ្វើហើយ តើអ្វីហ្ន៎ ដែលជាហេតុ ឱ្យព្រះអង្គទ្រង់ញញឹម ។

**យមទ្ទសាថ ឧហរឹ កុមារឹ**
**កាសាវវត្ថំ អនគារិយំ ចរន្តឹ**
**សា ខោ តទា រាជកញ្ញា អហោសិ**
**អហំ តទា នាគរាជា អហោសឹ ។**

អ្នកទាំងឡាយ បានឃើញនាងក្រមុំជាក្មេងស្រីណា ស្លៀកដណ្តប់សំពត់កាសាវៈ ប្រព្រឹត្តអនាគារិយវត្ត នាងភិក្ខុនីនោះ ក្នុងកាលនោះគឺព្រះរាជកញ្ញា ។ ឯស្តេចដំរីក្នុងកាលនោះ គឺជា **តថាគត** ។

បទថា **យមទ្ទសាថ** ដោយសេចក្តីថា ម្នាលអាវុសោទាំងឡាយ ព្រះសាស្តា ដែលភិក្ខុទាំងឡាយទូលសួរដូច្នេះហើយ កាលដែលព្រះអង្គទ្រង់ត្រាស់ប្រាប់ហេតុនៃការញញឹមរបស់ព្រះអង្គ ទ្រង់ចង្អុលភិក្ខុនីក្រមុំមួយអង្គ ហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយឃើញក្មេងស្រីនេះណា ដែលពេញក្រមុំ គ្រងនូវ

កាសាវពស្ត្រ បួសប្រព្រឹត្តនូវអនាគារិយវត្ត ក្នុងព្រះ-សាសនានេះ នាងភិក្ខុនីនោះ គឺព្រះនាងសុភទ្ទារាជកញ្ញា ក្នុងកាលនោះ ដែលជាអ្នកប្រើនាយព្រានសោណុត្តរទៅ ថា អ្នកចូរយកព្រួញលាបថ្នាំពិស ទៅបាញ់សម្លាប់ស្តេចដំរី ។ កាលនោះ តថាគតជាស្តេចដំរី ដែលនាយព្រានសោណុត្តរបានទៅបាញ់ ឱ្យដល់នូវការអស់ជីវិត ។

**អាទាយ ទន្តានិ គជុត្តមស្ស**
**វគ្គូ សុភេ អប្បដិមេ បថព្យា**
**យោ លុទ្ទកោ កាសិបុរំ ឧបាគមិ**
**សោ ខោ តទា ទេវទត្តោ អហោសិ** ។

ព្រានព្រៃណា កាន់យកនូវភ្លុកទាំងឡាយ នៃដំរីដ៏ប្រសើរ ជាភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ហើយចូលទៅកាន់កាសិបុរី ព្រានព្រៃនោះក្នុងកាលនោះ គឺជាទេវទត្ត ។

បទថា **ទេវទត្តោ** ដោយសេចក្តីថា ម្នាលភិក្ខុទាំងឡាយ នាយព្រានសោណុត្តរ ក្នុងគ្រានោះ បានមកជា



ទេវទត្ត ក្នុងកាលនេះ ។

**អនាវសូរំ ចិររត្តសំសិតំ**
**ឧច្ចាវចំ ចរិតមិទំ បុរាណំ**
**វីតទ្ទរោ វីតសោកោ វិសល្លោ**
**សយំ អភិញ្ញាយ អភាសិ ពុទ្ធោ** ។

ព្រះពុទ្ធអង្គ ទ្រង់ប្រាសចាកសេចក្តីក្រវល់ក្រវាយ ប្រាសចាកសេចក្តីសោក ប្រាសចាកនូវកូនសរគឺរាគៈ បានជ្រាបច្បាស់ដោយព្រះអង្គឯង ហើយទ្រង់សម្តែង នូវចរិតខ្ពស់និងទាបក្នុងកាលមុន ដែលអន្ទោលទៅអស់កាលដ៏យូរ ហាក់ដូចជាមិនកន្លងថ្ងៃ ។

បទថា **អនាវសូរំ** កាត់បទជា **ន** **អវសូរំ** ប្រែថា ព្រះអាទិត្យនៅមិនទាន់អស្តង្គត ។

បទថា **ចិររត្តសំសិតំ** ដោយសេចក្តីថា រាប់ដោយពេលដ៏យូរអង្វែង ព្រះអង្គទ្រង់ត្រាច់រង្គាត់ទៅហើយ គឺទ្រង់ស្ទុះទៅហើយ បានដល់ទ្រង់ប្រព្រឹត្តមកហើយដោយលំដាប់ ក្នុងទីបំផុតនៃកោដិកប្បមិនតិចឡើយ ។ លោក

ពោលពាក្យ អធិប្បាយទុកថា ម្នាលអាវុសោទាំងឡាយ ព្រះពុទ្ធជាអម្ចាស់ ដែលថា ទ្រង់ប្រាសចាកនូវការក្រវល់-ក្រវាយ ព្រោះព្រះអង្គប្រាសចាកកិលេស មានរាគៈជាដើម ។ ដែលថា ទ្រង់ប្រាសចាកនូវសេចក្ដីសោក ព្រោះមិនមានការសោកសៅដែលកើតអំពីញាតិ និងទ្រព្យជាដើម ។ ដែលថា ទ្រង់ប្រាសចាកនូវកូនសរ ព្រោះប្រាសចាកនូវកូនសរ មានរាគៈជាដើម ។ ទ្រង់ជ្រាបច្បាស់ដោយព្រះអង្គឯង ហើយបានត្រាស់រឿងនេះ ដែលជារឿងពីបុរាណ ។

ដែលឈ្មោះថា ព្រះចរិយាទាំងខ្ពស់ទាំងទាប ព្រោះទ្រង់ខ្ពស់ ដោយអំណាចនៃបុព្វចរិយារបស់ព្រះអង្គ និងព្រោះទាប ដោយអំណាចនៃចរិយារបស់ព្រះនាងសុភទ្ទារាជធីតា និង ចរិយារបស់នាយព្រានសោណុត្តរ គឺហាក់ដូចជា អំពើដែលធ្វើដោយការវង្វេង និងប្រាសចាកការវង្វេងនោះ ធ្វើនៅពេលព្រឹក ហើយព្រះអង្គទ្រង់រលឹកបាននៅពេលល្ងាចថ្ងៃនោះ ដូច្នោះឯង ។



**អហំ ខោ តេន កាលេន អហោសិំ តត្ថ ភិក្ខវេ នាគរាជា តទាហោសិំ ឯវំ ធារេថ ជាតកន្តិ ។**

ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតនៅក្នុងទីនោះ តថាគតគឺជាស្ដេចដំរី ។ អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។

បទថា **ខោ** ក្នុងបទថា **អហំ ខោ** នេះគ្រាន់តែជានិបាត ។ សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតបានជាស្ដេចដំរីនៅនឹងស្រះឆទ្ទន្តនោះ ។

បទថា **នាគរាជា** ដោយសេចក្ដីថា ក្នុងកាលនោះ នឹងថាជាអ្នកណាក៏ទេដែរ ដោយពិត ក៏គឺតថាគតជាស្ដេចដំរីឆទ្ទន្ត ។

បទថា **ឯវំ ធារេថ** ដោយសេចក្ដីថា អ្នកទាំង-ឡាយ ចូរទ្រទ្រង់ចាំទុក គឺគប្បីរៀននូវព្រះជាតកនេះដោយប្រការដូច្នេះឯង ។

មនុស្សទាំងឡាយ បានស្ដាប់នូវព្រះធម៌ទេសនាហើយ បានសម្រេចជាព្រះសោតាបន្នជាដើម ។ ចំណែក

នាងភិក្ខុនីក្រមុំអង្គនោះ ចម្រើនវិបស្សនាហើយ ក្រោយមកក៏បានសម្រេចនូវព្រះអរហត្តផល ។

**ចប់ ឆទ្ទន្តជាតក**

# រៀបរៀងកំណាព្យក្នុងឆទ្ទន្តជាតក

## ព្រះរាជាសន្ទនានឹងព្រះមហេសី

ម្នាលនាងសុភទ្ទាគួរនាចរណៃ ខ្លួនប្រាណជើងដៃបីដូចជាមាស
សម្បុរលឿងខ្ចីស្រីវរោភាស នេត្រាល្អល្អះវិសេសវិសាល ។
តើនាងកើតអ្វីទើបស្រីសោកា ភក្រ្តាស្រពោនទុក្ខអូនពុំស្រាល
បីដូចបទុមគេខ្ទាំហើយហាល អម្បាលមាលាក្នុងគ្រាស្រពាប់ ។

បពិត្រមហារាជអំណាចបវរ ខ្ញុំម្ចាស់ចាញ់គភិព្រោះតែយល់សប្តិ
ចំណង់ចម្លែកក្រែងប្លែកអភ័ព្វ មិនអាចបានទ្រព្យប្រសព្វទុក្ខព្រួយ ។

កាមគុណទាំងអស់ជារបស់មនុស្សា ក្នុងលោកនេះរ៉ាងណានីមួយ
សុទ្ធតែរបស់យើងម្ចាស់អូនកុំព្រួយ រៀមបងនឹងជួយតាមចិត្តអូនចង់។



បពិត្រព្រះអង្គសូមទ្រង់ឱ្យព្រាន ដែលមានប៉ុន្មានក្នុងដែនដីទ្រង់
មកប្រជុំគ្នាកុំបីរារង់ នឹងប្រាប់ចំណង់ដល់ពួកព្រានព្រៃ ។

សូមព្រះទេវីទតព្រះនេត្រា ពួកព្រាននេះណាសុទ្ធមានថ្វីដៃ
ជាអ្នកក្លៀវក្លាស្គាល់ម្រឹគស្គាល់ព្រៃ ដើម្បីក្សត្រថ្លៃស៊ូក្សយ័យនឹងជួយ ។

## ព្រះនាងសុភទ្ទាពោលទៅរកពួកព្រាន

លុទ្ទបុត្រទាំងអស់ដែលកោះប្រជុំ ចូរស្តាប់ពាក្យខ្ញុំរៀបរាប់ទុក្ខព្រួយ
ខ្ញុំសុបិនឃើញដំរីសមួយ ចិត្តញ៉រវញ្ជួយព្រោះចង់បានភ្លុក ។
ព្រោះភ្លុកទាំងគូចែងចាំងរស្មី ឆព្វណ្ណរង្សីហត្ថីប្រមុខ
ភ្ញាក់ឡើងកាលណាចិន្តាកើតទុក្ខ បើមិនបានភ្លុកខ្ញុំមុខជាក្ស័យ ។

## ពួកព្រានទូលសួរសេចក្តីនឹងព្រះទេវី

ពួកកូនចៅព្រានមានរាប់ពាន់នាក់ បានស្តាប់ឮជាក់ភ្ញាក់ផ្អើលពេកក្រៃ
ក្នុងចិត្តគ្រប់គ្នាមានការសង្ស័យ ថាឱម្ចាស់ថ្លៃដំរីអ្វីហ្នឹង ។
បិតាជីតាញាតិសាលោហិត នៃយើងខ្ញុំពិតគឺឥតដែលដឹង
ស្តេចដំរីសារអស្ចារ្យម្ល៉ឹងៗ មិនដែលបានដឹងបានឃើញឮឡើយ ។

គឺភ្លុកឆទ្ទន្តឆព្វណ្ណរង្សី ព្រះរាជបុត្រីសូមទ្រង់ត្រាស់ឆ្លើយ
សុបិនម្ដេចខ្លះទ្រង់ត្រាស់ឱ្យហើយ កុំបីកន្ដើយកុំឡើយលាក់ការណ៍ ។
ទិសតូចមានបួនជួននឹងទិសធំ លើក្រោមជួបជុំគ្រប់ដប់ទិសា
តើស្ដេចដំរីឋិតនៅទិសណា សូមព្រះវាចាតាមការយល់សប្ដិ ។
ស្ដេចដំរីសភ្លុកឆរង្សី ឈរដើរដេកដីប្រក្រតីទាំងសព្វ
ងូតទឹកយ៉ាងណាបរិវារតាមជាប់ ព្រះនាងរៀបរាប់សព្វគ្រប់ទើបល្អ ។

## ព្រះនាងសុភទ្ទាឆ្លើយប្រាប់សេចក្ដី ដល់ព្រានសោណុត្តរ

អ្នកចេញអំពីទីតាំងនេះទៅ ត្រូវដើរសំដៅទៅទិសឧត្តរ
ឆ្លងភ្នំធំៗឡើងខ្ពស់តៗ ខ្ពស់ក្រៃបវរភ្នំទីប្រាំពីរ ។
ភ្នំនោះមានឈ្មោះសុវណ្ណបស្សៈ អ្នកឃើញប្រចក្សបុប្ផាគិរី
ព្រមទាំងកិន្នរអ៊ូអរមូលមីរ សុវណ្ណគិរីសព្វសត្វទ្រហឹង ។
អ្នកចូរឡើងភ្នំជំរំកិន្នរ រួចហើយឱនកនេត្រាសម្លឹង
មើលចុះមកក្រោមដល់ជើងភ្នំហ្នឹង គ្រានោះអ្នកដឹងហេតុការណ៍ប្រាកដ ។
គឺអ្នកបានឃើញស្ដេចជ្រៃមួយដើម មានពួរសម្បើមប្រាំបីពាន់គត់
និគ្រោធរាជាមានពណ៌ប្រាកដ បាលីកំណត់មេឃវណ្ណោ ។



ស្ដេចដំរីសភ្លុកឆរង្សី នៅក្រោមដើមជ្រៃជោគជ័យពេញពោរ
គ្មានអ្វីផ្ទាញ់បានសន្ដានទន់ទោរ ស្ដេចកុញ្ជរោបរិវារញីឈ្មោល ។
ដំរីរក្សាមានប្រាំបីពាន់ អង្គរក្សឆទ្ទន្តភ្លុកដូចចន្ទោល
សន្ទុះដូចខ្យល់ប្រហារខ្ទាំងចោល មិនងាយនឹងចូលដល់សត្វជាម្ចាស់ ។
បរិវារទាំងនោះស្រែកស្រុះគួរស្លុត ក្រេវក្រោធបំផុតសូម្បីខ្យល់ប៉ះ
ឈរអែបឯកអង្គដង្ហើមខ្លាំងណាស់ សូរខ្យល់ឮច្បាស់កក្រើកធរណី ។
បើបានឃើញមនុស្សក្នុងទីនោះឯង គ្មានខ្លាចរអែងចាប់បោកជាន់ឈ្លី
ធ្វើឱ្យជាផេះជាផង់ធូលី បាត់បង់ជីវីខ្ទេចខ្ទីសូន្យល្អង ។
ជិតទីលំនៅនៃស្ដេចដំរី មានបោក្ខរណីស្អាតក្រៃកន្លង
មហោទកាទឹកថ្លាច្រើនផង ផ្កាមានលំអងរីករោយព្រោងព្រាត ។
កំពង់រាបស្មើសែនមនោរម្យ ដេរដាសដោយឃ្មុំភមរជាតិ
ឯស្ដេចដំរីតែងនៅមិនឃ្លាត ពីស្រះជលជាតស្រពកាយបវរ ។
ស្ដេចដំរីសបវរអង្គកាយ ស្បែកសសុសសាយដូចផ្កាឈូកស
ជម្រះសីសៈរីករាយត្រេកអរ ទ្រង់ផ្កាបវរឧប្បលមាលា ។
ឱ្យមេដំរីមហេសីសត្វ មាននាមបញ្ញត្តិសព្វភទ្ទា
នាំមុខទៅកាន់និគ្រោធរាជា ឬក៏គុហាលំនៅអាត្មា ។

## ព្រានសោណុត្តរសួរបញ្ជាក់ព្រះទេវី

បពិត្រសម្តេចព្រះរាជទេវី    គ្រឿងកែវមណីភ្ញីអលង្ការ
មាសប្រាក់កែវកងមានកែវមុក្តា    វេឡុរិយាគឺកែវពៃទូរ្យ ។
រតនៈគ្រប់យ៉ាងក្នុងរាជត្រកូល    បើរួមប្រមូលចាត់ចូលពហូ
ប៉ុន្តែព្រះនាងទ្រង់នៅគិតគូរ    ឱ្យព្រានតស៊ូសម្លាប់មហាសត្វ ។
ដើម្បីយកភ្លុកស្តេចដំរីស    ព្រៃភ្នំច្រើនតហើយឆ្ងាយពេកក្តាត់
ឧបសគ្គពេកកូវដែលត្រូវឆ្លងកាត់    គឺមិនមែនសត្វដែលងាយប្រហារ ។
បពិត្រសម្តេចព្រះជននី    តើព្រះទេវីពិតជាត្រូវការ
ដើម្បីយកភ្លុកឬក៏ប្រាថ្នា    ប្រហារកូនចៅផៅពង្សព្រានពិត ។

## ព្រះទេវីទ្រង់ឆ្លើយសារភាព

នែម្នាលនាយព្រានកុំមានកង្វា    យើងមានឥស្សាទាំងការអន់ចិត្ត
នឹកឃើញរឿងដើមយើងរឹងរៃពិត    ទើបយើងរិះគិតតាមព្យេវដែលចង ។
ម្នាលនាយព្រានព្រៃចូរលៃលកចុះ    ប្រសិនការនោះសមតាមបំណង
ប្រាំស្រុកយកសួយបានមួយសែនម្តង    យើងនឹងតបស្នងសងគុណដល់ព្រាន ។
នែសម្លាញ់ព្រានកុំមានបារម្ភ    ជាតិមុនយើងខំសន្សំធ្វើទាន
ដល់ព្រះបច្ចេកពោធិញ្ញាណ    រួចហើយយើងមានសេចក្តីប្រាថ្នា ។



ថាសូមឱ្យយើងបានឡើងឋានៈ    មានសិទ្ធិមានស័ក្តិសម្រេចកិច្ចការ
អាចប្រើនាយព្រានមកបាញ់ប្រហារ យកភ្លុកគជសារជាការសម្រេច ។
ចូរព្រានទៅចុះឱ្យលុះការងារ    កុំខ្លាចកុំរាតាំងចិត្តប្តូរផ្តាច់
យើងបានចងព្យេវមុខតែសម្រេច កាត់ភ្លុកថ្វាយស្តេចរង្វាន់បានព្រាន ។

## ដំរីឆទ្ទន្តទូន្មានព្រានសោណុត្តរ

អ្នកណាមិនទាន់បង្អន់ទឹកចត់    កិលេសសង្កត់ចិត្តក្បត់បំពាន
ប្រាសចាកបញ្ញាគ្មានការទូន្មាន    តណ្ហាស្រេកឃ្លានមិនមានសច្ចៈ ។
ជាជនទ្រុស្តសីលសិរិលសាកសព    នឹងស្លៀកដណ្តប់ដោយកាសាវៈ
អ្នកនោះមិនគួរនាំឱ្យប្រឡាក់    នូវកាសាវៈទង់ជ័យអរហន្ត ។
ចំណែកអ្នកណាខ្ជាក់ចោលទឹកចត់    សង្កត់កិលេសចេះគ្រប់ចេះគ្រាន់
ទូន្មានឥន្ទ្រិយសតិដឹងទាន់    មិនភាន់ស្មារតីវិចីសច្ចៈ ។
ជាអ្នកតាំងមាំក្នុងសីលគ្រប់សព្វ    នឹងស្លៀកដណ្តប់ដោយកាសាវៈ
អ្នកនោះទើបគួរមាននូវសិទ្ធិស័ក្តិ    ទ្រទ្រង់ទុកដាក់កាសាវពស្ត្រ ។
នែសម្លាញ់ព្រានអ្នកមានការអ្វី    ទើបបាញ់ដំរីព្រោះក្តីទោមនស្ស
ឬព្រោះត្រូវការដោយទ្រព្យរបស់    ឬកិច្ចទាំងអស់ព្រោះគេប្រើមក ។
សម្លាញ់ព្រានអើយយើងមិនប្រទូស្ត ត្រូវសរបាញ់ធ្លុះក៏យើងមិនសោក
អំពើអ្នកធ្វើជាកម្មទាបថោក    សូមអ្នកប្រាប់មកតើព្រោះហេតុអ្វី ។

## ព្រានសោណុត្តរពោលនឹងដំរីឆទ្ទន្ត

បពិត្រដំរីដ៏ចម្រើនអើយ　　មិនមែនខ្ញុំឡើយគឺព្រះក្សត្រី
ស្រីស្រស់ស្រីង្គារនាដែនកាសី　　មានព្រះសវនីយ៍ដោយក្ដីប្រាថ្នា ។
ព្រះនាងទេវីនាមសុភទ្ទា　　ដែលគេបូជាក្នុងរាជវង្សា
សុបិនឃើញអ្នកហើយប្រាប់ខ្ញុំថា　　យើងនេះត្រូវការភ្លុកគូរង្សី ។

## ដំរីឆទ្ទន្តបរិច្ចាគភ្លុកបំពេញព្រះបារមី

ព្រះរាជបុត្រីប្រាកដដឹងថា　　គូនៃភ្លុកណានោះវ៉ាច្រើនក្រៃ
របស់បិតាជីតាយើងនៃ　　តែនេះស្រីថ្លៃមានក្ដីវិរោធ ។
ជាមួយនឹងយើងនាងចងវេរា　　បំណងពាធាជាប់ជារហូត
នាងជាស្រីល្ងង់លង់ក្នុងក្ដីក្រោធ　　ទើបឱ្យអ្នកស្រូតមកសម្លាប់យើង ។
អ្នកលបបាញ់យើងដំឡើងព្រួញពិស　　បាញ់ត្រូវចំទិសពិសក្ដៅដូចភ្លើង
យើងអាចជាន់អ្នកកម្ទេចនឹងជើង　　ចូរអ្នកក្រោកឡើងយើងមិនប្រហារ ។
ឱសម្លាញ់ព្រានយើងទ្រាំនឹងទុក្ខ　　យើងឱ្យទានភ្លុកមុនក្ស័យជីវ៉ា
មិនមែនយើងស្អប់នូវភ្លុកនេះណា　　ក៏មិនប្រាថ្នាទេវតាឥន្ទព្រហ្ម ។
តែយើងប្រាថ្នាសម្ពោធិញ្ញាណ　　នាំសត្វកោដិលានទិព្វានសុខធំ
យើងសាងបារមីខន្តីអប់រំ　　នាំមនុស្សឥន្ទព្រហ្មឱ្យឆ្លងចាកទុក្ខ ។



នៃព្រានព្រៃអើយអ្នកចូលមកវ៉ា　　ហើយចាប់រណារអារកាត់នូវភ្លុក
ទាំងគូនេះចុះយើងទ្រាំនឹងទុក្ខ　　យើងលះបង់ភ្លុកមុននឹងមរណា ។
អ្នកគប្បីទូលព្រះរាជបុត្រី　　ដែលមានសេចក្ដីខឹងក្រោធនោះថា
ស្ដេចដំរីសបានស្លាប់ហើយណា　　នេះគូទន្ដានៃគជសារនោះ ។
បពិត្រព្រះនាងសូមយាងទទួល　　ដំរីមុនដួលស្រុះស្រួលសន្ដោស
បរិច្ចាគនូវភ្លុកឥតមានប្រទូស្ដ　　ប្រាថ្នាឱ្យលុះពោធិញ្ញាណថ្លៃថ្លា ។

## ព្រះពោធិសត្វអធិដ្ឋានឱ្យព្រានបានសុខតាមផ្លូវ

យើងត្រូវព្រួញពិសទម្លុះរាងកាយ　　មិនប្រទូសរ៉ាយដល់ជនឫស្យា
និងព្រោះព្រានជាប់ដណ្ដប់កាយា　　សំពត់ថ្លៃថ្លាទង់ជ័យពោធិញ្ញាណ ។
បើសេចក្ដីនេះជាការមែនពិត　　យើងសូមតាំងចិត្តសច្ចាធិដ្ឋាន
ក្នុងព្រៃដែលមានពាឡម្រឹគសាមាន្យ　　សូមកុំរំខានដល់ព្រានឡើយណា ។
②-កាលដែលមហាសត្វជាពុទ្ធង្កូរ　　លះភ្លុកទាំងគូប្តូរយកសម្ពោ
សម្ពោធិញ្ញាណមានរឿងសោកា　　ដល់ពួកគជសារមហាសុភទ្ទា ។
ព្រះពោធិសត្វពិតជាអស្ចារ្យ　　មុននឹងមរណាទ្រាំទុក្ខវេទនា
ខន្តីមេត្តាតបនឹងវេរា　　ព្រួញពិសក្លាយជាមាលាថ្វាយព្រះ ។

# អានិសង្សនៃការរម្ងាប់សេចក្ដីក្រោធ

ព្រះសាស្ដា កាលដែលព្រះអង្គគង់ប្រថាប់នៅអគ្គាឡវចេតិយ ទ្រង់ប្រារព្ធទេវតាមួយអង្គដែលមានបញ្ហាជាមួយភិក្ខុមួយរូប ព្រះអង្គទ្រង់ត្រាស់នូវព្រះធម៌ទេសនានេះថា « **យោ វេ ឧប្បតិតំ កោធំ** » ជាដើម ។

## ភិក្ខុកាប់ដើមឈើដែលទេវតាអាស្រ័យនៅ

សេចក្ដីពិស្ដារថា កាលព្រះសាស្ដាទ្រង់អនុញ្ញាតនូវសេនាសនៈដល់ភិក្ខុសង្ឃហើយ និងកាលសេនាសនៈទាំងឡាយ ដែលគ្រហស្ថទាំងឡាយ មានសេដ្ឋីក្នុងក្រុងរាជគ្រឹះជាដើម កំពុងចាត់ចែងឱ្យគេធ្វើ ក្នុងកាលនោះមានភិក្ខុអ្នកស្រុកអាឡវីមួយអង្គ បានសាងនូវសេនាសនៈរបស់ខ្លួន ។



ភិក្ខុមួយអង្គនោះ បានឃើញដើមឈើមួយដើមដែលធ្វើឱ្យលោកពេញចិត្ត ។ នៅពេលដែលលោករៀបចំនឹងកាប់ដើមឈើនោះ ស្រាប់តែទេវតាមានកូនតូចមួយអង្គ ដែលអាស្រ័យនៅនឹងដើមឈើនោះឯង ជាកន្លែងដែលទេវរាជក្នុងឋានចាតុម្មហារាជិកា អនុញ្ញាតឱ្យនៅបានពកូននឹងចង្កេះមកឈរអង្វរភិក្ខុអង្គនោះថា : បពិត្រព្រះគុណម្ចាស់ សូមព្រះគុណម្ចាស់កុំកាប់វិមានរបស់ខ្ញុំម្ចាស់ឡើយ ព្រោះខ្ញុំម្ចាស់មិនអាចពកូនដើររសាត់អណ្ដែតដោយមិនមានទីកន្លែងនៅនោះទេ ។

ភិក្ខុគិតថា យើងមិនអាចនឹងរកនូវដើមឈើផ្សេងឱ្យបានល្អដូចដើមឈើនេះឡើយ ។ ភិក្ខុទើបមិនអើពើនឹងពាក្យអង្វររបស់ទេវតានោះ ។

ទេវតាគិតថា ភិក្ខុនេះឃើញទារកហើយ នឹងឈប់កាប់ជាពិតប្រាកដ ។ ទេវតាទើបយកកូនទៅដាក់នៅនឹងមែកឈើត្រង់កន្លែងដែលភិក្ខុត្រូវកាប់ ទាំងដែលលោកកំពុងតែយារព្រៅថៅដើម្បីនឹងកាប់ទៅហើយនោះ ។

ចំណែកភិក្ខុកាលដែលលោកបានយារពូថៅ ដើម្បីនឹងកាប់ទៅហើយ លោកមិនអាចបញ្ឈប់នូវពូថៅនោះបានឡើយ ក៏ធ្វើឱ្យដាច់ដៃកូនទេវតានោះទៅ ។

ទេវតាកើតសេចក្តីក្រោធយ៉ាងខ្លាំង បានលើកដៃទាំងពីរឡើងដោយចេតនាថា អញនឹងទះភិក្ខុនេះឱ្យស្លាប់។ តែភ្លាមនោះ ក៏បានគិតយ៉ាងនេះថា ភិក្ខុនេះជាអ្នកមានសីល បើយើងសម្លាប់លោកទៅ យើងត្រូវធ្លាក់នរក ឯទេវតាដទៃទៀត កាលបានជួបភិក្ខុទាំងឡាយណា កាប់ដើមឈើរបស់ខ្លួនហើយ នឹងយកយើងជាគំរូ រួចហើយនឹងសម្លាប់ភិក្ខុទាំងឡាយនោះ ។

បានស្តាប់មកថា នៅព្រៃហិមពាន្ត មានការប្រជុំទេវតា រាល់៧ថ្ងៃបក្ស ។ ក្នុងព្រៃហិមពាន្តនោះ ពួកទេវតារមែងសួរនូវរុក្ខធម៌ថា អ្នកតាំងនៅ ឬមិនតាំងនៅក្នុងរុក្ខធម៌ ។ ឈ្មោះថា « រុក្ខធម៌ » បានដល់ ការដែលរុក្ខទេវតាមិនប្រទូសរ៉ាយតាមផ្លូវចិត្ត នៅពេលដែលដើមឈើជាលំនៅរបស់ខ្លួនត្រូវកាប់ ។ បណ្តាទេវតាទាំងនោះ



ទេវតាអង្គណាមិនតាំងនៅក្នុងរុក្ខធម៌ទេ ទេវតាអង្គនោះត្រូវគេបណ្តេញមិនឱ្យចូលរួមក្នុងអង្គប្រជុំឡើយ ។

**ទេវតាអង្គនេះឯង បានពិចារណាឃើញទោសក្នុងការមិនតាំងនៅក្នុងរុក្ខធម៌ ហើយបានលើកដល់បុព្វចរិយា ក្នុងកាលដែលព្រះតថាគតសោយព្រះជាតិជាដំរីឆទ្ទន្តជាដើម ដោយក្រសែនៃព្រះធម៌ទេសនា តាមដែលខ្លួនធ្លាប់បានស្តាប់មកអំពីព្រះឱ្ឋនៃព្រះដ៏មានព្រះភាគ ២**

ទេវតាអង្គនេះបានគិតជាបន្តទៀតថា ភិក្ខុនេះមានបិតា យើងនឹងក្រាបទូលរឿងនេះដល់បិតារបស់លោក ។ ទេវតាបានដាក់ដៃចុះហើយ រួចស្រែកយំទៅកាន់សំណាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ បានឈរនៅក្នុងទីមួយដ៏សមគួរ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងទេវតាអង្គនេះថា : តើយ៉ាងដូចម្តេចហ្នឹង ទេវតា ?

ទេវតាក៏បានក្រាបទូលថា : បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអង្គនោះ បានធ្វើនូវកម្មដូចនេះ ខ្ញុំព្រះអង្គប្រាថ្នានឹង

សម្លាប់លោក ប៉ុន្តែខ្ញុំព្រះអង្គបានគិតនូវសេចក្តីដូចនេះ ទើបមិនសម្លាប់លោកទៅវិញ ហើយក៏ប្រញាប់មកកាន់ទីនេះ ។ ទេវតាបានក្រាបទូលរឿងនោះទាំងអស់ ដោយពិស្តារចំពោះព្រះដ៏មានព្រះភាគ ។

ព្រះសាស្តាទ្រង់ព្រះសណ្តាប់រឿងនោះហើយ ព្រះអង្គត្រាស់ថា : សាធុ ! សាធុ ! ប្រពៃហើយទេវតា ត្រង់ដែលអ្នកគ្របសង្កត់នូវសេចក្តីក្រោធ ដែលកើតឡើងយ៉ាងនោះបាន ប្រៀបដូចជាគេបញ្ឈប់បាននូវរថ ដែលកំពុងតែលឿនទៅមុខដូច្នោះឯង ។

ព្រះអង្គបានត្រាស់ដូច្នេះហើយ ទើបទ្រង់សម្តែងនូវព្រះគាថាជាបន្ត :

**យោ វេ ឧប្បតិតំ កោធំ រថំ ភន្តំវ ធារយេ**
**តមហំ សារថឹ ព្រូមិ រស្មិគ្គាហោ ឥតរោ ជនោ** ។

ជនណា ហាមនូវសេចក្តីក្រោធ ដែលកើតឡើងហើយបាន ដូចជានាយសារថីបញ្ឈប់រថដែលកំពុងតែឆ្ពោះទៅមុខបានយ៉ាងនោះឯង តថាគតហៅជននោះថា



ជា **សារថី** ជនក្រៅពីនេះគ្រាន់តែជាអ្នកកាន់នូវខ្សែបង្ហៀរប៉ុណ្ណោះឯង ។

## ពន្យល់សេចក្តី

បណ្តាបទទាំងនោះ បទថា **ឧប្បតិតំ** បានដល់ដែលកើតឡើងហើយ ។

ពីរបទថា **រថំ ភន្តំវ** ដោយសេចក្តីថា ដូចយ៉ាងនាយសារថីដែលឆ្លាត បញ្ឈប់រថដែលកំពុងតែស្ទុះទៅយ៉ាងលឿនឱ្យឈប់បានតាមសេចក្តីប្រាថ្នា យ៉ាងណាមិញ បុគ្គលណា អាចសង្កត់នូវសេចក្តីក្រោធដែល កើតឡើងបាន ក៏យ៉ាងនោះដែរ ។

បទថា **តមហំ** ដោយសេចក្តីថា តថាគតហៅបុគ្គលនោះថា ជា **សារថី** ។

ពីរបទថា **ឥតរោ ជនោ** ដោយសេចក្តីថា ចំណែកជនក្រៅអំពីនេះ គឺសារថីរថរបស់ឥស្សរជនមាន

ព្រះរាជានិងឧបរាជជាដើម រមែងមានឈ្មោះត្រឹមតែថា ជាអ្នកកាន់ខ្សែបង្ហៀរប៉ុណ្ណោះ មិនមែនជាសារថីដ៏ប៉ិនប្រសប់ឡើយ ។

កាលចប់ព្រះធម៌ទេសនា ទេវតាក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម៌ទេសនាបាននូវប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

ចំណែកទេវតា បានក្រាបទូលព្រះដ៏មានព្រះភាគអំពីការដែលខ្លួនមិនមានកន្លែងនៅ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រួតមើលនូវស្ថានរបស់ទេវតាអង្គនេះ ។ ព្រះអង្គទ្រង់បានទតឃើញស្ថានដ៏សមគួរមួយ ទើបព្រះអង្គត្រាស់ទៅកាន់ទេវតាថា : នែ ទេវតាដ៏ចម្រើន មានដើមឈើមួយដើម នៅជិតព្រះគន្ធកុដិនាវត្តជេតពន ដែលទេវតាជាម្ចាស់បានចុតិទៅហើយកាលពីថ្ងៃមុន ដូច្នេះដើមឈើនោះនៅទំនេរ អ្នកចូរទៅស្ថិតនៅនឹងដើមឈើនោះចុះ ។

ចាប់តាំងពីពេលនោះមក ដោយទេវតាអង្គនោះ



បាននូវការគ្រប់គ្រងអំពីព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ក៏បានជាឧបដ្ឋាយិកាដ៏ល្អរបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងពេលដែលមានទេវសមាគម ទេវតាដែលមានស័ក្តិធំទាំងឡាយយាងមក ទេវតាដទៃដែលមានស័ក្តិតូចរមែងថយទៅរហូតដល់មហាសមុទ្រ និងភ្នំចក្កវាឡ ។ ចំណែកទេវតាអង្គនេះអង្គុយស្តាប់ធម៌ក្នុងលំនៅរបស់ខ្លួនហ្នឹងឯង ។ ទេវតាអង្គនេះអង្គុយស្តាប់បញ្ហាទាំងអស់ក្នុងវិមានរបស់ខ្លួន ទោះបីជាពួកភិក្ខុសួរក្នុងបឋមយាមនៃរាត្រីក្តី ទោះបីជាពួកទេវតាសួរក្នុងវេលាមជ្ឈិមយាមនៃរាត្រីក្តី។ សូម្បីស្តេចមហារាជទាំង ៤ ក្នុងឋានចាតុម្មហា-រាជិកា យាងមកកាន់ទីទំនុកបម្រុងព្រះដ៏មានព្រះភាគគ្រាកាលដែលត្រូវយាងត្រឡប់ទៅវិញ ក៏បានសំណេះសំ-ណាលគួរសមជាមួយនឹងទេវតាអង្គនេះដែរ ហើយទើបស្តេចយាងទៅ ។ ទោះជាទេវតាដែលមានស័ក្តិធំដទៃៗទៀត កាលដែលបានជ្រាបថា វិមានរបស់ទេវតានេះគឺព្រះដ៏មានព្រះភាគជាអម្ចាស់ទ្រង់ប្រទាន ដូច្នេះ ក៏រមែង

តែងតែគួរសមជាមួយនឹងទេវតាអង្គនេះជានិច្ច ។

ព្រះសាស្តាទ្រង់ធ្វើរឿងនេះ ឱ្យជាហេតុកើតឡើង ហើយ ទ្រង់ក៏បញ្ញត្តនូវភូតគាមសិក្ខាបទដល់ភិក្ខុទាំងឡាយ ដូច្នេះថា ភិក្ខុធ្វើភូតគាមឱ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ។

**(ស្រង់ចាកអដ្ឋកថាព្រះធម្មបទ កោធវគ្គ**

**និង អដ្ឋកថាព្រះវិន័យ ភូតគាមសិក្ខាបទទី១ )**

≈≈≈≈≈≈≈≈≈≈≈≈≈




**-១២៥-**

## ដាក់អាយុសង្ខារ-បរិនិព្វាន

-អាកាសត្រជាក់ធ្លាក់ជំនោរ តាមព្រែកទឹកហូរសូររងំ
ស្រណោះវាលស្រែខែក្អាត់យំ ម៉ែឪនៅជុំសុខសប្បាយ ។
ថ្ងៃហើយនិងយប់កន្លងទៅ បន្សល់ទុកនៅរឿងទាំងឡាយ
អ្នកស្លាប់បាត់បង់ទាំងរូបកាយ អ្នករស់ខ្វល់ខ្វាយជាធម្មតា ។
អង្គព្រះទ្រង់ញាណមានតេជះ សម្តែងប្រាប់ព្រះអានន្ទថា
រទេះដែលចាស់បរទៅណា ទៅបានដោយសារអបបូស្សី ។
តថាគតចាស់គ្រាំគ្រាហើយ ម្នាលអានន្ទអើយមានមាំអី
ដូចរទេះចាស់អបបូស្សី វស្សាឆ្នាំថ្មីប៉ែតសិបហើយ ។
ក្រោយព្រះអានន្ទទ្រង់ចេញផុត ពីព្រះសម្ពុទ្ធមិនយូរឡើយ
ក្រោយភត្តាហារថ្ងៃត្រង់ហើយ មារមិនកន្តើយគាល់សាស្តា ។
ឆ្នាំម្សាញ់ខែមាឃថ្ងៃអាទិត្យ ពេញបូណ៌មីពិតថ្ងៃនោះណា
ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ចំពោះមុខមារគ្រានោះឯង ។
នៅនាបាវាលចេតិយ ក្បែរវេសាលីក្រៅកំផែង
កក្រើកធរណីគ្រប់កន្លែង ផ្គរលាន់ខ្ទាត់ខ្ទែងខ្ទរអាកាស ។

**-១២៦-**

ក្រោយមកភិក្ខុជួបជុំគ្នា     អង្គព្រះភគវាទ្រង់បានត្រាស់
សម្ដែងគាថាអស្ចារ្យណាស់     រំលឹកយ៉ាងច្បាស់ត្រាស់ឱវាទ ។
-ទ្រង់បានត្រាស់ថាសង្ខារទាំងឡាយតែងតែអន្តរាយវិនាសខូចខាត
ចូរអ្នកទាំងឡាយកុំបីប្រមាទ     ប្រឹងប្រែងសង្វាតឱ្យសម្រេចការ ។
ភាជន៍ដែលស្មូនឆ្នាំងដំដុតដោយដី     តូចក្ដីធំក្ដីឆៅឆ្អិនយ៉ាងណា
ចុងក្រោយរមែងតែងមានកិរិយា     បែកធ្លាយធម្មតានេះជាការពិត ។
យ៉ាងណាជីវិតសព្វសត្វនិករ     ក្មេងចាស់មានក្រពាលឬបណ្ឌិត
ចុងក្រោយរមែងតែងតែស្លាប់ពិត     បាត់បង់ជីវិតក៏យ៉ាងនោះដែរ ។
ជីវិតតថាគតមានប្រមាណតិច     គោរពពាក្យពេចន៍ឥតគេចកែប្រែ
ពីថ្ងៃនេះទៅនៅត្រឹមបីខែ     តថាគតត្រូវតែបរិនិព្វាន ។
-បីខែកន្លងយ៉ាងរហ័ស     សែនសោកស្ដាយណាស់ព្រះទ្រង់ញាណ
វេលាជិតភ្លឺទ្រង់ចូលឈាន     ហើយចូលនិព្វានកណ្ដាលព្រៃ ។
ក្នុងខែពិសាខថ្ងៃអង្គារ     ឆ្នាំម្សាញ់វេលាចុងរាត្រី
ថ្ងៃដប់ប្រាំកើតពេញបូណ៌មី     បរិស័ទប្រុសស្រីជុំត្រៀបត្រា ។
ទីទ្រង់និព្វាននោះតាំងនៅ     ក្បែរផ្លូវទៅក្រុងកុសិនារា
វាំងភ្នំមួយគូសាលព្រឹក្សា     មានផ្ទាំងសិលានៅចន្លោះ ។

-១២៧-

កុំថាឡើយមនុស្សសោយសោកា     សូម្បីទេវតាស្ថានទាំងអស់
យំសោកបោកប្រាណស្ដាយស្រណោះ លាន់កក្រើកអស់ភពផែនដី ។
ទីទ្រង់និព្វាននោះឥឡូវ     មានស្ដូបតាំងនៅល្អប្រិមប្រិយ
សំគាល់ទីដែលព្រះជិនស្រី     និព្វានលើដីកុសិនារា ។
ក្នុងស្ដូបមានព្រះបដិមាថ្ម     កសាងយ៉ាងល្អគួរជ្រះថ្លា
តំណាងព្រះសពព្រះសាស្ដា     ស្ដូកស្ដឹងកាយាសែនអាសូរ ។
អ្នកទៅដល់ពិតចិត្តជិតជាប់     ឃើញដូចព្រះសពនៅជ្រងោ
មានស្បង់ចីវរថ្វាយផ្លាស់ប្ដូរ     ទឹកនេត្រាហូរនឹកព្រះអង្គ ។
នឹកហាក់ដូចជានៅថ្មីៗ     នឹកព្រះជិនស្រីប្រោសស្រោចស្រង់
នឹកដល់ព្រះធម៌ល្អផូរផង់     នឹកទាំងព្រះសង្ឃអង្គសាវ័ក ។
ចាប់តាំងអំពីថ្ងៃនេះទៅ     សូមដើរតាមផ្លូវព្រះអរិយៈ
ក្រោមម្លប់ព្រះធម៌ដ៏ត្រជាក់     ផុតពីអន្ទាក់នៃពួកមារ ។
សូមឱ្យលោកអ្នកបានសូធ្យស្ដាប់     ប្រវត្តិសារសព្វព្រះភគវា
បានសុខចម្រើនគ្រប់ៗគ្នា     កុំបីឃ្លាតឃ្លាគ្រាណាឡើយ ។

សូមអនុមោទនា !

ដោយឧបាសក **គុយ សុធន**

-១២៨-

## សូមពិចារណា

ចំណង់ចង់បានសុខសាន្តមានភ័ព្វ ខំរក្សាទ្រព្យពុំធ្លាប់គិតថា
ចំណេះដឹងនិងសតិបញ្ញា ជាអ្នករក្សាឱ្យសុខស្ងប់ពិត ។
គួរយកដើមឈើធ្វើជាតួយ៉ាង ជាគ្រឿងសំអាងទុកដាស់តឿនចិត្ត
ដើមឈើទ្រាំខ្យល់ទ្រាំនឹងក្ដៅពិត បាំងឱ្យញាតិមិត្តជិតត្រជាក់កាយ ។
កុំសង្ឃឹមថាសង្ខារសំខាន់ កុំចាប់ប្រកាន់ខន្ធធាតុទាំងឡាយ
កុំចងវេរានាំពៀរវែងឆ្ងាយ កុំធំភ្លេចម្ដាយអន្តរាយអស់ញាតិ ។
ដុំបាយមួយចានសម្រាប់មួយថ្ងៃ កេរ្តិ៍ឈ្មោះប្រពៃសម្រាប់មួយជាតិ
ឯបុណ្យកុសលផ្ដល់ផលឥតឃ្លាត សម្រាប់គ្រប់ជាតិក្នុងវដ្ដសង្សារ ។
សូមពុទ្ធបរិស័ទតូចធំទាំងឡាយ កុំបីឃ្លាតឆ្ងាយពីធមិមេត្តា
សូមកុំធំខ្ពស់ហួសគេហ៊ានថា ខុសឆ្គងម្ដេចម្ដាឱ្យគេហ៊ានប្រាប់ ។
សូមប្រុងប្រយ័ត្ននឹងពាក្យសរសើរ ក្រែងគេហែអើអែបអបចាំស្ដាប់
គេអាចបញ្ចោរបញ្ចូនឱ្យស្លាប់ ខុសឆ្គងឥតប្រាប់ចាំចាប់កំហុស ។
សូមឱ្យបាបមិត្តប្ដូរចិត្តប្រិតកាយ សត្រូវទាំងឡាយរសាត់ឆ្ងាយចុះ
អ្នកនៅជិតក្បែរប្រែមានសន្ដោស អ្នកផងស្រីប្រុសបានសុខដោយសារ ។
សូមសុខសួស្ដីសិរីមង្គល ចូលដល់អ្នកដែលមានចិត្តជ្រះថ្លា
គោរពស្រឡាញ់ជាតិនិងសាសនា សុខគ្រប់ប្រការរហូតតទៅ ។

ដោយឧបាសក **គុយ សុធន**



## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការងារធម្មទាន

| | |
|---|---|
| ១. ឧបាសក សំរ៉ង វណ្ណ | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. លោកគ្រូ រស់ សួផាត | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក សោម រតនៈ | ១២. ឧបាសក ជឹង វេងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសិកា ហួនចាន់បូជា | ១៦. ឧបាសិកា ស្រី បូរ៉ាន់ |
| ១៧. ឧបាសិកា ហាយច័ន្ទធីរី | ១៨. ឧបាសក ម៉ៅ ផុន |

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- ឧ.ស. យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម ........... ..... ស.រ.អ.

២- ឧ.ស. ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសែ .............  ស.រ.អ.

៣- ឧ.ស. ឆាយអ៊ីវ ស្រេងលីម និង ឧ.សិ.ហួត ឃីម...........  ស.រ.អ.

៤- ឧ.ស. ហៃ ប៊ុនណារិន និង ឧ.សិ.អោង ស៊ីថាន់ ........... ស.រ.អ.

៥- ឧ.ស. វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ..... ស.រ.អ.

៦- ឧ.សិ. ឆាន់ ហៃកឹង ព្រមទាំងបុត្រ និង ចៅ ................ ស.រ.អ.

៧- ឧ.សិ.ប៊ិត ថងខាំ និង ឧ.សិ.សាន ផល្លីន ព្រមទាំងបុត្រ ... ស.រ.អ.

៨- ឧ.សិ. ស៊ីវ យក់លុយ .............................................. ស.រ.អ.

៩- ឧ.ស. អ៊ុត ឆៃវ៉ាន និង ឧ.សិ.ធាន ស៊ុនលី ព្រមទាំងបុត្រ.. ស.រ.អ.

១០- ឧ.ស. ប្លោក ងួនថៃ និង ឧ.សិ.ធាន ត្រលុច + បុត្រ ....... ស.រ.អ.

១១- ឧបាសិកា អ៊ឹង ស៊ីវន .............................................. ស.រ.អ.

១២- ឧ.ស.សូ ហុកឡុង និង ឧ.សិ.កាន់ ឈីវហា ............... ស.រ.អ.

១៣- ឧ.ស. អៀង ឆាយ និង ឧ.សិ. អៀ កេសរ +បុត្រ ........ ស.រ.អ.

១៤- លោកតា តាន់ ឈីវហា និង លោកយាយ ស៊ូ ចិន្ត្រ ......... ស.រ.អ.



១៥- ឧ.សិ. តែ សាយជូ ព្រមទាំងកូនចៅ ......................... ស.រ.អ.

១៦- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ .......... ស.រ.អ.

១៧- ពុទ្ធបរិស័ទ ចាន់ នារីសុខ និងក្រុមគ្រួសារ ................... ស.រ.អ.

១៨- ឧ.សិ. ម៉ិល យ៉ែម ................................................ ស.រ.អ.

១៩- ឧ.ស.សារឿន ឧ.សិ.លាប+ឧ.ស.ហ៊ឹស៊ី ឧ.សិ.អាន ......... ស.រ.អ.

២០- ឧបាសក តាំង ស៊ុនម៉ាប ......................................... ស.រ.អ.

២១- លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ .................. ស.រ.អ.

២២- លោកយាយ ពិន សាត .......................................... ស.រ.អ.

២៣- លោក ចាន់ ម៉ល់ និងអ្នកស្រី ជា សុផា ....................... ស.រ.អ.

២៤- ភិក្ខុ ឈម បូ ( វិជ្ជាសម្បទា ) ................................... ស.រ.អ.

២៥- ឧ.ស. ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ................. ស.រ.អ.

២៦- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ............................................ ស.រ.អ.

២៧- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា+បុត្រ........ ស.រ.អ.

២៨- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ........................... ស.រ.អ.

២៩- ឧ.ស.ឡៅ ហោ និង ឧ.សិ.ង៉ោ ស៊ូអេង ....................... ស.រ.អ.

៣០- ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅ១ ............ ស.រ.អ.

៣១- ឧ.សិ.ស្រង់ អៃ និង ឧ.សិ.ស្រង់ ឡេង ....................... ស.រ.អ.

៣២- ឧ.សិ.ឧត្តមា ពេជ្រ អួន ........................................... ស.រ.អ.

៣៣- ឧ.ស.វ៉ាង សារ៉ុធ និង ឧ.សិ.គង់ ស៊ីណាត +បុត្រ .......... ស.រ.អ.

៣៤- ភិក្ខុ ឈួម បូ ( វត្តពន្លឺពុទ្ធចក្រ លោវែល ) .................. ស.រ.អ.

៣៥- លោក ពេជ្រ សីហា និងអ្នកស្រី ថាប់ សុរត្ន័ ................. ស.រ.អ.

៣៦- ឧ.ស.ប៊ុត ផល និង ភរិយា ...................................... ស.រ.អ.

៣៧- លោកគ្រូធម្មបណ្ឌិត អឿ សៅ ................................ ស.រ.អ.

៣៨- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង រីទ្ធារី  ព្រមទាំងបុត្រ ... ស.រ.អ.

៣៩- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា.............. ស.រ.អ.

៤០- ឧ.សិ.ឡុង អ៊ឹម .................................................... ស.រ.អ.

៤១- ឧ.សិ.ច័ន្ទ ប៉ុណ្ណារី................................................... ស.រ.អ.

៤២- ឧ.សិ.ហោ ប៊ួយ និងឧ.សិ.ហោ មួយ ហៅតាំងហ៊្គិចមួយ ... ស.រ.អ.

៤៣- លោក សំណាង យឹម និង អ្នកស្រី ឡូរ៉ា យឹម .............. ស.រ.អ.

៤៤- ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... ស.រ.អ.

៤៥- ឧ.ស.អ៊ុក សាមឿន និង ឧ.សិ.វួច អ៊ឹម ព្រមទាំងបុត្រ ..... ស.រ.អ.

៤៦- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ ..... ស.រ.អ.

៤៧- ឧ.សិ.តាំង លេខគៀវ ព្រមទាំងបុត្រ និងចៅ ............... ស.រ.អ.

៤៨- ឧ.សិ.នួន ប៊ុច និង ឧ.សិ.រស់ សុផល .......................... ស.រ.អ.

៤៩- ឧ.ស.ហោ លាន និង ភរិយា ..................................... ស.រ.អ.

៥០- ឧ.ស.អ៊ុន ឆៃត្រី និង ភរិយា .................................... ស.រ.អ.

**-១៣៣-**

៥១- ឧ.សិ.មិល យ៉ែម និង ឧ.សិ.គួយ ឡេង ....................... ស.រ.អ.

៥២- ឧ.សិ.ហុក ឈិន និង ឧ.សិ.ប្រាក់ អៀត ព្រមទាំងកូនចៅ  ស.រ.អ.

៥៣- ឧ.សិ.ប៉ាន់ ពិណ្ណារី និងស្វាមី ព្រមទាំងបុត្រ .................. ស.រ.អ.

៥៤- ឧ.សិ.ស៊ុន ឡេង ព្រមទាំងបុត្រ និងចៅ ....................... ស.រ.អ.

៥៥- លោក សួន សាលាភ និងអ្នកស្រី សួ សកនីន + បុត្រ ..... ស.រ.អ.

៥៦- ភិក្ខុ ឡូញ ផល្លី និង ភិក្ខុ ភឿក បូរ .......................... អូស្ត្រាលី

៥៧- ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ....... អូស្ត្រាលី

៥៨- ឧ.សិ.ឱម លក្ខណា  ព្រមទាំងបុត្រធីតា ...................... អូស្ត្រាលី

៥៩- ឧ.ស.លីម ងីនសួ និង ឧ.សិ. អ៊ឹង ឆាយហួ +បុត្រ. ........ អូស្ត្រាលី

៦០- ឧ.ស.ប៉ុច វឿត  និង ឧ.សិ.ញូង ស៊ាងម៉េង+បុត្រ .......... អូស្ត្រាលី

៦១- ឧ.សិ. ឈ គឹមស៊ីន និង ក្រុមគ្រួសារ ......................... អូស្ត្រាលី

៦២- ឧ.សិ. សេង សៀងឈុន ព្រមទាំងបុត្រ ...................... អូស្ត្រាលី

៦៣- ឧ.សិ.ស៊ិត ស៊ីវន ................................................ អូស្ត្រាលី

៦៤- ឧ.សិ. អ៊ុក ណារី ព្រមទាំងបុត្រ ............................. អូស្ត្រាលី

៦៥- កញ្ញា ស៊ុយ ដាណែត ............................................ អូស្ត្រាលី

៦៦- យុវជន ចាន់ ឌីណា ............................................. អូស្ត្រាលី

៦៧- ឧ.ស.យ៉ង់ សិន និងឧ.សិ.នន់ ហេង +បុត្រ.................. អូស្ត្រាលី

៦៨- ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ... អូស្ត្រាលី

**-១៣៤-**

៦៩- ឧ.ស.សរ ប៊ុនធៀង ព្រមទាំងបុត្រ និងចៅ................. អូស្ត្រាលី
៧០- ឧ.សិ.នូ ធុច ព្រមទាំងបុត្រ និងចៅ........................... អូស្ត្រាលី
៧១- យាយ ប្រាក់ខាត់ +ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ .. អូស្ត្រាលី
៧២- ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង + បុត្រ ...... អូស្ត្រាលី
៧៣- ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.ពា ស៊ីម +បុត្រនិងចៅ ........... អូស្ត្រាលី
៧៤- ឧ.ស.ឃិន ថុងអ៊ាន និង ឧ.សិ.ម៉េង គិមស៊ាន + បុត្រ..... អូស្ត្រាលី
៧៥- ឧ.ស.សុខ សារឿន និង ឧ.សិ.មោក មី + បុត្រ............ អូស្ត្រាលី
៧៦- ឧ.សិ.យុង សុន ព្រមទាំងបុត្រ................................. អូស្ត្រាលី
៧៧- ឧ.ស. លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី +បុត្រ ......... អូស្ត្រាលី
៧៨- ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ .អូស្ត្រាលី
៧៩- ឧ.សិ.ម៉េង ប៊ុនធារី ( ហៅស្រីពៅ ) ......................... អូស្ត្រាលី
៨០- ឧ.សិ.ជា ឡេង .................................................... អូស្ត្រាលី
៨១- ឧ.ស.សាប់ ភូរិន្ទ .................................................. អូស្ត្រាលី
៨២- ឧ.ស.ស៊ូ ឃីម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ ...... អូស្ត្រាលី
៨៣- លោក ឃឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ .... អូស្ត្រាលី
៨៤- ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ .... អូស្ត្រាលី
៨៥- Mr ANARING និងអ្នកស្រី កាយ សផា+បុត្រ+បងប្អូន . អល្លឺម៉ង់
៨៦- លោក យូណូស អាស៊ីស និង អ្នកស្រី ហុក ណារី+បុត្រ .... បារាំង



៨៧- ឧ.ស.ង៉ូវ ជួនណារេត និង ឧ.សិ.ង៉ូវ សោភ័ណ+បុត្រ........... បារាំង
៨៨- ឧ.ស. ឡុក ប៊ុនអ៊ីវ និង ឧ.សិ.តាន់ ស៊ីវឡាង+បុត្រ............ បារាំង
៨៩- ឧ.សិ. អ៊ឹង ហ្គេចតេង ព្រមទាំងបុត្រ ........................... បារាំង
៩០- ឧ.ស. ឡោ សេងជ្រុន និង ឧ.សិ.ផាំង លី ព្រមទាំងបុត្រ..... បារាំង
៩១- ឧ.សិ. ជា ម៉ាក់លាង ................................................. បារាំង
៩២- ឧ.ស.ហ្វាន់ វ៉ាន់ហួ និង ឧ.សិ.ហ្វាន់ យូលាង ................... បារាំង
៩៣- ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ .................. បារាំង
៩៤- ឧ.សិ.គីម មុយ ព្រមទាំងក្រុមគ្រួសារ .......................... បារាំង
៩៥- ឧ.សិ.ទាវ គីមហ៊ួន ព្រមទាំងកូនចៅ ............................. បារាំង
៩៦- ឧ.សិ.ដៀប រុន ព្រមទាំងបុត្រធីតា .............................. បារាំង
៩៧- ឧ.ស.បាន ណារិន និង ឧ.សិ.ហោ ចន្ធូ ព្រមទាំងបុត្រ......... បារាំង
៩៨- ឧ.ស.ជីន ជុង និងភរិយា............................................ បារាំង
៩៩- ឧ.សិ.អ៊ឹង យ៉េកសាង ព្រមទាំងបុត្រ ............................ បារាំង
១០០- ឧ.ស.ឈុត ស៊ីថន និង ឧ.សិ.អូ សុផា ព្រមទាំងបុត្រ ....... បារាំង
១០១- ឧ.សិ.ឆាយ ស៊ន ព្រមទាំងបុត្រ+ចៅ+ចៅទួត........... កាណាដា
១០២- ឧ.ស.ពុធ ប៉ោលាង និង ឧ.សិ. ហ៊ុន ស៊ីវអៀង +បុត្រ.. កាណាដា
១០៣- Chhem Sokreth et Puth Kunthea ............... កាណាដា
១០៤- ឧ.សិ. អ៊ា នៅ ព្រមទាំងបងប្អូនកូនចៅ ................. កាណាដា

១០៥- ឧ.សិ. ចំណាន ព្រមទាំងក្រុមគ្រួសារ ...................... កាណាដា

១០៦- ឧ.សិ. លី វ៉ន ព្រមទាំងក្រុមគ្រួសារ ....................... កាណាដា

១០៧- ឧ.ស.ឡាវ លាងថេង និង ឧ.សិ.ពឹង ឈីវអ៊ាន........... កាណាដា

១០៨- ឧ.សិ.លាន ម៉ិច ................................................ កាណាដា

១០៩- ឧ.សិ.តាន់ វ៉ួចឆាយ ........................................... កាណាដា

១១០- ឧ.ស.ហេង ជាវ និង ឧ.សិ.កាយ ហួន ព្រមទាំងបុត្រ . កាណាដា

១១១- ឧ.ស. យន្ត សួន និង ឧ.សិ.តាំង ឈុងប៊ួយ ព្រមទាំងបុត្រ. ភ.ព.

១១២- ឧ.ស.ធ្នាំ ( ធម្ម ) ប៊ុនស្រេន និង ឧ.សិ.យ៉ែម សួស្តី+បុត្រ .. ភ.ព.

១១៣- ឧ.ស.សយ ស៊ីផាន់ណា និង ឧ.សិ.ម៉ៅ សុផល+បុត្រ ....... ភ.ព.

១១៤- ឧ.សិ. ច័ន្ទ បុប្ផាណា ព្រមទាំងបុត្រធីតា ........................ ភ.ព.

១១៥- ឧ.សិ.សួន កល្យាណ ............................................... ភ.ព.

១១៦- ឧ.សិ.សួន ចរណៃ ................................................. ភ.ព.

១១៧- ឧ.សិ.ប៉ក់ សូត្រសុភាព ព្រមទាំងបុត្រ ......................... ភ.ព.

១១៨- ឧ.ស.ម៉ៅ សុគន្ធ និង ឧ.សិ.អ៊ឹង យ៉េកហួយ និងបុត្រ ..... ភ.ព.

១១៩- ឯ.ឧ.អ៊ិត ប្រាំង និង លោកជំទាវ ញ៉ែម សេដ្ឋា +បុត្រ ...... ភ.ព.

១២០- ឯ.ឧ.ចែម វីឡា និង លោកជំទាវ សុខា ស៊ូលីវណ្ណ+បុត្រ .. ភ.ព.

១២១- ឯ.ឧ.កាន់ វ៉ាត់ និង ឧ.សិ.កែវកល្យាណ+ក.កាន់សុថារ័ត្ន... ភ.ព.

១២២- ឯ.ឧ. ឯម ប៊ុនសាត និង លោកជំទាវ នូ ចន្ថា + បុត្រ...... ភ.ព.



១២៣- ឧកញ៉ា ស៊ិន សុខា និង លោកជំទាវ សុខា ផល្លី +បុត្រ .... ភ.ព.

១២៤- ឧកញ៉ា សេង ឆាយអ៊ូរ និង ឧ.សិ.កាំង ហ៊ួចណៃ+បុត្រ .... ភ.ព.

១២៥- ឧកញ៉ា សុខ សុខា និង លោកជំទាវ ចាន់ លាង +បុត្រ ..... ភ.ព.

១២៦- ឧ.ស.ប៉ុល នាង និង ឧ.សិ.គ្រៀល ស៊ីយ៉ា +បុត្រ ............ ភ.ព.

១២៧- ឧ.ស.ឡាយ សុខុម និង ឧ.សិ.សួន ចន្ថា និងបុត្រ ........... ភ.ព.

១២៨- ឧ.ស.យឹម ស៊ីមុន្នី និង ឧ.សិ.យូ ប៉ូលីន និងបុត្រ ............. ភ.ព.

១២៩- ឧ.សិ. ប៉ូអាន ស៊ីវុត្ថា .............................................. ភ.ព.

១៣០- ឧ.សិ. ប៉ូ ផាវ៉ាណេ ................................................ ភ.ព.

១៣១- ឧ.សិ. ម៉ៅ សុន្ថា ...................................................ភ.ព.

១៣២- ឧ.សិ. សាក់ ស៊ាងអេង ព្រមទាំងបុត្រ ......................... ភ.ព.

១៣៣- ឧ.ស. ស៊ីវ សៅរ៍ និង ឧ.សិ. ស្រៀង វ៉ួចលាង ............... ភ.ព.

១៣៤- ឧ.ស.អ៊ុក សាម៉ាណារ៉ា និង ឧ.សិ.ហ៊ាប តេង + បុត្រ...... ភ.ព.

១៣៥- ឧ.ស. ម៉ៅ ស្រ៊ិន និង ឧ.សិ. ទូច ស៊ីនហ៊ន ព្រមទាំងបុត្រ. ភ.ព.

១៣៦- ឧ.ស. ម៉ែន សឿន និង ឧ.សិ. អៀង ណារី + បុត្រ ......... ភ.ព.

១៣៧- ឧ.សិ. សយ វណ្ណា និង ស្វាមី ព្រមទាំងបុត្រ ................ ភ.ព.

១៣៨- លោក សែន សុវណ្ណារិទ្ធ និងភរិយា .............................. ភ.ព.

១៣៩- ឧ.សិ. តាន់ ជាលី និងពុទ្ធបរិស័ទខេត្តសៀមរាប ............. ស.រ.

១៤០- ឧ.សិ.ជុំ ឆាយ + ឧ.សិ.ជុំ ណារ៉ា+ជុំ ពិសិដ្ឋ+ជុំ សុជាតិ ...... ភ.ព.

១៤១- ឧ.សិ. ស៊ីវ យក់លី ................................................. ភ.ព.

១៤២- ឧ.ស. ជាន យ៉ែត និង ឧ.សិ. សុក ចេង ព្រមទាំងបុត្រ .... ភ.ព.

១៤៣- ឧ.ស. សោម រតនៈ និង ឧ.សិ. ស៊ិប វណ្ណា + បុត្រ + ចៅ.. ព.វ.

១៤៤- ឧ.ស.ហេងសម្បូរដ្ឋ ឧ.សិ.ស៊ិនគន្ធា+មាតាហេងបូរីស្រីនាថ ភ.ព.

១៤៥- យុវជន ជា សុភ័ក្ត្រ និងមាតាបិតា .............................. ភ.ព.

១៤៦- ឧ.សិ.ហ៊ុយ សុខម៉ា និងស្វាមី ព្រមទាំងបុត្រ ................. ភ.ព.

១៤៧- ឧ.សិ. វណ្ណ មុនី ព្រមទាំងបុត្រ និងចៅ ......................... ភ.ព.

១៤៨- ឧ.ស.តៅ ឃាង និង ឧ.សិ. ឈុន លន ព្រមទាំងកូនចៅ.... ភ.ព.

១៤៩- ឧ.សិ. សុខ ភួង និង ឧ.សិ. សុខ ផៃ .............................. ភ.ព.

១៥០- ឧ.សិ. អ៊ុក លន់ និងក្រុមវេន ព្រមទាំងបុត្រ .................. ភ.ព.

១៥១- ឧ.សិ. គង់ ម៉ៃ ព្រមទាំងបុត្រ និងចៅ ......................... ភ.ព.

១៥២- ឧ.សិ.លី ស៊ីវជូ ព្រមទាំងបុត្រ ................................... ភ.ព.

១៥៣- ឧ.សិ.មុំ ទូច និងឧ.សិ.សាមុល គឹមធន់ (ជាកូន )............ភ.ព.

១៥៤- ឧ.ស.ម៉ៅ វ៉ាន និង ឧ.សិ.ធន់ សំបូរ ព្រមទាំងបុត្រ.......... ភ.ព.

១៥៥- លោក ម៉េង ហ៊ា អ្នកស្រី ម៉ាន ស៊ីសុថា និងបុត្រ ............. ភ.ព.

១៥៦- ឧ.ស.ចៅ ហ្វា និង ឧ.សិ.ឡា គឹមសាន និងបុត្រ ............ ភ.ព.

១៥៧- ឧ.សិ.វឿន គង់+ស្វាមី និង លោក ប្រាក់ ខេមរិន្ទ+ភរិយា... ភ.ព.

១៥៨- ឧ.សិ.ឯម សុខឃីម និង ស្វាមី ព្រមទាំងបុត្រ ................ ភ.ព.

-១៣៩-

១៥៩- លោកយាយ ប៊ុន យ៉ាំ ព្រមទាំងកូន និងចៅ .................. ភ.ព.

១៦០- ឧ.សិ.ហេង ស៊ីវខេង និងម្ដាយឈ្មោះ អៀង ហ៊ួច ...... កណ្ដាល

១៦១- ឧ.សិ.អ៊ិតឆេងស៊ី ក្រុមវេនថ្ងៃ២កើតវត្តព្រះពុទ្ធមានបុណ្យ. ភ.ព.

១៦២- ក្រុមព្រែកខ្ទិត ព្រែកលាប និងទួលគោក ..................... ភ.ព.

១៦៣- ក្រុមចាបម៉ុងឡេង+ឈាងហុង វេន៩កើតសំពៅមាស .... ភ.ព.

១៦៤- ឧ.ស.ហេង ឆៃទិត និង ឧ.សិ.រស់ ម៉ាលី ព្រមទាំងបុត្រ.... ភ.ព.

១៦៥- ឧ.ស.ឡាយ ហ៊ុយទ្រៀង និង ឧ.សិ.លាក ណាក់ +បុត្រ ... ភ.ព.

១៦៦- ឧ.ស.តូច ផាន់ណាស៊ី និង ឧ.សិ.សុខ ច័ន្ទណារិទ្ធ+បុត្រ...... ភ.ព.

១៦៧- ឧ.ស.សូរ សារឹម និង ឧ.សិ.បុង ផល្លី ព្រមទាំងបុត្រ ........ ភ.ព.

១៦៨- ឧ.សិ.ហែម វណ្ណា និង ឧ.សិ.ហែម វុឌ្ឍី +បុត្រ ................ ភ.ព.

១៦៩- ឧ.ស.យ៉ាំ ស្រេន និង ឧ.សិ.អ៊ុល សេងលាង + បុត្រ.......... ភ.ព.

១៧០- ឧ.ស.ស៊ីន វ៉ា+យានថៃ+ឧ.ស.ស៊ីនម៉េងស្រ៊ុន+ប្អូជុំស៊ីន ..... ភ.ព.

១៧១- ឧ.សិ.ជា សុណារី .................................................. ភ.ព.

១៧២- ឧ.ស.ភាវ សាន និង ឧ.សិ.ប៉ក់ សុបុណ្យ+បុត្រ................ ភ.ព.

១៧៣- ឧ.ស.ម៉ូង យឿនវណ្ណៈ និង ឧ.សិ.ប៉ក់ សូត្រសុទ្ធី+បុត្រ..... ភ.ព.

១៧៤- ឧ.ស.ស៊ឹម សុង ឧ.សិ.ឆៃ គាង+ពុទ្ធបរិស័ទផ្សារកអណ្ដើក. ព.វ.

១៧៥- លោក រឿង សេដ្ឋា និងអ្នកស្រី នាង ជួនអេង + បុត្រ ..... ភ.ព.

១៧៦- លោក ស៊ា រស់ និងអ្នកស្រី ញ៉េប ដារ៉េត ព្រមទាំងបុត្រ .. ភ.ព.

-១៤០-

១៧៧- ឧ.សិ.ឈួន គីមនី និងបងប្អូន កូនក្មួយ ......................... ភ.ព.

១៧៨- ឧ.សិ.គ្រី ណៃប៊ួយ ព្រមទាំងបុត្រ .............................. ភ.ព.

១៧៩- ឧ.សិ.ច្រឹង គីមស្រ៊ី ព្រមទាំងបុត្រ .............................. ភ.ព.

១៨០- ឧ.ស.ម៉ៅ ផុន និងមាតា យស សម្បត្តិ ........................ ភ.ព.

១៨១- ឧ.ស.ម៉ៅ សយ និង ឧ.សិ.គង់ ចំរើន +បុត្រ ................. ភ.ព.

១៨២- ឧ.សិ.ហ៊ុយ ព្រឿងគិមស្រ៊ាង ព្រមទាំងបុត្រ និងចៅ......... ភ.ព.

១៨៣- ក្រុមឧ.ស. មួង យេន វត្តសំពៅមាស ..................... ភ.ព.

១៨៤- ឧ.សិ.ថៅ ហៀក ព្រមទាំងបុត្រ ................................ ភ.ព.

១៨៥- ឧ.ស.ខៀវ ជៀប និង ភរិយា ព្រមទាំងបុត្រ +ចៅ ......... ភ.ព.

១៨៦- ឧ.សិ.តាំង លីគាង និង ស្វាមី ព្រមទាំងបុត្រ +ចៅ ......... ភ.ព.

១៨៧- ឧ.សិ.ឈឹម ផលវិទ្យា ............................................ ភ.ព.

១៨៨- ឧ.សិ.កាំង ប៉ោទាង និង ឧ.ស.ហេ អេន +កូនចៅ ........... ភ.ព.

១៨៩- ឧ.សិ.លីម មួយគា និង លោក យុន ឈុន្នី+អ្នកស្រី ទី មុំ... ភ.ព.

១៩០- ឧ.ស.បេង ហុងសុជាតិដារិដ ឧ.សិ.ប៉ក់ សុខបូផាន+បុត្រី... ភ.ព.

១៩១- ឧ.សិ.លឹម អេង ព្រមទាំងបុត្រ ................................ ភ.ព.

១៩២- ឧ.ស.ង៉ូវ គា និង ឧ.សិ.ឈុន គីមអេង ព្រមទាំងបុត្រ....... ប.ប.

១៩៣- លោក លាភ ឆាយ និង អ្នកស្រី ហែម ពៅ + បុត្រ.......... ភ.ព.

១៩៤- ឧ.ស.ម៉េង សាខន និង ឧ.សិ.ចាន់ សុខា ព្រមទាំងបុត្រ...... ភ.ព.



១៩៥- ឧ.សិ.យ៉ាន ច័ន្ទលី .................................................. ភ.ព.

១៩៦- ឧ.សិ.លឹម វួចហ៊ាង ព្រមទាំងបុត្រ និងចៅ .................. ភ.ព.

១៩៧- ឧ.ស.ស្រួ ងាម និង ឧ.សិ.ហ៊ួង ម៉ន ............................. ភ.ព.

១៩៨- ឧ.សិ.យឹម សាវ៉ាត និង ឧ.សិ.លី ហ្គេចឡាង+ស្វាមី+បុត្រ.. ភ.ព.

១៩៩- ឧ.ស. ស៊ុយ ជូ និង ឧ.សិ. តាំង ទៀង .......................... ភ.ព.

២០០- ឧ.សិ.រស់ សេរី និង ឧ.សិ.សឿ ចន្ថា............................ ភ.ព.

២០១- ឧ.សិ.រៀល យ៉ូន ព្រមទាំងបុត្រ ................................. ភ.ព.

២០២- ឧ.ស.សុខ សារឿន និង ឧ.សិ.ទូច ម៉ុម ហៅឃីម +បុត្រ... ភ.ព.

២០៣- ឧ.ស.គង់ សៀងហៃ និងឧ.សិ.ប៉ក់ សូត្រតារាភិឱន+បុត្រ. ភ.ព.

២០៤- ឧ.ស.ងីម ញាណ និង ឧ.សិ.កាំង ប៉ូលីន ព្រមទាំងបុត្រ. ក.ព.ស.

២០៥- ឧ.ស. យូ ម៉េង និង ឧ.សិ. ជួន សំណាង.................... ក.ព.ស.

២០៦- ឧ.ស.ជ្រា បេង និង ឧ.សិ.គ្រិត គីម ព្រមទាំងបុត្រ ......... ភ.ព.

២០៧- ឧ.សិ.ហ៊ុយ រ៉ាវី និង ស្វាមី ព្រមទាំងបុត្រ ..................... ភ.ព.

២០៨- ឧ.សិ.ប៊ូ សៀកហ៊ុន ព្រមទាំងបុត្រ និងចៅ ................... ភ.ព.

២០៩- វេជ្ជ.ហ៊ាន រ៉ាវី និង ឧ.សិ.ម៉ូវ លាង ព្រមទាំងបុត្រ ........... ភ.ព.

២១០- ឧ.ស.ម៉ូវ ធីម និង ឧ.សិ.ហ៊ាន ណៃឃីម ព្រមទាំងបុត្រ ... ភ.ព.

២១១- ឧ.ស.ហ៊ាន រ៉ាវឿន និង ឧ.សិ.ប៉ែន បុប្ផា ព្រមទាំងបុត្រ .... ភ.ព.

២១២- ឧ.ស.ង៉ែត ផេង និង ឧ.សិ.ហៅ ហេង +បុត្រផេង បូរ៉ា .... ភ.ព.

២១៣- ឧ.សិ. ថៃ នាថ ព្រមទាំងបុត្រ និងចៅ ......................... ភ.ព.

២១៤- ឧ.ស.វ៉ៃន សារូ និង ឧ.សិ.តូច លីណារ៉ា ព្រមទាំងបុត្រ .... ភ.ព.

២១៥- លោក ជា សារ៉ាយ និង អ្នកស្រី អ៊ុំ សុផានី +បុត្រ+ចៅ ... ភ.ព.

២១៦- ឧ.ស.មាស ខេង និង ឧ.សិ.មួរ វ៉ួច ព្រមទាំងកូនចៅ ....... ភ.ព.

២១៧- ឧ.ស.ឃុត គឹមថន + ឧ.ស.ព្រុំ សុន និង ភរិយា ............ ភ.ព.

២១៨- ឧ.សិ. គឹម សុខុន និងបុត្រ ........................................ ភ.ព.

២១៩- ឧ.សិ.ឯម សុខន ព្រមទាំងបុត្រ និង ឧ.សិ.សុខ សាអ៊ីក..... ភ.ព.

២២០- ឧ.សិ.អ៊ូស៊ីណាត+ឧ.ស.ឡឹងជី និងឧ.សិ.អ៊ូ ប៊ុននី+កូនចៅ . ភ.ព.

២២១- ឧ.សិ.គឹម ឆេង ព្រមទាំងកូនចៅ ................................ ភ.ព.

២២២- ឧ.សិ.ជូ ឆេងហោ .................................................... ភ.ព.

២២៣- ឧ.សិ.លី ឡៃហ៊ាង ព្រមទាំងបុត្រ និងចៅ ................... ភ.ព.

២២៤- ឧ.ស.ថាច់ លី និង ឧ.សិ.ភ្យេង ភ្យេង .......................... ភ.ព.

២២៥-Mr.JONATHAN BALK and Mss.BUNNA KEO BALK ភ.ព.

២២៦- ឧ.សិ.ព្រុំ សុភាព .................................................... ភ.ព.

២២៧- លោក សឹក ធឿន+ឧ.ស.វុទ្ធី សម និង ឧ.សិ.គឹម អេង .... ភ.ព.

២២៨- លោក ស្រេង ហេង និង ឧ.សិ.កែវ រស្មី ព្រមទាំងបុត្រ ... ភ.ព.

២២៩- ឧ.ស.នុត វន្ថា និង ឧ.សិ.ម៉ៅ សុភា ព្រមទាំងបុត្រ ......... ភ.ព.

២៣០- ឧ.សិ.អ៊ូ សំណាង និង ឧ.សិ.ឡាច ផន ព្រមទាំងបុត្រ ...... ភ.ព.

-១៤៣-

២៣១- ឧ.ស.ជា សុខុម និង ឧ.សិ.អ៊ុន ពូន .............................. ភ.ព.

២៣២- ឧ.ស.ឡាយ សេង និងឧ.សិ.ម៉ែន វណ្ណា ព្រមទាំងកូនចៅ . ភ.ព.

២៣៣- ឧ.សិ.ជុំ ស៊ីម៉ុន និងបុត្រ ពេជ្រ សុឃុន ......................... ភ.ព.

២៣៤- ឧ.ស.ស៊ា បូរ៉ា និង ឧ.សិ.ប៉ុល បុទម +បុត្រ ស៊ា ស៊ូជីង .... ភ.ព.

២៣៥- ឧ.ស.គង់ ហេង និង ឧ.សិ.ធាវ ស៊ីប ព្រមទាំងកូនចៅ ..... ភ.ព.

២៣៦- ឧ.សិ.ហ៊ុន ហេង ..................................................... ភ.ព.

២៣៧- ឧ.ស.ទី គៀង និង ភរិយា ព្រមទាំងបុត្រ ..................... ភ.ព.

២៣៨- ក្រុមលោកតា ម៉ោង វត្តទួលទំពូង ............................. ភ.ព.

២៣៩- ឧ.សិ.តោ ឡោ ព្រមទាំងកូនចៅ ................................ ភ.ព.

២៤០- ឧ.ស.ហង់ ច័ន្ទរិទ្ធ និង ឧ.សិ.ដួង រ៉ាវី ព្រមទាំងបុត្រ ......... ភ.ព.

២៤១- ឧ.សិ.ជា ស៊ីវយ៉េក ព្រមទាំងបុត្រ ................................ ភ.ព.

២៤២- ឧ.ស.សេង តាំងឃី និង ឧ.សិ.ហេង មួយចេង + បុត្រ .... ភ.ព.

២៤៣- ក្រុមវេនចង្ហាន់សង្ឃ ,១កើតសំពៅមាស ,៦កើតចំបក់មានជ័យ,
១១កើតសុវណ្ណបទុម,៦រោចនិគ្រោធវ័ន,១០រោចវេឡុវ័ន..ភ.ព.

២៤៤- មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ខេត្តពោធិ៍សាត់.... ព.ស.

២៤៥- ក្រុមពុទ្ធបរិស័ទស្រុកមង្គលបូរី+សិរីសោភ័ណ ............. ប.ម.ជ.

២៤៦- ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី និងមែលប៊ន.. ប្រទេសអូស្ត្រាលី

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

-១៤៤-

# I

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -04h50 mn<br>-05h00 mn<br>-05h30 mn<br>-12h10 mn<br>-18h00 mn<br>-19h00 mn<br>-20h00 mn<br>-20h30 mn | -FM 98 MHz<br>-FM 99 MHz<br>-FM 96 MHz<br>-FM 96 MHz<br>-FM 95 MHz<br>-AM 918 KHz<br>-FM 98 MHz<br>-FM 96 MHz |
| ក្រុងព្រះសីហនុ | -06h00 mn<br>-13h00 mn<br>-17h30 mn | -FM 92 MHz<br>-FM 92 MHz<br>-FM100.5MHz |
| ខេត្តបាត់ដំបង | -05h30 mn<br>-06h00 mn<br>-18h00 mn<br>-18h30 mn<br>-19h30 mn | -FM103.2MHz<br>-FM 92.7MHz<br>-FM 91 MHz<br>-FM 92.7MHz<br>-FM103.2MHz |
| ក្រុងប៉ៃលិន | -18h00 mn | -FM 90.5MHz |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង ។



# II

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| ខេត្តពោធិ៍សាត់ | -06h00 mn | -FM 98.5 MHz |
| ខេត្តសៀមរាប | -05h00 mn<br>-05h30 mn<br>-18h30 mn | -FM 98 MHz<br>-FM 105.5 MHz<br>-FM 100.5 MHz |
| ខេត្តបន្ទាយមានជ័យ | -05h20 mn<br>-17h00 mn | -FM 96.5 MHz |
| ខេត្តកំពត | -05h00 mn<br>-18h30 mn | -FM 93.25 MHz<br>-FM 103.5 MHz |
| ខេត្តព្រះវិហារ | -18h30 mn | -FM 99 MHz |
| ខេត្តឧត្តរមានជ័យ | -05h00 mn<br>-19h00 mn | -FM 90.25MHz |
| ខេត្តស្ទឹងត្រែង | -18h30 mn | -FM100.5 MHz |
| ខេត្តស្វាយរៀង | -05h30 mn | -FM103.75MHz |
| ខេត្តក្រចេះ | -05h30 mn | -FM 98.5 MHz |
| ខេត្តរតនគីរី | -18h30 mn | -FM 89.5 MHz |
| ខេត្តតាកែវ | -17h00 mn | -FM 92.5 MHz |

## សៀវភៅដែលរៀបរៀងដោយ

## ខ្ញុំព្រះករុណា ខ្ញុំបាទ

## ✍ ប៊ុត_សាវង្ស ✍

១. ព្រះពោធិសត្វ ភាគទី ១

២. ជំនួយសតិភាគទី ១ ដល់ភាគទី ១៣

៣. មនុស្សជាមួយនឹងការងារ

៤. សិក្ខាបទមនុស្សល្អ

៥. ពរ ៤ ប្រការ

៦. ព្រះពុទ្ធភាសិត ៤៣ គាថា

៧. ខ្លឹមសារគួរយល់ដឹង

៨. ព្រះពុទ្ធសាសនា

៩. កូនមាសឪពុក

១០. ម៉ែ !!!

១១. វិធីរម្ងាប់សេចក្តីក្រោធ

១២. សុខចិត្ត និងគុណភាពនៃជីវិត

១៣. មេរៀនជីវិត



១៤. ពាក្យពេចន៍ម៉ែឪ

១៥. បទពិចារណា

១៦. ពន្លឺធម៌ព្រះពុទ្ធ

១៧. បារមីភាគទី ១ និងខ្លឹមសារខ្លីៗ

១៨. បារមីភាគទី ២ និងខ្លឹមសារខ្លីៗ

១៩. ៤៨ ធម្មទស្សន៍

២០. ស្ត្រីក្នុងព្រះពុទ្ធសាសនា

២១. ឧបមាភាសិត ៤៩

**សូមអនុមោទនាធម្មទាន !**

**បោះពុម្ពជាធម្មទាន ៤០.០០០ ក្បាល**
**ក្នុងតម្លៃ ១៥.២០០ ដុល្លារ**
**រោងពុម្ព មិត្តភាពកម្ពុជា_ជប៉ុន**

# សារបណ្ណ

| ឈ្មោះអត្ថបទ | ទំព័រ |
| --- | --- |
| ១.វានរិន្ទជាតក ........................... | ១ |
| ២.អដ្ឋកថា វានរិន្ទជាតក .................. | ២ |
| ៣.តយោធម្មជាតក ....................... | ១០ |
| ៤.អដ្ឋកថា តយោធម្មជាតក ............... | ១១ |
| ៥.អត្ថស្ស ទ្វារជាតក ....................... | ១៩ |
| ៦.អដ្ឋកថា អត្ថស្ស ទ្វារជាតក ............... | ២០ |
| ៧.គោធជាតក ............................ | ២៧ |
| ៨.អដ្ឋកថា គោធជាតក .................... | ២៨ |
| ៩.ឆទ្ទន្តជាតក ............................. | ៣៥ |
| ១០.រៀបរៀងកំណាព្យក្នុងឆទ្ទន្តជាតក ....... | ១០៩ |
| ១១.អានិសង្សនៃការរម្ងាប់សេចក្តីក្រោធ ..... | ១១៧ |



## សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវង្ស

**ទីបង្ករពុទ្ធវង្ស ទី ១** បិដក ៧៧,ទំព័រ ២៦

ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលេចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកលះចោលទូកចាស់ យ៉ាងនោះឯង ។

បុរស កាលដើរ ទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅ យ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹង លះបង់កាយនេះចេញព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ ។